ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# ផែនការសកម្មភាពជាតិ
# ស្តីពី
# ការទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ
# ឆ្នាំ២០២៥-២០៣០

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ
នាថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៥
ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

# បុព្វកថា

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានចាត់ទុកអំពើហិង្សាលើកុមារជាការងារអាទិភាពមួយដែលគ្រប់ក្រសួង ស្ថាប័ន វិស័យឯកជន និងសង្គមស៊ីវិលត្រូវចូលរួមអនុវត្ត ក្នុងការទប់ស្កាត់និងឆ្លើយតបឱ្យបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព ដើម្បីឆ្ពោះទៅសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ដូចបានកំណត់នៅក្នុងគោលដៅ១៦.១ «កាត់បន្ថយគ្រប់ទម្រង់ទាំងអស់នៃអំពើហិង្សានិងអត្រាមរណៈ ដែលពាក់ព័ន្ធនឹងអំពើហិង្សាក្នុងកម្រិតមួយគួរឱ្យកត់សម្គាល់នៅគ្រប់កន្លែងទាំងអស់» និងគោលដៅ១៦.២ «បញ្ចប់ការរំលោភបំពាន អំពើកេងប្រវ័ញ្ច ការជួញដូរ និងអំពើហិង្សាគ្រប់ទម្រង់ព្រមទាំងការធ្វើទារុណកម្មកុមារ» និងគោលដៅ ៥.២ «លុបបំបាត់គ្រប់ទម្រង់ទាំងអស់នៃអំពើហិង្សាលើស្ត្រីនិងកុមារគ្រប់រូបនៅកន្លែងសាធារណៈនិងកន្លែងឯកជន រាប់បញ្ចូលទាំងការជួញដូរនិងការកេងប្រវ័ញ្ចផ្លូវភេទ ព្រមទាំងការកេងប្រវ័ញ្ចក្នុងទម្រង់ដទៃទៀត»។ ទន្ទឹមនេះការទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារត្រូវបានដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា។

ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិជាច្រើន មានជាអាទិ៍អនុសញ្ញាស្តីពីសិទ្ធិកុមារនៅឆ្នាំ១៩៩២ ពិធីសារបន្ថែមស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធនៅឆ្នាំ២០០៤ និងពិធីសារស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារនៅឆ្នាំ២០០២ អនុសញ្ញាលេខ១៣៨ ស្តីពីការកម្រិតអាយុអប្បបរមាសម្រាប់ការចូលធ្វើការងារនៅឆ្នាំ១៩៩៩ អនុសញ្ញាលេខ១៨២ ស្តីពីការហាមប្រាមនិងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនៅឆ្នាំ២០០៥ និងអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេសនៅឆ្នាំ២០០៧។ ទន្ទឹមនេះ ព្រះរាជាណាចក្រកម្ពុជា ក៏បានចូលជាសមាជិកនៃប្រទេសភាពជាដៃគូសកលដើម្បីលុបបំបាត់អំពើហិង្សាលើកុមារនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ និងបានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍វីប្រូថិច(WePROTECT) នៅទីក្រុងអាប៊ុយដាប៊ី នៃប្រទេសអេមីរ៉ាតអារ៉ាប់រួម(UAE)នៅឆ្នាំ២០១៥ ដែលពាក់ព័ន្ធនឹងសកម្មភាពទប់ស្កាត់ការរំលោភបំពាននិងកេងប្រវ័ញ្ចលើកុមារតាមប្រព័ន្ធអនឡាញ។

ក្នុងនាមជាប្រទេសហត្ថលេខីនៃលិខិតុបករណ៍អន្តរជាតិ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល គោលនយោបាយ ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ផែនការសកម្មភាពនានា និងពង្រឹងយន្តការកិច្ចការពារកុមារប្រទាក់ក្រឡាជាពហុវិស័យនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីទប់ស្កាត់និងឆ្លើយតបគ្រោះមហន្តរាយ ភាពក្រីក្រ អំពើហិង្សាក្នុងគ្រួសារ និងការធ្វើចំណាកស្រុក។ របាយការណ៍នៃការអង្កេតស្តីពីអំពើហិង្សាលើកុមារនៅកម្ពុជាលើកដំបូង បាននាំឱ្យមានការផ្តោតយកចិត្តទុកដាក់យ៉ាងច្បាស់លាស់លើអត្រានៃអំពើហិង្សាលើកុមារដែលផ្តល់ជាភស្តុតាងនិងជាធាតុចូលយ៉ាងសំខាន់សម្រាប់ឱ្យក្រសួងកិច្ចការនារីនិងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រៀបចំផែនការសកម្មភាពដើម្បីទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០១៧-២០២១។

ផែនការសកម្មភាពដើម្បីទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០១៧-២០២១ ត្រូវបានពន្យារការអនុវត្តសកម្មភាពដែលមិនទាន់បានបញ្ចប់រហូតដល់ដំណាច់ឆ្នាំ២០២៣ ដោយសារជំងឺកូវីដ-១៩។ ផែនការសកម្មភាពនេះត្រូវបានធ្វើការវាយតម្លៃដោយផ្តោតលើភាពពាក់ព័ន្ធ ប្រសិទ្ធភាព ភាពប្រទាក់ក្រឡា សក្តិសិទ្ធិភាព និរន្តរភាព ផលប៉ះពាល់ និងបញ្ហាអន្តរវិស័យនៃផែនការសកម្មភាព ហើយបានលើកជាអនុសាសន៍ចំនួន១១ចំណុច ក្នុងនោះបានផ្តល់អនុសាសន៍សម្រាប់រៀបចំ «ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់និង

**ឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០២៥-២០៣០»** ដែលជាផែនទីតម្រង់ទិសសម្រាប់ក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល និងវិស័យឯកជនក្នុងការបង្ការ ទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារឱ្យកាន់តែមានប្រសិទ្ធភាពនិងសក្តិសិទ្ធិភាព ឆ្លើយតបនឹងតម្រូវការរបស់កុមាររងគ្រោះនិងងាយរងគ្រោះ។

ជាគោលការណ៍ ដើម្បីអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០២៥-២០៣០នេះឱ្យទទួលបានជោគជ័យ តម្រូវឱ្យមានកិច្ចសហការ ការវិភាជធនធាន ការផ្តល់មធ្យោបាយ និងការប្តេជ្ញាចិត្តរួមពីគ្រប់ក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍ វិស័យឯកជន និងអ្នកពាក់ព័ន្ធទាំងអស់ រួមទាំងប្រជាជននិងកុមារគ្រប់រូបផងដែរ ដើម្បីប្រែក្លាយផែនការសកម្មភាពជាតិនេះឱ្យទៅជាសកម្មភាពជាក់ស្តែងនៅតាមវិស័យនីមួយៗ។ ហេតុដូច្នេះ ខ្ញុំមានការជឿជាក់ថា ជាមួយនឹងការប្តេជ្ញាចិត្តខ្ពស់និងស្មារតីនៃភាពជាម្ចាស់ក្នុងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន ព្រមទាំងកិច្ចសហការជាមួយដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងភាគីពាក់ព័ន្ធទាំងអស់ នឹងបំពេញការងារប្រកបដោយភាពទទួលខុសត្រូវខ្ពស់ និងភាពជាដៃគូល្អ ដើម្បីសម្រេចបាននូវយុទ្ធសាស្ត្រនិងសកម្មភាពចម្បងៗទាំងឡាយដែលបានកំណត់ក្នុងផែនការសកម្មភាពជាតិនេះ។ រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តយ៉ាងមោះមុតក្នុងការធ្វើការងារជាមួយដៃគូទាំងអស់ដើម្បីលុបបំបាត់អំពើហិង្សាលើកុមារ ដូចមាននៅក្នុងសេចក្តីថ្លែងការណ៍វីប្រូថិច(WePROTECT) ២០១៥ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០។

ក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំពិតជាសូមកោតសរសើរនិងសូមថ្លែងអំណរគុណដល់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រុមការងារបច្ចេកទេសអន្តរក្រសួង អង្គការក្លែនអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍនានា ដែលបានផ្តល់ការគាំទ្រទាំងថវិកា និងបច្ចេកទេសក្នុងការរៀបចំផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០២៥-២០៣០នេះ និងសូមអំពាវនាវដល់គ្រប់ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ និងសាធារណជនគ្រប់មជ្ឈដ្ឋានទាំងអស់ សូមបន្តគាំទ្រនិងរួមអនុវត្តផែនការសកម្មភាពជាតិនេះឱ្យទទួលបានប្រសិទ្ធភាពនិងប្រសិទ្ធផល ដើម្បីប្រជាពលរដ្ឋកម្ពុជា ជាពិសេសកុមាររងគ្រោះនិងងាយរងគ្រោះ រស់នៅប្រកបដោយសុវត្ថិភាពនិងសុខុមាលភាព។

ថ្ងៃ ពុធ ៥ កើត ខែស្រាពណ៍ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែកក្កដាឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

# មាតិកា


មុខកថា ..... i

ពាក្យបំព្រួញ ..... v

១- សារបាន ..... ១

១.១- គោលនយោបាយ ..... ១

១.១.១- ក្របខ័ណ្ឌជាតិ ..... ១

១.១.២- ក្របខ័ណ្ឌអន្តរជាតិ ..... ៣

១.២- ស្ថានភាពអំពើហិង្សាលើកុមារ ..... ៤

១.២.១- អំពើហិង្សាលើកុមារ ..... ៥

១.២.២- អាពាហ៍ពិពាហ៍នៅវ័យក្មេង ..... ៦

១.២.៣- ពលកម្មកុមារ ..... ៦

១.២.៤- ការជួញដូរកុមារ ..... ៧

១.២.៥- អំពើកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអ៊ីនធឺណិត ..... ៧

១.២.៦- កុមារដែលមានការប្រឈមខ្ពស់ទៅនឹងអំពើហិង្សា ..... ៨

១.៣- លទ្ធផលសម្រេចបាន ..... ៨

១.៤- ចលនាលុបបំបាត់អំពើហិង្សាលើកុមារ ..... ៩

១.៤.១- ចលនាសកលដើម្បីបញ្ចប់អំពើហិង្សាលើកុមារ ..... ៩

១.៤.២- គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ..... ៩

១.៤.៣- យុទ្ធសាស្ត្រចំនួនប្រាំពីរសម្រាប់បញ្ចប់អំពើហិង្សាលើកុមារ(INSPIRE) ..... ១០

១.៤.៤- ការឆ្លើយតបរបស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ចំពោះអំពើហិង្សាលើកុមារ ..... ១១

១.៤.៥- ការឆ្លើយតបរបស់កម្ពុជាចំពោះអំពើហិង្សាលើកុមារ ..... ១១

១.៥- ក្របខ័ណ្ឌយុទ្ធសាស្ត្រក្នុងការរៀបចំផែនការសកម្មភាពជាតិ ..... ១២

១.៥.១- ទ្រឹស្តីនៃការផ្លាស់ប្តូរស្តីពីអំពើហិង្សាលើកុមារ ..... ១៣

១.៥.២- គោលការណ៍ទូទៅនិងអភិក្រម ..... ១៤

១.៦- បញ្ហាអាទិភាព ..... ១៥

២- យុទ្ធសាស្ត្រ ..... ១៦

យុទ្ធសាស្ត្រទី១ : ការសម្របសម្រួលនិងកិច្ចសហប្រតិបត្តិការ ..... ១៦

យុទ្ធសាស្ត្រទី២ : ការបង្ការនិងទប់ស្កាត់ ..... ១៧

យុទ្ធសាស្ត្រទី៣ : សេវាឆ្លើយតបជាពហុវិស័យចំពោះកិច្ចការពារកុមារ ........ ១៧
យុទ្ធសាស្ត្រទី៤ : ការរៀបចំក្របខ័ណ្ឌគតិយុត្តនិងប្រព័ន្ធយុត្តិធម៌ ........ ១៧
យុទ្ធសាស្ត្រទី៥ : ការត្រួតពិនិត្យនិងវាយតម្លៃ ........ ១៧
**៣- ផែនការសកម្មភាព** ........ ១៧
**៣.១- វិសាលភាព** ........ ១៨
**៣.២- សកម្មភាពនៃការអនុវត្តការងារ** ........ ១៨
**៤- កាលវិភាគរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត** ........ ៤៩
**៥- គម្រោងចំណាយ** ........ ៤៩
**៦- ការត្រួតពិនិត្យនិងវាយតម្លៃ** ........ ៤៩
**៦.១- យន្តការសម្របសម្រួលថ្នាក់ជាតិ** ........ ៤៩
**៦.២- យន្តការសម្របសម្រួលថ្នាក់ក្រោមជាតិ** ........ ៥០
**៦.៣- ប្រព័ន្ធប្រមូលទិន្នន័យ** ........ ៥០
**៧- សេចក្តីសន្និដ្ឋាន** ........ ៥០
**សន្ទានុក្រម** ........ i

# ពាក្យបំព្រួញ

| | | |
|---|---|---|
| ACWC | The ASEAN Commission on the Promotion and Protection of the Rights of Women and Children | គណៈកម្មាធិការអាស៊ានស្តីពីការលើកកម្ពស់ និងការការពារសិទ្ធិស្ត្រីនិងកុមារ |
| CDHS | Cambodia Demographic and Health Survey | ការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា |
| CNCC | Cambodian National Council for Children | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |
| CNCW | Cambodian National Council for Women | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី |
| CSAM | Child Sexual Abuse Material | រូបភាព សម្ភារៈរំលោភបំពានផ្លូវភេទលើកុមារ |
| CVACS | Cambodia Violence Against Children Survey | ការអង្កេតស្តីពីអំពើហិង្សាលើកុមារនៅកម្ពុជា |
| CCWC | Commune Committee for Women and Children | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ |
| EVAC | Elimination of Violence Against Children | ការលុបបំបាត់អំពើហិង្សាលើកុមារ |
| ICTs | Information and Communication Technologies | បច្ចេកវិទ្យាទូរគមនាគមន៍និងព័ត៌មាន |
| LGBTIQ+ | Lesbian, Gay, Bisexual, Transgender, Intersex, Queer/Questioning | ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា |
| MoINF | Ministry of Information | ក្រសួងព័ត៌មាន |
| MoI | Ministry of Interior | ក្រសួងមហាផ្ទៃ |
| MoSVY | Ministry of Social Affairs Veteran and Youth Rehabilitation | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា |
| MoWA | Ministry of Women's Affairs | ក្រសួងកិច្ចការនារី |
| MoEYS | Ministry of Education Youth and Sport | ក្រសួងអប់រំ យុវជន និងកីឡា |
| MoCAR | Ministry of Cults and Religions | ក្រសួងធម្មការនិងសាសនា |
| MCFA | Ministry of Culture and Find Art | ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ |
| MoJ | Ministry of Justice | ក្រសួងយុត្តិធម៌ |
| MoH | Ministry of Health | ក្រសួងសុខាភិបាល |
| MoP | Ministry of Planning | ក្រសួងផែនការ |
| MPTC | Ministry of Post and Telecommunications | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ |
| MoLVT | Ministry of Labour and Vocational Training | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MPCCL | Municipal-Provincial Committee for Countering Child Laboure | គណៈកម្មការប្រឆាំងពលកម្មកុមារ រាជធានី ខេត្ត(គ.ព.រ.ខ.) |
| NCCL | National Committee for Countering Child Laboure | គណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ (គ.ជ.ព.) |
| NCCT | National Committee for Counter Trafficking | គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស |
| NSDP | National Strategic Development Plan | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |

| | | |
|---|---|---|
| ASEAN RPA on EVAC | ASEAN Regional Plan of Action on the Elimination of Violence Against Children | ផែនការសកម្មភាពរបស់អាស៊ានស្តីពីការលុបបំបាត់អំពើហិង្សាលើកុមារ |
| OCSE | Online Child Sexual Exploitation | ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ |
| SOGIESC | Sexual Orientation, Gender Identity, Gender Expression and Sex Characteristics | និន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ |
| SDGs | Sustainable Development Goals | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| UNIAP | The United Nations Inter-Agency Project on Human Trafficking | គម្រោងអន្តរទីភ្នាក់ងារសហប្រជាជាតិប្រឆាំងការជួញដូរមនុស្ស |
| UNICEF | United Nations International Children's Emergency Fund | មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ |
| WHO | World Health Organization | អង្គការសុខភាពពិភពលោក |
| WCCC | Women and Children's Consultative Committee | គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រីនិងកុមារ |

## ១- សារធាតុ

### ១.១- គោលនយោបាយ

#### ១.១.១- ក្របខ័ណ្ឌជាតិ

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាចាត់ទុកថា «**កុមារជាទំពាំងស្នងឫស្សី**» និង «**កុមារជាសសរទ្រូងសម្រាប់ប្រទេសជាតិ**» ដើម្បីផ្តល់កិច្ចការពារនិងលើកកម្ពស់សិទ្ធិកុមារ ជាពិសេសទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ រាជរដ្ឋាភិបាលបានដាក់ចេញនូវច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយជាច្រើនមានដូចខាងក្រោម៖

ក- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៤៨ ចែងថា «រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងនៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានភាពមានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច ឬកាមគុណលើកុមារ។ រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយណាដែលអាចធ្វើឱ្យខូចដល់ការអប់រំនិងការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាពឬសុខុមាលភាពរបស់កុមារ»។

ខ- ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ និងក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។

គ- ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥ មាត្រា១ចែងថា «ច្បាប់នេះមានគោលបំណងទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការពារជនរងគ្រោះ និងពង្រឹងវប្បធម៌អហិង្សា និងភាពសុខដុមរមនាក្នុងគ្រួសារក្នុងសង្គមនៅព្រះរាជាណាចក្រកម្ពុជា។ ច្បាប់នេះមានទិសដៅបង្កើតយន្តការនីត្យានុកូលដើម្បីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការពារជនរងគ្រោះ និងថែរក្សាសុខដុមរមនាក្នុងគ្រួសារ តាមទំនៀមទម្លាប់និងប្រពៃណីល្អរបស់ជាតិ ស្របតាមមាត្រា៤៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដោយបំពេញបន្ថែមលើបទដ្ឋានគតិយុត្តជាធរមាន»។ មាត្រា៣ចែងថា «អំពើហិង្សាក្នុងគ្រួសារទាមទារឱ្យមានការទប់ស្កាត់ទាន់ពេលវេលានិងប្រកបដោយប្រសិទ្ធភាព ហើយតម្រូវឱ្យចាត់វិធានការសមស្របបំផុត ដើម្បីការពារជនរងគ្រោះឬជនអាចនឹងរងគ្រោះ។ អំពើហិង្សា រួមមានការប៉ះពាល់ដល់ជីវិត ការប៉ះពាល់ដល់បូរណភាពរូបកាយ ការធ្វើទារុណកម្មឬការធ្វើអំពើឃោរឃៅ ការឈ្លានពានខាងផ្លូវភេទ»។ មាត្រា៦ចែងថា «អំពើទារុណកម្មឬអំពើឃោរឃៅ រួមមាន : ការធ្វើទុក្ខបុកម្នេញបង្កឱ្យមានការឈឺចុកចាប់ផ្លូវចិត្ត សតិអារម្មណ៍ បញ្ញាស្មារតីដល់រូបវន្តបុគ្គលក្នុងគ្រួសារ ការធ្វើឱ្យប៉ះទង្គិចលើផ្លូវចិត្ត និងលើរូបកាយ ដែលប្រព្រឹត្តហួសពីសីលធម៌និងច្បាប់កំណត់»។ មាត្រា៧ចែងថា «អំពើឈ្លានពានខាងផ្លូវភេទ រួមមាន : ការប្រើហិង្សាសេពសន្ថវៈ ការបៀតបៀនកេរខ្មាស ការធ្វើអាស្រូវភាស»។ មាត្រា៨ចែងថា «ត្រូវទប់ស្កាត់ផងដែរចំពោះអំពើគំរាមកំហែងក្នុងគោលបំណង ធ្វើឱ្យជនរងគ្រោះភ័យខ្លាច តក់ស្លុត និងអំពើប៉ះពាល់ដល់បុគ្គលភាព និងទ្រព្យសម្បត្តិនៃជនដែលរស់នៅក្រោមដំបូលផ្ទះនិងក្នុងបន្ទុកគ្រួសារតែមួយ។ មិនរាប់បញ្ចូលថាជាការប្រើហិង្សាឬសកម្មភាពហិង្សាក្នុងគ្រួសារទេ រាល់ការប្រៀនប្រដៅដោយផ្តល់ដំបូន្មាន ឬធ្វើការដាស់តឿនក្រើនរំលឹក ឬចាត់វិធានការនានាសមស្រប ដើម្បីឱ្យសហព័ទ្ធ ឬកូន ឬអ្នកនៅក្នុងបន្ទុកដើរក្នុងផ្លូវល្អតាមលក្ខណៈរស់នៅថ្លៃថ្នូរនៃទំនៀមទម្លាប់និងប្រពៃណីល្អរបស់ជាតិ ប្រសិនបើការ

ប្រៀនប្រដៅនិងការអប់រំនោះធ្វើឡើងប្រកបដោយព្រហ្មវិហារធម៌ និងស្របទៅតាមគោលការណ៍នៃអនុសញ្ញាស្តីពីសិទ្ធិមនុស្ស និងសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិ ដែលទទួលស្គាល់ដោយព្រះរាជាណាចក្រកម្ពុជា»។ មាត្រា៩ចែងថា «អាជ្ញាធរមានសមត្ថកិច្ចដែលនៅជិតបំផុត មានកាតព្វកិច្ចធ្វើអន្តរាគមន៍ជាបន្ទាន់ក្នុងករណីមានអំពើហិង្សាក្នុងគ្រួសារកើតឡើងឬបម្រុងនឹងកើតឡើង ដើម្បីទប់ស្កាត់និងការពារជនរងគ្រោះ។ ក្នុងអំឡុងពេលចូលធ្វើអន្តរាគមន៍ អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើកំណត់ហេតុឱ្យបានជាក់លាក់អំពីហេតុការណ៍នោះ រួចរាយការណ៍ជាបន្ទាន់ទៅព្រះរាជអាជ្ញាមានសមត្ថកិច្ច»។ មាត្រា១០ចែងថា «ក្នុងគោលដៅទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងការពារជនរងគ្រោះ មន្ត្រីនៃកិច្ចការនារីបម្រើការងារលើវិស័យដែលបញ្ញត្តដោយច្បាប់នេះ ត្រូវបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ និងអាចធ្វើជាដើមបណ្តឹងជួសមុខឱ្យជនរងគ្រោះស្របតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន»។ មាត្រា១១ចែងថា «ក្នុងករណីអវត្តមាននៃមន្ត្រីដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌រួចហើយនោះ មន្ត្រីសមត្ថកិច្ចដទៃទៀត រួមមានមន្ត្រីនគរបាល ភ្នាក់ងារនគរបាលកងរាជអាវុធហត្ថ អាជ្ញាធរមូលដ្ឋានឃុំ សង្កាត់ មន្ត្រីរបស់ក្រសួងកិច្ចការនារី រួមទាំងមេភូមិដែលបានធ្វើអន្តរាគមន៍ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងការពារជនរងគ្រោះ ត្រូវបានទទួលអំណាចពីច្បាប់នេះដើម្បីធ្វើកំណត់ហេតុជូនតុលាការ។ កំណត់ហេតុនេះមានតម្លៃស្មើគ្នា ដូចកំណត់ហេតុដែលបំពេញដោយមន្ត្រីនគរបាលយុត្តិធម៌»។ មាត្រា១៣ចែងថា «ដើម្បីទប់ស្កាត់អំពើហិង្សាដែលកំពុងតែកើតឬជឿជាក់ថានឹងកើតឡើង អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើអន្តរាគមន៍ជាបន្ទាន់»។

ឃ- ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨ ហាមឃាត់អំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទតាមរូបភាពផ្សេងៗ។

ង- ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ មាត្រា១៥ចែងថា «ការងារដោយបង្ខំឬកាតព្វកិច្ច ត្រូវហាមឃាត់ជាដាច់ខាត ដោយអនុលោមតាមអនុសញ្ញាលេខ២៩ ស្តីពីការងារដោយបង្ខំឬកាតព្វកិច្ច អនុម័តនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៣០ ដោយអង្គការអន្តរជាតិខាងការងារ ហើយព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័ននៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៦៩។ មាត្រានេះត្រូវអនុវត្តទៅលើបុគ្គលទាំងអស់ គិតទាំងអ្នកបម្រើក្នុងផ្ទះហើយនិងកម្មករ និយោជិតក្នុងសហគ្រាសកសិកម្មទាំងឡាយ»។ មាត្រា១៦ចែងថា «ការជួលមនុស្សឱ្យធ្វើការងារ ដើម្បីកាត់ជំពាក់ត្រូវហាមឃាត់»។ «ច្បាប់ស្តីពីការងារនិងច្បាប់ពាក់ព័ន្ធដទៃទៀត ហាមឃាត់មិនឱ្យមានការបៀតបៀនផ្លូវភេទនិងឥរិយាបថមិនសមរម្យនៅកន្លែងធ្វើការ»។ ព្រមទាំងប្រកាសចំនួន១៣ ពាក់ព័ន្ធនឹងពលកម្មកុមារ។

ច- ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦ មាត្រា១៤ កថាខណ្ឌទី២ នីតិវិធីទាក់ទងនឹងអនីតិជនអាយុក្រោម១៤(ដប់បួន)ឆ្នាំ ចែងថា «អនីតិជនមានអាយុក្រោម១៤(ដប់បួន)ឆ្នាំ ដែលជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើស ពុំអាចត្រូវបានគេឃាត់ខ្លួនឡើយ ហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រគល់អនីតិជននោះទៅឱ្យអ្នកតំណាងដែលច្បាប់បានកំណត់។ ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារនិងថែទាំ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរឬការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាពនិងស្ថានភាពសង្គមរបស់អនីតិជន។ មន្ទីរឬការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍អំពីការទទួលអនីតិជនពីមន្ត្រីនគរបាលយុត្តិធម៌ជូនទៅព្រះរាជអាជ្ញា

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារនិងថែទាំ នោះមន្ទីរឬការិយាល័យត្រូវចាត់ចែងការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ។ ក្នុងករណីដែលអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ។ គ្រប់អំពើដែលជាបទល្មើសទាំងអស់ដែលប្រព្រឹត្តដោយអនីតិជនអាយុក្រោម១៤(ដប់បួន)ឆ្នាំ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា»។ ក្នុងន័យនេះ មិនត្រូវប្រើអំពើហិង្សាចំពោះអនីតិជនដែលជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើស។

ឆ- យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១។

ជ- គោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥។

ឈ- គោលនយោបាយជាតិប្រជាជន ឆ្នាំ២០១៦-២០៣០។

ញ- គោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩-២០២៩។

ដ- គោលនយោបាយជាតិស្តីពីសុខភាពសិក្សា ឆ្នាំ២០១៩។

ឋ- គោលនយោបាយស្តីពីការអប់រំបរិយាបន្ន ឆ្នាំ២០១៨។

ឌ- គោលនយោបាយវត្តសង្គហកុមារ ឆ្នាំ២០២០។

ឍ- គោលនយោបាយជាតិស្តីពីគាំពារនិងអភិវឌ្ឍន៍កុមារតូច ឆ្នាំ២០១០។

ណ- គោលនយោបាយស្តីពីកិច្ចការពារកុមារនៅសាលារៀន ឆ្នាំ២០១៦។

ត- គោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ ឆ្នាំ២០២៤។

ថ- គោលនយោបាយ«ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព» ឆ្នាំ២០២១។

ទ- Cambodia PROTECT ជាយុទ្ធនាការគ្រួសាររឹងមាំ ដោយផ្តោតលើគោលដៅ ប្រព័ន្ធផ្សព្វផ្សាយចម្រុះ បច្ចេកវិទ្យាគមនាគមន៍ដែលមានការប្រាស្រ័យទាក់ទងគ្នា(ICTs) សកម្មភាពចូលរួមពីសហគមន៍និងការស្វែងរកការគាំទ្រ។

### ១.១.២- ក្របខ័ណ្ឌអន្តរជាតិ

ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើលិខិតុបករណ៍អន្តរជាតិនិងការចូលរួមសកម្មភាពមួយចំនួនដើម្បីការពារនិងលើកកម្ពស់សិទ្ធិកុមារ ក្នុងនោះរួមមាន៖

ក- អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ : សេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិកុមារ ដែលប្រកាសឡើងដោយសេចក្តីសម្រេចចិត្តលេខ1386(XIV)របស់មហាសន្និបាតអង្គការសហប្រជាជាតិ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩ ហើយដែលកម្ពុជាបានចុះហត្ថលេខាទទួលយកអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩២។ អនុសញ្ញាស្តីពីសិទ្ធិកុមារ គឺជាសន្ធិសញ្ញាអន្តរជាតិដែលមានចែងពីបទដ្ឋានអប្បបរមាជាសកល និងពីគោលការណ៍សីលធម៌សម្រាប់ការប្រព្រឹត្តលើកុមារនៅក្នុងសង្គម ស្របតាមគោលការណ៍១០យ៉ាង ក្នុងសេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិកុមារ និងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ មានសិទ្ធិសំខាន់ៗចំនួន៤គឺ សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានកិច្ចការពារ សិទ្ធិក្នុងការចូលរួម និងសិទ្ធិក្នុងការអភិវឌ្ឍ។

ខ- ពិធីសារបន្ថែមស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធនៅឆ្នាំ២០០៤ និងពិធីសារស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារនៅឆ្នាំ២០០២។

គ- អនុសញ្ញាអន្តរជាតិខាងការងារ លេខ២៩ ស្តីពីការងារដោយបង្ខំឬជាកាតព្វកិច្ច នៅឆ្នាំ១៩៦៩។

ឃ- អនុសញ្ញាអន្តរជាតិខាងការងារ លេខ១៣៨ ស្តីពីការកម្រិតអាយុអប្បបរមាសម្រាប់ការចូលធ្វើការងារនៅឆ្នាំ១៩៩៩។

ង- អនុសញ្ញាអន្តរជាតិខាងការងារ លេខ១៨២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុត នៃពលកម្មកុមារនៅឆ្នាំ២០០៥។

ច- កម្ពុជាបានចូលជាសមាជិកនៃប្រទេសភាពជាដៃគូសកល ដើម្បីលុបបំបាត់អំពើហិង្សាលើកុមារ នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ និងបានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍ WePROTECT នៅទីក្រុងអាប៊ុយដាប៊ីឆ្នាំ២០១៥ ពាក់ព័ន្ធនឹងសកម្មភាពទប់ស្កាត់ការរំលោភបំពាន និងកេងប្រវ័ញ្ចលើកុមារតាមប្រព័ន្ធអនឡាញ។

ឆ- គោលការណ៍ណែនាំអង្គការសហប្រជាជាតិសម្រាប់ការថែទាំជំនួសចំពោះកុមារនៅឆ្នាំ២០០៩។

ជ- គណៈកម្មាធិការសិទ្ធិកុមារបញ្ចប់ការសង្កេតលើរបាយការណ៍តាមការកំណត់គួបលើកទី៤និងទី៦របស់កម្ពុជា។

ឈ- របាយការណ៍ការពិនិត្យឡើងវិញជាសកល តាមកាលកំណត់ជុំទី៤ ឆ្នាំ២០២៤។

ញ- នៅក្នុងរបាយការណ៍បច្ចុប្បន្នត្រូវបានដាក់ជូនដោយអនុលោមតាមសេចក្តីសម្រេចរបស់មហាសន្និបាតរបស់អ.ស.ប. លេខ276/147 អ្នករាយការណ៍ពិសេសស្តីពីការលក់ ការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានផ្លូវភេទលើកុមារ ពិពណ៌នាអំពីសកម្មភាពដែលបានអនុវត្តទាក់ទងនឹងការចាកចេញពីអាណត្តិរបស់លោកស្រី ចាប់តាំងពីរបាយការណ៍មុនរបស់លោកស្រីទៅកាន់សភា( A/77/140 )។ លោកស្រីក៏បង្ហាញអំពីការសិក្សាតាមប្រធានបទស្តីពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារ ក្នុងបរិបទនៃការធ្វើដំណើរនិងទេសចរណ៍រួមទាំងការមើលឱ្យកាន់តែជិតដល់អំពីបាតុភូតនៃទេសចរណ៍ស្ម័គ្រចិត្ត។

បន្ថែមពីនេះ ព្រះរាជាណាចក្រកម្ពុជាក៏បានចូលរួមប្តេជ្ញាចិត្តនៅថ្នាក់តំបន់ ដើម្បីការពារនិងលើកកម្ពស់សិទ្ធិកុមារ ដែលការប្តេជ្ញាចិត្តសំខាន់ៗទាំងនោះរួមមាន៖

ក- សេចក្តីប្រកាសអាស៊ានស្តីពីការប្រឆាំងនឹងអំពើជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ ឆ្នាំ២០០៤។

ខ- សេចក្តីប្រកាសអាស៊ានស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រីនិងកុមារ ឆ្នាំ២០១៣។

គ- អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងនឹងអំពើជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ ឆ្នាំ២០១៥។

ឃ- ផែនការសកម្មភាពប្រចាំតំបន់អាស៊ានស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រីនិងកុមារ ឆ្នាំ២០១៧។

ង- ការយល់ស្របរបស់អាស៊ានលើការលើកកម្ពស់និងកិច្ចការពាររបស់ពលករទេសន្តរប្រវេសន៍។

## ១.២- ស្ថានភាពអំពើហិង្សាលើកុមារ

យោងតាមជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ កម្ពុជាមានប្រជាជនសរុបចំនួន ១៥,៦លាននាក់ ហើយក្នុងនោះចំនួន៥,៤លាននាក់( ៣៤,៨% ) គឺជាកុមារ( អាយុ០-១៧ឆ្នាំ )។ ក្នុងចំណោមកុមារទាំងនោះ មានកុមារចំនួន១,៤លាននាក់ មានអាយុចន្លោះពី០-៤ឆ្នាំ កុមារចំនួន១,៥លាននាក់ មានអាយុចន្លោះពី៥-៩ឆ្នាំ និងកុមារចំនួន២,៥លាននាក់ ស្ថិតក្នុងវ័យជំទង់ដែលមានអាយុចន្លោះពី១០-១៧ឆ្នាំ។ មានកុមារពិការចំនួន១,២% ស្មើ១៦៩ ២២៥នាក់ សម្រាប់ក្រុមកុមារអាយុ៥-១៤ឆ្នាំ ក្នុងចំណោមប្រជាជនមានអាយុពី

៥ឆ្នាំឡើង មានចំនួន១៤ ១០២ ០៥២នាក់។ យោងតាមលទ្ធផលចុងក្រោយអង្កេតចន្លោះជំរឿនឆ្នាំ២០២៤ បង្ហាញថាប្រជាជនកម្ពុជាសរុបមានចំនួន១៧ ២៨០ ៥៤៣នាក់។

កុមារទទួលរងនិងជួបប្រទះអំពើហិង្សា ការរំលោភបំពាន ការកេងប្រវ័ញ្ច និងការមិនអើពើ ក្នុងកម្រិតមួយគួរឱ្យកត់សម្គាល់។ បទពិសោធរបស់កុមារក្នុងការទទួលរងអំពើហិង្សា កើតមាននៅក្នុងគ្រប់ស្រទាប់វណ្ណៈទាំងអស់នៅក្នុងសង្គម ទាំងអ្នកមាននិងអ្នកក្រ ប៉ុន្តែនិន្នាការនៃការប្រឈមទៅនឹងអំពើហិង្សារបស់ពួកគេកាន់តែមានភាពធ្ងន់ធ្ងរ ដោយសារបញ្ហាវិសមភាពយេនឌ័រ ការមិនសូវទទួលបានការយកចិត្តទុកដាក់ចំពោះជនក្រីក្រនៅតំបន់ទីក្រុងនិងជនបទ ភាពបែកខ្ញែកនៃគ្រួសារដោយសារការចំណាកស្រុកស្វែងរកការងារធ្វើឥរិយាបថអវិជ្ជមាន និងការរើសអើងចំពោះកុមារមានពិការភាព។ កុមារទទួលរងនិងជួបប្រទះអំពើហិង្សានៅកន្លែងសាធារណៈ កន្លែងឯកជននៅផ្ទះ សាលារៀន សហគមន៍ និងកន្លែងសាសនា ព្រមទាំងតាមប្រព័ន្ធអ៊ីនធឺណិត។ អំពើហិង្សាលើកុមារកើតឡើងជាញឹកញាប់ ដោយសារមនុស្សពេញវ័យនិងកុមារដែលមានវ័យច្រើនជាងដែលពួកគាត់មានតួនាទីជាអ្នកផ្ដល់ការថែទាំ ក្នុងនោះរួមមានឪពុកម្ដាយ បងប្អូនបង្កើត និងសាច់ញាតិ គ្រូបង្រៀន មិត្តភក្តិនៅឯសាលារៀន សមាជិកសហគមន៍ មេដឹកនាំសាសនា និងអ្នកផ្ដល់ការថែទាំនៅតាមមណ្ឌលថែទាំកុមារ។ អំពើហិង្សាលើកុមារមានច្រើនទម្រង់ និងមានការជំរុញពីកត្តាជាច្រើននៅកម្រិតគ្រួសារសហគមន៍និងសង្គម ដូច្នេះតម្រូវឱ្យមានដំណោះស្រាយដោយប្រើប្រាស់នូវអន្តរាគមន៍ជាច្រើនបែបដែរ។

### ១.២.១- អំពើហិង្សាលើកុមារ

ការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា CDHS ២០២១-២២ បានបង្ហាញថា ជារួមពីរភាគបី(៦៦%) នៃកុមារកម្ពុជាអាយុពី១-១៤ឆ្នាំ ធ្លាប់ទទួលរងនូវវិធីសាស្ត្រប្រៀនប្រដៅ ដោយការដាក់ពិន័យពីមនុស្សពេញវ័យក្នុងគ្រួសារពួកគេ។ មានតែ២៣% នៃកុមារអាយុពី១-១៤ ឆ្នាំប៉ុណ្ណោះ ដែលមិនធ្លាប់ទទួលរងនូវវិធីសាស្ត្រប្រៀនប្រដៅ ដោយការដាក់ពិន័យពីមនុស្សពេញវ័យក្នុងគ្រួសារ។ ស្ទើរតែបីនាក់ក្នុងចំណោមប្រាំនាក់(៥៩ %) នៃកុមារធ្លាប់ទទួលរងនូវការដាក់ពិន័យលើផ្លូវចិត្ត ខណៈ៤៣% ទទួលរងការដាក់ពិន័យលើរាងកាយ និង៥% ធ្លាប់ទទួលរងនូវការដាក់ពិន័យរាងកាយធ្ងន់ធ្ងរ ដូចជាការវាយ ឬទះលើមុខ ក្បាល។[៩]

យោងតាមរបាយការណ៍វិភាគស៊ីជម្រៅទិន្នន័យការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជាCDHS ២០២១-២២ «អំពើហិង្សាក្នុងគ្រួសារ» បានរកឃើញថាមានស្ត្រីច្រើនជាង២១% នៃស្ត្រីកម្ពុជាធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយ លើផ្លូវភេទ ឬលើផ្លូវចិត្ត ក្នុងជីវិតដែលបង្កឡើងដោយដៃគូស្និទ្ធស្នាលរបស់ពួកគេ។ ប៉ុន្តែវាបង្ហាញពីឧត្តមភាពនៃការប្រៀបធៀបជាមួយការអង្កេតមុនៗ។ ភាគរយនៃស្ត្រីដែលស្ថិតក្នុងក្រុមអាយុ១៥-៤៩ឆ្នាំដែលធ្លាប់បានហើយរងនូវអំពើហិង្សាលើរាងកាយលើផ្លូវភេទ លើផ្លូវចិត្ត ឬលើសេដ្ឋកិច្ច ក្នុងជីវិតដែលបង្កឡើងដោយដៃគូស្និទ្ធស្នាលឬប្ដីរបស់ពួកគេ បានថយចុះពី២៩% ឆ្នាំ២០១៤ មក២១% ក្នុងឆ្នាំ២០២១។ នៅក្នុងឆ្នាំ ២០២១-២២ មានស្ត្រីប្រហែលមួយភាគបី(៣៧% ក្នុងឆ្នាំ២០២១ បើប្រៀបធៀបជាឆ្នាំ២០១៤ មាន ៥០%) និងមានបុរសប្រហែល(១៦% ក្នុងឆ្នាំ២០២១-២២ បើប្រៀបធៀបជាឆ្នាំ២០១៤ មាន២៦%) ពីក្រុមអាយុ១៥-៤៩ឆ្នាំបានយល់ស្របថាប្ដីមានភាពត្រឹមត្រូវក្នុងការវាយប្រពន្ធរបស់គាត់នៅក្រោមកាលៈទេសៈជាក់លាក់មួយឬច្រើន។ **ស្ត្រីវ័យក្មេងឬក្មេងស្រីនិងស្ត្រីនៅតំបន់ទីប្រជុំជនទំនងជារងនូវអំពើហិង្សាតិចជាងស្ត្រីវ័យចំណាស់និងស្ត្រីនៅតំបន់ជនបទ ដោយមានការប្រែប្រួលពី៣៣% ទល់នឹង៤៥%និង២៧%ទល់នឹង**

---

[៩] ការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជាCDHS២០២១-២២ នៅទំព័រ២៩២។ សំណាកគំរូត្រូវបានជ្រើសរើសស្មើគ្នារវាងក្មេងប្រុសនិងក្មេងស្រី (៥០%) ដូចនេះទិន្នន័យដែលរកឃើញមានក្មេងស្រីពាក់កណ្ដាល(១/២)។

**៤៥% តាមលំដាប់លេខរៀងគ្នា។ បុរសវ័យក្មេងឬក្មេងប្រុសមានការរងអំពើហិង្សាប្រហាក់ប្រហែលនឹងបុរសវ័យចំណាស់(១៧%ទល់នឹង២១%) ប៉ុន្តែបុរសនៅតំបន់ទីប្រជុំជនទំនងជារងនូវអំពើហិង្សាតិចជាង បើប្រៀបធៀបទៅនឹងតំបន់ទីជនបទ(១២% ទល់នឹង២០%)។** អំពើហិង្សាលើរាងកាយនិងផ្លូវភេទដែលបង្កឡើងដោយដៃគូស្និទ្ធស្នាលមានភាពត្រួតស៊ីគ្នាកម្រិតខ្ពស់។ ភាគច្រើននៃស្ត្រីដែលធ្លាប់រងអំពើហិង្សាផ្លូវភេទពីដៃគូស្និទ្ធស្នាលក៏ធ្លាប់ទទួលរងអំពើហិង្សាទាំងលើរាងកាយនិងលើផ្លូវភេទពីដៃគូស្និទ្ធស្នាលផងដែរ។"[២]

## ១.២.២- អាពាហ៍ពិពាហ៍នៅវ័យក្មេង

ការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា CDHS ២០២១-២២ បានរកឃើញថា ស្ត្រីរៀបអាពាហ៍ពិពាហ៍មុនអាយុ១៥ឆ្នាំ មាន១,៨% ហើយស្ត្រីរៀបអាពាហ៍ពិពាហ៍មុនអាយុ១៨ឆ្នាំ មាន១៩% ចំណែកបុរសរៀបអាពាហ៍ពិពាហ៍មុនអាយុ១៨ឆ្នាំ មាន៦%។ របាយការណ៍ការសិក្សាស្រាវជ្រាវស្តីពីអាពាហ៍ពិពាហ៍នៅវ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំនិងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេងឆ្នាំ២០២៤ បានរកឃើញថា មានស្ត្រី១៣,៩៣% រៀបការនៅអាយុចន្លោះ១៥-១៨ឆ្នាំ មានស្ត្រី១៤,៤៤% រៀបការមុនអាយុ១៨ឆ្នាំ ចំណែកបុរសវិញមានតែ ០,២២% ប៉ុណ្ណោះដែលរៀបការមុនអាយុ១៥ឆ្នាំ មានបុរស២,៩៦% រៀបការនៅអាយុពី១៥-១៨ឆ្នាំ។ ដោយឡែកនៅលើពិភពលោក មានក្មេងស្រីនិងស្ត្រីប្រមាណ៦៤០លាននាក់បានរៀបការក្នុងវ័យកុមារ នៅក្នុងនោះ នៅអាស៊ីអាគ្នេយ៍មាន២៩០លាននាក់(៤៥%) សាធារណរដ្ឋអាហ្វ្រិកមាន១២៧លាននាក់(២០%) អាស៊ីខាងកើតនិងប៉ាស៊ីហ្វិកមាន៩៥លាននាក់(១៥%) អាម៉េរិកឡាទីននិងការ៉ាប៊ីនមាន៥៨លាននាក់(៩%) មជ្ឈិមបូព៌ានិងអាហ្វ្រិកខាងជើងមាន៣៧លាននាក់(៦%) អឺរ៉ុបខាងកើតនិងអាស៊ីកណ្ដាលមាន២០លាននាក់(៣%) និងតំបន់ផ្សេងៗទៀតមាន១៣លាននាក់(២%)។

ការរៀបអាពាហ៍ពិពាហ៍វ័យក្មេង អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរស់នៅជាប្តីប្រពន្ធនៅវ័យក្មេង មានផលប៉ះពាល់ទៅលើកត្តាជាច្រើន រួមមានការមានផ្ទៃពោះនៅវ័យក្មេង ផលវិបាកផ្នែកសុខភាព ភាពក្រីក្រ និងចំណូលទាប ការកើតមានអំពើហិង្សាក្នុងគ្រួសារ ការរំលោភលើសិទ្ធិនិងសេរីភាពរបស់ក្មេងស្រី ការទទួលបានការអប់រំ ការផ្តាច់ទំនាក់ទំនងពីសង្គម ការចូលរួមក្នុងនាមជាពលរដ្ឋ និងការចូលរួមការងារសង្គម។ អាពាហ៍ពិពាហ៍នៅវ័យក្មេង បង្កើនភាពងាយរងគ្រោះលើសុខភាពផ្លូវភេទនិងសុខភាពបន្តពូជ ការរំលូតកូន និងបញ្ហាសម្រាលកូន ហើយបន្តធ្វើឱ្យសេដ្ឋកិច្ចនៅតែមានបញ្ហាប្រឈម តាមរយៈការកាត់បន្ថយការវិនិយោគលើការអប់រំនិងសុខភាពកុមារីវ័យក្មេង បន្តធ្វើឱ្យផលិតភាពនៅមានកម្រិតទាបនិងបន្តវដ្តនៃភាពក្រីក្រ។ ការមានផ្ទៃពោះនៅវ័យជំទង់ធ្វើឱ្យមានភាពឯកោក្នុងសង្គមនិងបញ្ហាប្រឈមក្នុងការចិញ្ចឹមកូន ដែលបណ្តាលឱ្យមានការកាត់បន្ថយការចូលរួមក្នុងកិច្ចការសហគមន៍និងវេទិកាធ្វើសេចក្តីសម្រេចចិត្ត។

## ១.២.៣- ពលកម្មកុមារ

ផែនការសកម្មភាពជាតិស្តីពីការកាត់បន្ថយពលកម្មកុមារនិងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ(២០១៦-២០២៥) បានកំណត់ថា ពលកម្មកុមារគឺជាការងារទាំងឡាយណា ទោះបីទទួលបានកម្រៃ ឬមិនបានទទួលកម្រៃក្តី ដែលប៉ះពាល់ដល់ការរីកលូតលាស់ផ្នែកចិត្តគំនិត ផ្នែករាងកាយ ផ្នែកសង្គម និងផ្នែកសីលធម៌របស់កុមារអាយុក្រោម១៨ឆ្នាំ ជាពិសេសរាំងស្ទះដល់ការអប់រំរបស់ពួកគេ។ ដោយឡែកការងារកុមារ គឺជាការងារទាំងឡាយណាដែលជួយអប់រំនិងបណ្តុះបណ្តាលដល់កុមារឱ្យចេះធ្វើការនៅពេលអនាគត ដែលជាផ្នែកមួយនៃវិជ្ជាជីវៈគ្រួសារ មិនចាត់ទុកជាពលកម្មកុមារទេ។

---

[២] របាយការណ៍វិភាគស៊ីជម្រៅទិន្នន័យការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជាCDHS ២០២១-២២ «អំពើហិង្សាក្នុងគ្រួសារ» នៅទំព័រ៤ ។

ពលកម្មកុមារ គឺជាបាតុភូតសង្គមដ៏ស្មុគស្មាញមួយដែលមានទំនាក់ទំនងទៅនឹងវិជ្ជភាពសេដ្ឋកិច្ច សង្គមកម្ពុជានិងឥរិយាបថសហគមន៍។ ភាពក្រីក្រនិងការយល់ដឹងរបស់សហគមន៍នៅមានកម្រិតទាប ជាមូលហេតុចម្បងដែលនាំឱ្យមានពលកម្មកុមារ។ ក្រុមគ្រួសារក្រីក្រដែលខ្វះធនធាន ខ្វះជំនាញ មានការអប់រំទាប និងមានប្រាក់ចំណូលតិច ជាមុខសញ្ញាក្នុងការប្រើប្រាស់ពលកម្មកុមារ ដើម្បីទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេ។ ដោយសារមូលហេតុនេះ គេសង្កេតឃើញពលកម្មកុមារ មានគ្របដណ្តប់នៅតាមតំបន់ភូមិសាស្ត្រ មុខព្រួញសេដ្ឋកិច្ច និងទម្រង់ផ្សេងៗនៃវិស័យការងារ។

យោងតាមលទ្ធផលនៃការអង្កេតកម្លាំងពលកម្មនិងពលកម្មកុមារនៅឆ្នាំ២០១៣ និងការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០២៣ របស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ បានបង្ហាញថាស្ថានភាពពលកម្មកុមារនៅប្រទេសកម្ពុជា មានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ ដែលឆ្លុះបញ្ចាំងពីវឌ្ឍនភាពនិងសមិទ្ធផលដ៏ធំធេងដែលរាជរដ្ឋាភិបាលកម្ពុជាសម្រេចបានក្នុងរយៈពេលមួយទសវត្សកន្លងមកនេះ។ ជាក់ស្តែង កុមារចូលរួមក្នុងការងារអាយុចន្លោះពី៥-១៧ឆ្នាំ បានថយចុះពីចំនួន២៣,៦% នៅឆ្នាំ២០១២ មកត្រឹម១៧%នៅឆ្នាំ២០២១ និង ១១,៩%នៅឆ្នាំ២០២៣។ នៅក្នុងចំណោមកុមារចូលរួមក្នុងការងារនៅឆ្នាំ២០២៣ កុមារធ្វើការងារផងសិក្សាផងមានចំនួន៣០,៣% និងកុមារធ្វើការងារមិនបានសិក្សាមានចំនួន៦៩,៧%។ តាមតួលេខនេះ កុមារដែលធ្វើការនិងមិនបានសិក្សា គឺជាក្តីបារម្ភនៃភាពងាយរងគ្រោះពលកម្មកុមារ ដែលត្រូវការអនុវត្តកិច្ចអន្តរាគមន៍ស្នូល និងវិធានការអធិការកិច្ចការងារ ដើម្បីបង្ការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ។ ជាមួយនឹងកិច្ចអន្តរាគមន៍ស្នូល និងវិធានការអធិការកិច្ចការងារ សេវានៃកិច្ចអន្តរាគមន៍ ដើម្បីទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ គឺជាកិច្ចការអាទិភាពមួយ។

### ១.២.៤- ការជួញដូរកុមារ

ការជួញដូរកុមារ គឺជាបញ្ហាប្រឈមចំពោះសុខុមាលភាពកុមារ និងជីវភាពរស់នៅរបស់ក្រុមគ្រួសារកុមារ ដែលរដ្ឋជាសមាជិក ត្រូវអនុលោមតាមអនុសញ្ញាអន្តរជាតិនានា ដែលពាក់ព័ន្ធនឹងការទប់ស្កាត់និងហាមឃាត់ការជួញដូរកុមារ និងការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ។ កុមារធ្វើទេសន្តរប្រវេសន៍ការងារ ជាមួយក្រុមគ្រួសារ ត្រូវហាមឃាត់ដាច់ខាត និងធានាកិច្ចសហការជាមួយប្រទេសក្នុងតំបន់ ដើម្បីធ្វើមាតុភូមិនិវត្តន៍កុមារឱ្យមានសុវត្ថិភាព និងធានាបាននូវការគាំពារ សុខុមាលភាព និងការអភិវឌ្ឍរបស់កុមារ។

### ១.២.៥- អំពើកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអ៊ីនធឺណិត

ការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ(OCSE) សំដៅទៅលើការប្រើប្រាស់អ៊ីនធឺណិតឬបច្ចេកវិទ្យាឌីជីថល ជាមធ្យោបាយដើម្បីប្រព្រឹត្តបទល្មើសធ្វើអាជីវកម្មផ្លូវភេទឬរំលោភបំពានផ្លូវភេទកុមារ ដែលកើតឡើងនៅពេលកុមារស្ថិតក្នុងស្ថានភាពប្រើប្រាស់ការទំនាក់ទំនងគ្នាតាមប្រព័ន្ធអនឡាញ មានការប្រើប្រាស់រូបភាព សម្ភារៈរំលោភបំពានផ្លូវភេទកុមារ(CSAM) ការលួងលោមតាមប្រព័ន្ធអនឡាញក្នុងគោលបំណងផ្លូវភេទ ការផ្ញើសារបែបរំលោភបំពានផ្លូវភេទ(Sexting) ការគំរាមទាក់ទងនឹងផ្លូវភេទ(Sextortion) និងការផ្សាយផ្ទាល់ការរំលោភបំពានផ្លូវភេទកុមារ។[៣] ជាសកល ការប្រើប្រាស់សេវាអ៊ីនធឺណិតតាមរយៈកុំព្យូទ័រ ឧបករណ៍អេឡិចត្រូនិក និងទូរសព្ទឆ្លាត កំពុងកើនឡើងយ៉ាងឆាប់រហ័សនៅស្ទើរគ្រប់ទីកន្លែង រួមទាំងក្នុងសហគមន៍ក្រីក្រនិងងាយរងគ្រោះ។

ការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ បានក្លាយជាបញ្ហាសកលនិងនៅក្នុងប្រទេសកម្ពុជា ហើយវាក៏បានក្លាយជាក្តីបារម្ភថ្មីមួយទៀត ដែលទាមទារឱ្យភាគីពាក់ព័ន្ធទាំងសាធារណជន

[៣] WePROTECT. (2016).

អាណាព្យាបាល អង្គការសង្គមស៊ីវិល មន្ត្រីអនុវត្តច្បាប់ ក្រុមហ៊ុនបច្ចេកវិទ្យា និងរដ្ឋាភិបាល ចាំបាច់ធ្វើការរួមគ្នាដើម្បីបង្ការទប់ស្កាត់ និងការពារកុមារពីគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរទាំងនេះ។ ការតភ្ជាប់អ៊ីនធឺណិតនៅកម្ពុជាបានកើនឡើងជាលំដាប់ ហើយមនុស្សកាន់តែច្រើនឡើងៗ រួមទាំងកុមារមានលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យាឌីជីថលយ៉ាងសម្បូរបែបមិនធ្លាប់មានពីមុន។ ការសិក្សាស្រាវជ្រាវសកលស្ដីពីការបញ្ឈប់គ្រោះថ្នាក់នៅកម្ពុជា ដែលបានចេញផ្សាយថ្មីៗនេះបានបង្ហាញថា កុមារជាង៨០% ដែលមានអាយុចន្លោះពី១២ឆ្នាំ ទៅ១៧ឆ្នាំ បានកំពុងប្រើប្រាស់និងភ្ជាប់អ៊ីនធឺណិត។ ខណៈពេលដែលកុមារនិងកុមារវ័យជំទង់ ចំណាយពេលវេលាជាច្រើននៅលើអ៊ីនធឺណិត ពួកគេភាគច្រើនមិនបានដឹងពីហានិភ័យនិងគ្រោះថ្នាក់នៃការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញនោះទេ។ ជាមួយនឹងការប្រើប្រាស់បច្ចេកវិទ្យា ល្បិចកលរបស់ជនល្មើសនិងរូបភាពនៃការរំលោភបំពានផ្លូវភេទកុមារកាន់តែស្មុគស្មាញនិងអាក្រក់ទៅៗ ដែលទាមទារឱ្យចាត់វិធានការដោះស្រាយរួមគ្នាបន្ទាន់។

កុមាររងគ្រោះពីការរំលោភបំពាននិងកេងប្រវ័ញ្ចផ្លូវភេទ បានទទួលរងនូវផលប៉ះពាល់ធ្ងន់ធ្ងរទាំងរាងកាយនិងផ្លូវចិត្តនិងអាចអូសបន្លាយពេញមួយជីវិតរបស់ពួកគេ។ កុមាររងគ្រោះភាគច្រើនមានអារម្មណ៍អាម៉ាសពិបាកក្នុងការទុកចិត្តអ្នកដទៃអស់សង្ឃឹម បាក់ទឹកចិត្ត ខកចិត្ត ស្អប់ខ្ពើមខ្លួនឯង ឆាប់ភ័យខ្លាច និងមានតម្រូវការដោះស្រាយបញ្ហាបន្ទាន់ៗ។ ទំហំផលប៉ះពាល់នៃដំណើរការស្តារនីតិសម្បទារបស់កុមាររងគ្រោះ ត្រូវការរយៈពេលយូរ និងការគាំទ្រគ្រប់គ្រាន់ពីសំណាក់ឪពុកម្ដាយអាណាព្យាបាល អ្នកជំនាញ និងសហគមន៍ទាំងមូល។

### ១.២.៦- កុមារដែលមានការប្រឈមខ្ពស់ទៅនឹងអំពើហិង្សា

ជាទូទៅកុមារគ្រប់រូបងាយរងគ្រោះខ្លាំងជាងមនុស្សពេញវ័យ ដោយសារតែពួកគេមានវ័យក្មេងជាងមានបទពិសោធជីវិតតិចតួច មានទំហំរូបរាងកាយតូចជាង ភាពចាស់ទុំនិងមានមធ្យោបាយតិចជាងមនុស្សពេញវ័យ។ ទោះបីជាដូច្នេះក្ដី កុមារមួយចំនួនកាន់តែងាយរងគ្រោះជាងកុមារដទៃទៀតនិងមានការប្រឈមខ្ពស់ជាងទៅនឹងអំពើហិង្សា ដោយសារតែលក្ខណសម្បត្តិបុគ្គលឬដោយសារតែជាសមាជិកនៃក្រុមដែលងាយរងគ្រោះ និងកត្តាហានិភ័យផ្សេងៗទៀតដែលបណ្ដាលឱ្យកុមាររងនូវអំពើហិង្សា។

## ១.៣- លទ្ធផលសម្រេចបាន

រាជរដ្ឋាភិបាលដោយសហការជាមួយដៃគូអភិវឌ្ឍនិងអង្គការសង្គមស៊ីវិល បានសម្រេចនូវសមិទ្ធផលជាច្រើននៃការអនុវត្តផែនការសកម្មភាពដើម្បីទប់ស្កាត់និងឆ្លើយតបអំពើហិង្សាលើកុមារ ដូចជា(១)ការបង្កើតនូវគោលនយោបាយជាតិស្ដីពីប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩-២០២៩ នីតិវិធីប្រតិបត្តិកិច្ចការពារកុមារ និងសេចក្ដីព្រាងច្បាប់ស្ដីពីកិច្ចការពារកុមារ និងលិខិតបទដ្ឋានគតិយុត្តជាច្រើន (២)រៀបចំឯកសារបណ្តុះបណ្តាលនិងផ្សព្វផ្សាយអំពីសុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ ទៅដល់មន្ត្រីអនុវត្តច្បាប់ អាជ្ញាធរ សហគមន៍ ឪពុកម្ដាយរួមទាំងកុមារនិងយុវជន (៣)ការដាក់បញ្ចូលប្រធានបទស្ដីពីការឆ្លើយតបការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ ទៅក្នុងកម្មវិធីបណ្ដុះបណ្ដាលរបស់បណ្ឌិត្យសភានគរបាលកម្ពុជា និងទៅក្នុងកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា (៤)ការពង្រឹងនូវការឆ្លើយតប ការផ្ដល់សេវា ការគ្រប់គ្រងករណីបញ្ហារបស់កុមារ និងការបង្កើនចំណេះដឹងដល់កម្លាំងសេវាសង្គម និងអ្នកផ្ដល់សេវាដទៃទៀត (៥)ចាត់វិធានការទៅលើបញ្ហាកិច្ចការពារកុមារផ្ដល់យុត្តិធម៌ដល់កុមារ ផ្ដល់សេវាសុខាភិបាល និងផ្លូវចិត្តដល់កុមាររងគ្រោះពីអំពើរំលោភបំពានផ្លូវភេទ និងកុមាររងគ្រោះទម្រង់ផ្សេងៗ និង(៦)ការដាក់ឱ្យដំណើរការប្រព័ន្ធរាយការណ៍បន្ទាន់តាមអ៊ីនធឺណិតនៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន។

យោងតាមរបាយការណ៍វាយតម្លៃផែនការសកម្មភាពដើម្បីទប់ស្កាត់និងឆ្លើយតបអំពើហិង្សាលើកុមារ ឆ្នាំ២០១៧-២០២១[៦] បានរកឃើញថា ការអនុវត្ត(យុទ្ធសាស្ត្រទី១) ការសម្របសម្រួលនិងកិច្ចសហប្រតិបត្តិការ មានលក្ខណៈវិជ្ជមានមធ្យម(កម្រិត៥ លើមាត្រាដ្ឋាន៦ពិន្ទុ) និង(យុទ្ធសាស្ត្រទី៥) ការពិនិត្យតាមដាននិងវាយតម្លៃមានលក្ខណៈអវិជ្ជមានតិចតួច(កម្រិត៣ លើមាត្រាដ្ឋាន៦ពិន្ទុ) (យុទ្ធសាស្ត្រទី៤) ការបង្កើតនិងការធ្វើវិសោធនកម្មច្បាប់និងការអនុវត្តគោលនយោបាយ មានលក្ខណៈវិជ្ជមានតិចតួច(កម្រិត៤ លើមាត្រាដ្ឋាន៦ពិន្ទុ) លើការអនុវត្តគោលនយោបាយ ចំណែកការធ្វើវិសោធនកម្មច្បាប់មានលក្ខណៈអវិជ្ជមានតិចតួច(កម្រិត៣ លើមាត្រាដ្ឋាន៦ពិន្ទុ) (យុទ្ធសាស្ត្រទី២) ការទប់ស្កាត់បឋម និង(យុទ្ធសាស្ត្រទី៣) សេវាឆ្លើយតបជាពហុវិស័យចំពោះកិច្ចការពារកុមារមានលក្ខណៈវិជ្ជមានមធ្យម(កម្រិត៥ លើមាត្រាដ្ឋាន៦ពិន្ទុ)។[៧] ការវាយតម្លៃនេះផ្តោតលើភាពពាក់ព័ន្ធ ប្រសិទ្ធភាព ភាពជាប់ទាក់ទងគ្នា ប្រសិទ្ធផល ផលប៉ះពាល់ និរន្តរភាព និងបញ្ហាប្រទាក់ក្រឡាគ្នានៃផែនការ និងបានផ្តល់អនុសាសន៍ចំនួន១១ចំណុច រួមទាំងការរៀបចំផែនការសកម្មភាពថ្មីផងដែរ។

## ១.៤- ចលនាលុបបំបាត់អំពើហិង្សាលើកុមារ

### ១.៤.១- ចលនាសកលដើម្បីបញ្ចប់អំពើហិង្សាលើកុមារ

ការឆ្លើយតបរបស់ប្រទេសកម្ពុជា គឺជាផ្នែកមួយនៃចលនាសកលដើម្បីបញ្ចប់អំពើហិង្សាលើកុមារ។ របាយការណ៍សិក្សាស្រាវជ្រាវឯករាជ្យរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ស្តីពីអំពើហិង្សាលើកុមារ[៨] «ការសិក្សាស្រាវជ្រាវរបស់អង្គការសហប្រជាជាតិស្តីពីអំពើហិង្សាលើកុមារ» បានផ្តល់ការសិក្សាស្រាវជ្រាវកម្រិតសកលដំបូងបង្អស់ស្តីពីអំពើហិង្សាលើកុមារ។ ការសិក្សាស្រាវជ្រាវនេះបានកត់សម្គាល់ថា អំពើហិង្សាលើកុមារមានទម្រង់មួយចំនួន ក្នុងនោះរួមមានអំពើហិង្សាផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទ ព្រមទាំងការមិនអើពើផងដែរ។ ការសិក្សាបានរាយការណ៍ឱ្យដឹងផងដែរថា អំពើហិង្សាលើកុមារកើតឡើងនៅតាមកន្លែងមួយចំនួន ដូចជានៅតាមផ្ទះ សហគមន៍ សាលារៀន កន្លែងការងារ កន្លែងកម្សាន្ត រាប់បញ្ចូលទាំងក្លឹបកីឡា ក្លឹបយុវជន កន្លែងថែទាំកុមារ កន្លែងឃុំខ្លួន កន្លែងសាសនា និងក្នុងអំឡុងពេលអនុវត្តច្បាប់ និងនីតិវិធីតុលាការ។ ការសិក្សាស្រាវជ្រាវបានគូសបញ្ជាក់អំពីផលវិបាកជាច្រើននៃអំពើហិង្សាកាលពីកុមារភាព ក្នុងនោះរួមមានការបុះអន់ថយនៃការអភិវឌ្ឍផ្នែកសង្គម ស្មារតីនិងសតិបញ្ញាពេញមួយជីវិត ព្រមទាំងមានទំនាក់ទំនងកាន់តែខ្ពស់ទៅនឹងបញ្ហាសុខភាព និងសុខភាពផ្លូវចិត្ត អំពើហិង្សាពីដៃគូស្និទ្ធស្នាល និងការប៉ុនប៉ងធ្វើអត្តឃាត។ ការសិក្សាស្រាវជ្រាវនេះ បានផ្តល់អនុសាសន៍ថា «រដ្ឋទាំងអស់ត្រូវអភិវឌ្ឍក្របខ័ណ្ឌពហុវិស័យមួយដែលមានលក្ខណៈជាប្រព័ន្ធ ដើម្បីឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ដែលបានធ្វើសមាហរណកម្មទៅក្នុងដំណើរការរៀបចំផែនការសកម្មភាពជាតិ»[៩]។

### ១.៤.២- គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព

ប្រទេសកម្ពុជាបានប្រកាន់យករបៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។ ការលុបបំបាត់ភាពក្រីក្រគ្រប់ទម្រង់និងគ្រប់ទំហំ គឺជាចំណុចស្នូលនៃរបៀបវារៈឆ្នាំ២០៣០ ដែលត្រូវបានអនុម័តក្នុងខែកញ្ញា ឆ្នាំ២០១៥ ដោយមេដឹកនាំពិភពលោកចំនួន១៩៣ នៅក្នុងកិច្ចប្រជុំកំពូលនៃការអភិវឌ្ឍប្រកប

[៦] របាយការណ៍វាយតម្លៃផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបអំពើហិង្សាលើកុមារឆ្នាំ២០១៧-២០២១ ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០២២។

[៧] កម្រិតពិន្ទុនៃការវាយតម្លៃ ១ អវិជ្ជមានខ្លាំង ២ អវិជ្ជមានមធ្យម ៣ អវិជ្ជមានតិចតួច ៤ វិជ្ជមានតិចតួច ៥ វិជ្ជមានមធ្យម និង ៦វិជ្ជមានខ្លាំង។

[៨] UN General Assembly. A/61/299: UN Study on Violence Against Children. 2006.

[៩] UN General Assembly. A/61/299: UN Study on Violence Against Children, para 96. 2006.

ដោយចីរភាពរបស់អង្គការសហប្រជាជាតិ នៅទីក្រុងញូវយ៉ក។ របៀបវារៈដែលមាន១៧គោលដៅ និង១៦៩ ចំណុចដៅ បានចូលជាធរមាននៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៦។ អង្គការសហប្រជាជាតិនៅកម្ពុជានៅតែបន្ត គាំទ្ររាជរដ្ឋាភិបាលកម្ពុជា ក្នុងការបម្លែងការប្តេជ្ញាចិត្តចំពោះគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព«SDG» ទៅជាការអនុវត្តក្នុងស្រុក ខណៈដែលប្រទេសកម្ពុជាត្រូវបានគេរំពឹងថា នឹងធ្វើមូលដ្ឋាននីយកម្មនូវគោលដៅ ទាំង១៧ ជាមួយនឹងការបន្ថែមគោលដៅមួយលើសកម្មភាពមីន ក្នុងបរិបទនៃចក្ខុវិស័យជាតិ យុទ្ធសាស្ត្រ និង ផែនការសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។ សេចក្តីថ្លែងការណ៍ស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព ឆ្នាំ២០៣០ គិតគូរអំពីដំណើរការរួមបញ្ចូលជាមួយនឹងការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធទាំងអស់ រួមទាំង សហគមន៍ និងសង្គមស៊ីវិល ព្រមទាំងដៃគូអភិវឌ្ឍនិងវិស័យឯកជនផងដែរ។ ឆ្លើយតបទៅនឹងការសិក្សារបស់ អង្គការសហប្រជាជាតិស្តីពីអំពើហិង្សាលើកុមារ គោលដៅរបស់«SDG»បានរាប់បញ្ចូលការយកចិត្តទុកដាក់ ថ្មីមួយទៅលើកិច្ចការពារកុមារ និងការដោះស្រាយបញ្ហាអំពើហិង្សាលើកុមារ ក្នុងនោះរួមមាន៖

- គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព«SDG» ១៦.២«បញ្ចប់ការរំលោភបំពាន អំពើកេងប្រវ័ញ្ច ការ ជួញដូរ និងអំពើហិង្សាគ្រប់ទម្រង់ ព្រមទាំងការធ្វើទារុណកម្មកុមារ»
- គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព«SDG» ៥.២«លុបបំបាត់គ្រប់ទម្រង់ទាំងអស់នៃអំពើហិង្សា លើស្ត្រី និងកុមារីគ្រប់រូប នៅកន្លែងសាធារណៈនិងកន្លែងឯកជន រាប់បញ្ចូលទាំងការជួញដូរ និងការ កេងប្រវ័ញ្ចផ្លូវភេទ ព្រមទាំងការកេងប្រវ័ញ្ចក្នុងទម្រង់ដទៃទៀត»
- គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព«SDG» ១៦.១«កាត់បន្ថយគ្រប់ទម្រង់ទាំងអស់នៃអំពើហិង្សា និងអត្រាមរណៈដែលពាក់ព័ន្ធនឹងអំពើហិង្សាក្នុងកម្រិតមួយគួរឱ្យកត់សម្គាល់នៅគ្រប់កន្លែងទាំងអស់»
- គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព«SDG» ៨.៧ ស្តីពីការបញ្ចប់ទាសភាពសម័យទំនើប ការជួញដូរ មនុស្ស និងពលកម្មកុមារ។

គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពដទៃទៀតដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារ ក៏រួមចំណែកដោះស្រាយ កត្តាហានិភ័យនៃអំពើហិង្សាលើកុមារបន្ថែមទៀតដែរ ក្នុងនោះរួមមានភាពក្រីក្រ សុខភាព សមភាពយេនឌ័រ ការអប់រំ បរិយាកាសប្រកបដោយសុវត្ថិភាព និងយុត្តិធម៌។

ដើម្បីគាំទ្រដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពសម្រាប់កិច្ចការពារកុមារ **ភាពជាដៃគូសកលដើម្បី បញ្ចប់អំពើហិង្សាលើកុមារ** ត្រូវបានបង្កើតឡើង ដើម្បីជួយគាំទ្ររដ្ឋាភិបាល ទីភ្នាក់ងារអង្គការសហប្រជាជាតិ សង្គមស៊ីវិល គ្រឹះស្ថានអប់រំ វិស័យឯកជន និងប្រជាពលរដ្ឋវ័យក្មេងក្នុងការជំរុញសកម្មភាព សំដៅសម្រេចឱ្យ បាននូវគោលដៅសកលថ្មីដើម្បីបញ្ចប់អំពើរំលោភបំពាន ការកេងប្រវ័ញ្ច ការជួញដូរ និងអំពើហិង្សាគ្រប់ទម្រង់ ព្រមទាំងការធ្វើទារុណកម្មលើកុមារ។

### ១.៤.៣- យុទ្ធសាស្ត្រចំនួនប្រាំពីរសម្រាប់បញ្ចប់អំពើហិង្សាលើកុមារ(INSPIRE)

បេះដូងនៃយុទ្ធសាស្ត្ររបស់ភាពជាដៃគូសកលដើម្បីបញ្ចប់អំពើហិង្សាលើកុមារ គឺយុទ្ធសាស្ត្រចំនួនប្រាំពីរ ដើម្បីបញ្ចប់អំពើហិង្សាលើកុមារ(INSPIRE)[៤] គឺជាកញ្ចប់អន្តរាគមន៍មួយដែលមានមូលដ្ឋានផ្អែកលើភស្តុតាង ដើម្បីទប់ស្កាត់អំពើហិង្សាដែលអង្គការសុខភាពពិភពលោក(WHO) បានអភិវឌ្ឍឡើង ដោយសហការជាមួយ អ្នកឯកទេសគ្រប់វិស័យ[៥] ដោយពង្រីកបន្ថែមទៅលើយុទ្ធសាស្ត្រទាំងប្រាំមួយរបស់អង្គការយូនីសេហ្វសម្រាប់

[៤] INSPIRE http://www.who.int/iolence_injury_prevention/violence/inspire/en/

[៥] The United States Centers for Disease Control and Prevention (CDC), End Violence Against Children: The Global Partnership, the Pan American Health Organization (PAHO), the President's Emergency Program for AIDS Relief

ការធ្វើសកម្មភាព[១០] យុទ្ធសាស្ត្រចំនួនប្រាំពីរដើម្បីបញ្ចប់អំពើហិង្សាលើកុមារ ត្រូវបានពិចារណានិងបានដាក់បញ្ចូលក្នុងផែនការសកម្មភាពនេះ រួមមានសកម្មភាព លទ្ធផល និងសូចនាករ ដែលផ្តោតទៅលើការអនុវត្តនិងការពង្រឹងច្បាប់ និយាមបទដ្ឋាននិងគុណតម្លៃ បរិយាកាសប្រកបដោយសុវត្ថិភាព កិច្ចគាំទ្រឪពុកម្តាយ និងអ្នកថែទាំ ការពង្រឹងប្រាក់ចំណូលនិងសេដ្ឋកិច្ច សេវាឆ្លើយតបនិងគាំទ្រ និងការអប់រំនិងជំនាញបំណិនជីវិត។

### ១.៤.៤- ការឆ្លើយតបរបស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ចំពោះអំពើហិង្សាលើកុមារ

ក្នុងឆ្នាំ២០១១ គណៈកម្មាធិការអាស៊ានស្តីពីការលើកកម្ពស់និងការការពារសិទ្ធិស្ត្រីនិងកុមារ(ACWC) បានកំណត់ថា ការលុបបំបាត់អំពើហិង្សាលើកុមារ(EVAC) គឺជាវិស័យអាទិភាពមួយនៅក្នុងផែនការការងាររបស់គណៈកម្មាធិការអាស៊ានស្តីពីការលើកកម្ពស់និងការការពារសិទ្ធិស្ត្រីនិងកុមារក្នុងឆ្នាំ២០១២-២០១៦ ការពិនិត្យឡើងវិញជាប្រព័ន្ធមួយក្នុងឆ្នាំ២០១២ ទៅលើការស្រាវជ្រាវស្តីពីអំពើហិង្សាក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ដែលគាំទ្រដោយអង្គការយូនីសេហ្វ បានប៉ាន់ប្រមាណថា អត្រារំលោភបំពានផ្លូវកាយក្នុងចំណោមកុមារានិងកុមារីនៅក្នុងតំបន់ មានកម្រិតចន្លោះពី១០% ទៅ៣០,៣% អំពើរំលោភបំពានផ្លូវភេទ មានកម្រិតចន្លោះពី១,៧% ទៅ១១,៦% អំពើរំលោភបំពានផ្លូវចិត្ត មានកម្រិតចន្លោះពី៣១,៣% ទៅ៦៨,៥% និងពលកម្មកុមារ មានកម្រិតចន្លោះពី៦,៥% ទៅ៥៦%។ បន្ថែមពីនេះទៀត កុមារចំនួន៣នាក់ ក្នុងចំណោមកុមារ៤នាក់ នៅក្នុងតំបន់បានទទួលរងការអនុវត្តវិន័យបែបហិង្សា ដែលប្រព្រឹត្តដោយគ្រូបង្រៀនឬឪពុកម្តាយ។ ក្នុងឆ្នាំ២០១៥ ផែនការសកម្មភាពរបស់អាស៊ានស្តីពីការលុបបំបាត់អំពើហិង្សាលើកុមារ(ASEAN RPA on EVAC) ត្រូវបានអនុម័តដោយកិច្ចប្រជុំកំពូលអាស៊ាននៃប្រមុខរដ្ឋនិងរដ្ឋាភិបាល។ ផែនការសកម្មភាពថ្នាក់តំបន់នេះ មានរយៈពេល ១០ឆ្នាំ(២០១៦-២០២៥)។

### ១.៤.៥- ការឆ្លើយតបរបស់កម្ពុជាចំពោះអំពើហិង្សាលើកុមារ

គោលនយោបាយនិងក្របខ័ណ្ឌច្បាប់ក្នុងប្រទេសកម្ពុជា សម្រាប់ទប់ស្កាត់អំពើហិង្សាលើកុមារ បានចាប់ផ្តើមពីការផ្តល់សច្ចាប័នលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារក្នុងឆ្នាំ១៩៩២ និងអនុសញ្ញាអន្តរជាតិសំខាន់ៗមួយចំនួនទៀតជាបន្តបន្ទាប់ ក្នុងគោលបំណងការពារសិទ្ធិកុមារ ដែលរួមមានអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ និងសេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច។ បន្ថែមពីនេះទៀត រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣១ និងមាត្រា៤៨ ទទួលស្គាល់និងគោរពអនុសញ្ញាស្តីពីសិទ្ធិមនុស្សនិងទទួលស្គាល់សិទ្ធិកុមារ ដូចមានចែងនៅក្នុងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ជាពិសេសសិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការអប់រំ និងការចៀសផុតពីអំពើកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច និងអំពើកេងប្រវ័ញ្ចផ្លូវភេទ។ ដើម្បីបង្ការអំពើហិង្សាលើកុមារ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំនិងអនុម័តឯកសារគតិយុត្តិជាច្រើន ដែលរួមមានជាអាទិ៍ ការរំលោភបំពាន ការកេងប្រវ័ញ្ច និងការមិនអើពើ ការអប់រំ និងសុខុមាលភាពគ្រួសារ និងការថែទាំជំនួស និងកុមារដែលពាក់ព័ន្ធនៅក្នុងប្រព័ន្ធយុត្តិធម៌ ព្រមទាំងគោលនយោបាយនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

បន្ថែមពីនេះទៀត រាជរដ្ឋាភិបាលបានរៀបចំបង្កើតច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយមួយចំនួនពាក់ព័ន្ធសិទ្ធិកុមារ និងបានបង្កើតយន្តការសម្របសម្រួលកិច្ចការពារកុមារទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ[១១]។ យន្តការនៅថ្នាក់ជាតិមានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដែលមានអគ្គលេខាធិការដ្ឋាន

(PEPFAR), Together for Girls, the United Nations Children's Fund (UNICEF), United Nations Office on Drugs and Crime (UNODC), United States Agency for International Development (USAID), and the World Bank.

[១០] 10 UNICEF. Ending Violence Against Children: Six Strategies for Action. 2014

[១១] មាត្រា ៤៤ អនុសញ្ញាស្តីពីសិទ្ធិកុមារ បញ្ជាក់ថារដ្ឋភាគីត្រូវរាយការណ៍ពីស្ថានភាពសិទ្ធិកុមារជូនគណៈកម្មាធិការ អង្គការសហប្រជាជាតិ។

និងអនុគណៈកម្មការ ចំណែកនៅតាមក្រសួង ស្ថាប័ន បានបង្កើតគណៈកម្មាធិការមួយចំនួន។ ទន្ទឹមនឹងនេះ នៅថ្នាក់ក្រោមជាតិបានបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ(ក.ជ.ក.) រាជធានី ខេត្ត គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រីនិងកុមារ(គ.ក.ស.ក.) រាជធានី ខេត្ត គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រីនិងកុមារ (គ.ក.ស.ក.) ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ(គ.ក.ន.ក.) ឃុំ សង្កាត់ ហើយក៏បានបង្កើតគណៈកម្មការប្រឆាំងពលកម្មកុមាររាជធានី ខេត្ត គណៈកម្មាធិការរាជធានី ខេត្ត គរបជ/គខបជ និងយន្តការគាំពារនិងអភិវឌ្ឍកុមារតូចនៅថ្នាក់ក្រោមជាតិដែលជាខ្សែបណ្តាយរបស់គណៈកម្មាធិការនៅថ្នាក់ជាតិ។ បើទោះជាដូច្នេះក្តី រាជរដ្ឋាភិបាលកម្ពុជាក៏ទទួលស្គាល់ផងដែរអំពីសេចក្តីត្រូវការក្នុងការបោះជំហានឱ្យហួសពីគោលនយោបាយនិងក្របខ័ណ្ឌច្បាប់ដើម្បីឱ្យមានអន្តរាគមន៍ឆ្លើយតបដែលមានការកំណត់គោលដៅប្រសើរជាងនេះ ចំពោះបញ្ហាអំពើហិង្សាលើកុមារ។

## ១.៥- ក្របខ័ណ្ឌយុទ្ធសាស្ត្រក្នុងការរៀបចំផែនការសកម្មភាពជាតិ

ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០២៥-២០៣០ ត្រូវបានរៀបចំឡើងផ្អែកលើ (១)គោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩-២០២៩ (២)អនុសាសន៍នៃរបាយការណ៍វាយតម្លៃផែនការសកម្មភាពដើម្បីទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០១៧-២០២១ (៣)អនុសាសន៍នៃការពិនិត្យពាក់កណ្តាលអាណត្តិនៃវិស័យអាទិភាពក្រោមផែនការកម្មភាពតំបន់អាស៊ានស្តីពីការលុបបំបាត់អំពើហិង្សាលើកុមារ ឆ្នាំ២០១៦-២០២៥ (៤)ប្រសិទ្ធភាពនៃការអនុវត្តមុខងារដូចមានចែងនៅក្នុងគោលនយោបាយ អនុក្រឹត្យ ប្រកាស សេចក្តីសម្រេច និងសេចក្តីណែនាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (៥)ការពិនិត្យនិងវិភាគទៅលើចំណុចខ្វះចន្លោះនៃសកម្មភាពដែលមានស្រាប់ (៦)ការប្តេជ្ញាចិត្តជាគន្លឹះរបស់ក្រសួងស្ថាប័នពាក់ព័ន្ធ (៧)ការពិនិត្យទៅលើការអនុវត្ត និងបទពិសោធល្អៗក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាលើកុមារនៅប្រទេសកម្ពុជានិងប្រទេសដទៃទៀត (៨)ដោយផ្តោតលើអភិក្រមអន្តរវិស័យ និងវដ្តនៃអំពើហិង្សា (៩)យុទ្ធសាស្ត្រ ព្រមទាំងផែនការសកម្មភាពតាមវិស័យដទៃទៀតដែលពាក់ព័ន្ធ (១០)ការប្តេជ្ញាចិត្តរបស់កម្ពុជា ក្នុងការសម្រេចបានគោលដៅបញ្ចប់អំពើហិង្សាលើកុមាររបស់ប្រទេសកម្ពុជានិងសម្រេចតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព«SDGs» នៅត្រឹមឆ្នាំ២០៣០ និង (១១)លិខិតលេខ១៧១៩ សជណ.សស ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រីបានឯកភាពលើសេចក្តីព្រាងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់ការចូលរួមក្នុងសន្និសីទពិភពលោកថ្នាក់រដ្ឋមន្ត្រី លើកទី១ ដើម្បីបញ្ចប់អំពើហិង្សាលើកុមារ[១២] មានដូចជា៖

- ទី១- ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ ច្បាប់ជាតិ គោលនយោបាយ ផែនការ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីលើកកម្ពស់សុខុមាលភាពនិងកិច្ចការពារកុមារ ដូចជាគោលនយោបាយជាតិគាំពារសង្គម គោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារជាដើម ព្រមទាំងជំរុញការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារកុមារ និងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០២៥-២០៣០។
- ទី២- ពង្រឹងនិងពង្រីកការអនុវត្តកម្មវិធីកិច្ចការពារកុមារនៅកម្ពុជា ដូចជាការចិញ្ចឹមកូនបែបវិជ្ជមាន ការដាក់វិន័យបែបវិជ្ជានៅតាមសាលារៀន កិច្ចការពារកុមារនៅតាមវត្តអារាម និងកិច្ចការពារកុមារ

---

[១២]ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីបញ្ចប់អំពើហិង្សាលើកុមារ ថ្លែងដោយ **លោកជំទាវ ញៀប សុភាព** រដ្ឋលេខាធិការទទួលបន្ទុកជំនួសឯកឧត្តម **ឯកឧត្តម ជា សុមេធី រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ក្នុងសន្និសីទពិភពលោកថ្នាក់រដ្ឋមន្ត្រីលើកទី១ ដើម្បីបញ្ចប់អំពើហិង្សាលើកុមារ នៅថ្ងៃទី៧-៨ ខែវិច្ឆិកា ឆ្នាំ២០២៤ ទីក្រុងប៊ូហ្គោតា ប្រទេសកូឡុំប៊ី។

តាមប្រព័ន្ធអនឡាញជាដើម ដើម្បីធានាថាកុមារត្រូវបានការពារនិងរស់នៅក្នុងបរិយាកាសមួយប្រកបដោយសុវត្ថិភាព។

ទី៣- ពង្រឹងប្រព័ន្ធប្រមូលទិន្នន័យនិងគ្រប់គ្រងកិច្ចការពារកុមារ ការវិភាគទិន្នន័យនិងការប្រើប្រាស់ទិន្នន័យសម្រាប់រៀបចំត្រួតពិនិត្យនិងវាយតម្លៃគោលនយោបាយ ផែនការ និងកម្មវិធីជាតិ រួមទាំងអនុសញ្ញាស្តីពីសិទ្ធិកុមារ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព«SDG»។

ទី៤- ពង្រឹងសមត្ថភាពកម្លាំងសេវាសង្គមសម្រាប់ផ្តល់សេវាកិច្ចការពារកុមារ ជាអាទិ៍កុមាររងគ្រោះដោយអំពើហិង្សា កុមារមានពិការភាព និងកុមារក្នុងស្ថានភាពរស់នៅ និងស្ថានភាពយេនឌ័រខុសៗគ្នា កុមារទំនាស់នឹងច្បាប់ ការមិនអើពើ ការរំលោភបំពាន ការជួញដូរ និងការគំរាមកំហែងគ្រប់រូបភាពឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ពីថ្នាក់សហគមន៍មូលដ្ឋាន ដល់ថ្នាក់ជាតិ រួមទាំងយន្តការវិធានការព្រមទាំងពង្រីកហេដ្ឋារចនាសម្ព័ន្ធបែបកុមារមេត្រី ដែលឆ្លើយតបទៅនឹងតម្រូវការតាមស្ថានភាពនៃកុមារ។

ទី៥- លើកកម្ពស់និងពង្រឹងកិច្ចសហប្រតិបត្តិការពីគ្រប់ភាគីដែលពាក់ព័ន្ធក្នុងរាជរដ្ឋាភិបាល ដោយប្រើប្រាស់យន្តការដែលមានស្រាប់ដើម្បីលើកកម្ពស់សុខុមាលភាពកុមារនិងកិច្ចការពារកុមារ ជាពិសេសពង្រឹងយន្តការសម្របសម្រួល ដើម្បីចាត់វិធានការទាន់ពេលវេលានិងតឹងរ៉ឹងដាច់ខាតចំពោះសកម្មភាពហិង្សាគ្រប់ទម្រង់លើកុមារ។

ទី៦- បង្កើនថវិកាជាតិសម្រាប់កុមារក្នុងក្របខ័ណ្ឌគាំពារសង្គមនិងសេវាសង្គម ព្រមទាំងការកៀរគរធនធានទាំងហិរញ្ញវត្ថុពីដៃគូនិងវិស័យឯកជន ដើម្បីគាំទ្រនិងធានាចីរភាពនៃចលនាបញ្ចប់អំពើហិង្សាលើកុមារ។

ទី៧- លើកកម្ពស់ការចូលរួមក្នុងការធ្វើឱ្យមានការផ្លាស់ប្តូរការគិតនិងឥរិយាបថសង្គម ពីគ្រប់ភាគីពាក់ព័ន្ធដូចជារដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន សាសនា គ្រួសារ សហគមន៍ ជាពិសេសកុមារនិងយុវជន ដើម្បីកសាងគ្រួសារនិងសង្គមមួយដែលមានសុវត្ថិភាពនិងគ្មានអំពើហិង្សាលើកុមារ។

### ១.៥.១- ទ្រឹស្តីនៃការផ្លាស់ប្តូរស្តីពីអំពើហិង្សាលើកុមារ

ទ្រឹស្តីនៃការផ្លាស់ប្តូរស្តីពីអំពើហិង្សាលើកុមារក្នុងប្រទេសកម្ពុជា ប្រតិបត្តិនៅ«កម្រិតប្រព័ន្ធ» និងកំណត់អំពីរបៀបនៃការផ្លាស់ប្តូរទៅលើប្រព័ន្ធការពារកុមាររបស់ប្រទេសកម្ពុជា ដែលអាចនាំឱ្យសម្រេចបាននូវគោលបំណងក្នុងការកាត់បន្ថយ ឬលុបបំបាត់អំពើហិង្សាលើកុមារគ្រប់ទម្រង់ក្នុងប្រទេសកម្ពុជា។ ទ្រឹស្តីនៃការផ្លាស់ប្តូរបានរកឃើញកត្តាកំណត់ចម្បងៗនៃអំពើហិង្សាលើកុមារមានចំនួន៧ ដែលត្រូវដោះស្រាយនៅក្នុងផែនការសកម្មភាព : ភាពក្រីក្រនិងវិសមភាពផ្នែកសង្គមសេដ្ឋកិច្ច ការអប់រំ ទម្លាប់ដែលគាំទ្រដល់ការអនុវត្តវិន័យបែបហិង្សា ទម្លាប់រើសអើងយេនឌ័រ និទណ្ឌភាព ខ្វះការយល់ដឹងអំពីច្បាប់ដែលមានស្រាប់ បទពិសោធរងអំពើហិង្សាកន្លងមករបស់កុមារ និងកង្វះសេវាការពារនិងឆ្លើយតបចំពោះកិច្ចការពារកុមារ។

ក្នុងការអភិវឌ្ឍកិច្ចអន្តរាគមន៍ ដើម្បីដោះស្រាយកត្តាកំណត់អំពីអំពើហិង្សាលើកុមារ ទ្រឹស្តីនៃការផ្លាស់ប្តូរបានធ្វើការសំដៅដល់ការអនុវត្តល្អដែលមានស្រាប់ ក្នុងការបង្ការនិងឆ្លើយតបទៅនឹងអំពើហិង្សាលើកុមារ ក្នុងនោះរាប់បញ្ចូលការសិក្សាស្រាវជ្រាវរបស់អង្គការសហប្រជាជាតិស្តីពីអំពើហិង្សាលើកុមារ យុទ្ធសាស្ត្រទាំងពីរសម្រាប់បញ្ចប់អំពើហិង្សាលើកុមារ(INSPIRE)របស់ភាពជាដៃគូសកល ចូលរួមចំណែកនិងបានទទួលការគាំទ្រពីសកម្មភាពដើម្បីសម្រេចបានចំណុចដៅ៤.៧ ត្រឹមឆ្នាំ២០៣០ ធានាបានថាអ្នកសិក្សាទាំងអស់ទទួល

បានចំណេះដឹងនិងជំនាញដែលចាំបាច់ ដើម្បីលើកកម្ពស់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព រួមមានតាមរយៈការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនិងរបៀបរស់នៅប្រកបដោយនិរន្តរភាព សិទ្ធិមនុស្ស សមភាពយេនឌ័រ ការលើកកម្ពស់វប្បធម៌សន្តិភាពនិងអហិង្សា ភាពជាពលរដ្ឋសកលនិងការឱ្យតម្លៃចម្រុះគ្នាផ្នែកវប្បធម៌ ព្រមទាំងការចូលរួមចំណែករបស់វប្បធម៌ទៅក្នុងការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងចំណុចដៅ ៥.១ បញ្ឈប់គ្រប់ទម្រង់ទាំងអស់នៃការរើសអើងស្ត្រីនិងកុមារីទាំងអស់នៅគ្រប់ទិសទី នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

ឥទ្ធិពលជាសក្តានុពលនៃការផ្លាស់ប្តូរនិយាមនិងគុណតម្លៃមកលើការកាត់បន្ថយអំពើហិង្សាលើកុមារ រួមមាន (១)កាត់បន្ថយការទទួលយកអំពើហិង្សាលើស្ត្រីនិងកុមារ (២)ជំនឿកាន់តែគួរជាទីចង់បានទាក់ទងជាមួយសមភាពយេនឌ័រ និងបំណែងចែកពលកម្មដែលមានសមភាពយេនឌ័រ (៣)ឥរិយាបថគួរជាទីចង់បានថែមទៀតចំពោះគោលវិធីអហិង្សានៅក្នុងការដាក់ពិន័យរបស់ឪពុកម្តាយ (៤)ការទទួលស្គាល់កាន់តែច្រើនឡើងអំពីធាតុដែលបង្កឱ្យមានអាកប្បកិរិយារំលោភបំពានចំពោះដៃគូស្និទ្ធស្នាលនិងកុមារ (៥)បង្កើនអន្តរាគមន៍ពីភាគីពាក់ព័ន្ធដើម្បីបង្ការអំពើហិង្សាលើកុមារនិងដៃគូស្និទ្ធស្នាល និង(៦)កាត់បន្ថយអំពើហិង្សាផ្លូវកាយឬអំពើហិង្សាផ្លូវភេទប្រព្រឹត្តដោយឪពុកម្តាយ ឬដៃគូស្និទ្ធស្នាល។

### ១.៥.២- គោលការណ៍ទូទៅនិងអភិក្រម

គណៈកម្មាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិកុមារ បានពន្យល់អំពីអ្វីដែលត្រូវបញ្ចូលទៅក្នុងក្របខ័ណ្ឌនៃការសម្របសម្រួលដើម្បីដោះស្រាយបញ្ហាអំពើហិង្សាលើកុមារ ឬឆ្លើយតបទៅនឹងផែនការសកម្មភាពជាតិ[១៣],[១៤] ដែលត្រូវបញ្ចូលវិធានការផ្នែកច្បាប់ រដ្ឋបាល សង្គម និងការអប់រំ ព្រមទាំងដំណាក់កាលនៃកិច្ចអន្តរាគមន៍(ចាប់ពីការទប់ស្កាត់ រហូតដល់ពេលសះជាឡើងវិញ និងសមាហរណកម្ម)[១៥]។ ការអភិវឌ្ឍផែនការសកម្មភាពនេះ ទទួលបាននូវមគ្គុទ្ទេសក៍ណែនាំពីគោលការណ៍មួយចំនួន ដូចខាងក្រោម៖

- **ភាពជាម្ចាស់របស់រាជរដ្ឋាភិបាលទៅលើផែនការសកម្មភាពជាតិ :** ការទទួលស្គាល់ភាពជាម្ចាស់របស់រាជរដ្ឋាភិបាលកម្ពុជាទៅលើផែនការនេះ គឺផ្អែកលើការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលចំពោះសិទ្ធិកុមារឱ្យរួចផុតពីអំពើហិង្សាគ្រប់ទម្រង់ ការអភិវឌ្ឍផែនការជាតិរយៈពេល៥ឆ្នាំ គឺជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងដែលមានការសម្របសម្រួល ក្រោមការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល ដោយមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការចូលរួមយ៉ាងសកម្ម និងកិច្ចសហការពីក្រសួង ស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិ វិស័យឯកជន និងដៃគូអភិវឌ្ឍដទៃទៀត
- **អភិក្រមសិទ្ធិកុមារ :** ការទទួលស្គាល់ថា កុមារគឺជាម្ចាស់សិទ្ធិនិងមិនមែនជាអ្នកទទួលផលនៃសកម្មភាពមនុស្សធម៌របស់មនុស្សពេញវ័យឡើយ។ ការអភិវឌ្ឍផែនការសកម្មភាពជាតិនេះមានការចូលរួមពីកុមារនិងកុមារវ័យជំទង់ក្នុងនាមជាម្ចាស់សិទ្ធិ ហើយនឹងខិតខំបញ្ចូលការចូលរួមរបស់ពួកគេទៅក្នុងការអនុវត្តការពិនិត្យនិងការវាយតម្លៃផងដែរ(ដោយពិចារណាទៅលើអាយុនិងសមត្ថភាពរបស់ពួកគេ)
- **ទិដ្ឋភាពយេនឌ័រនិងអំពើហិង្សាលើកុមារ :** ការពិចារណាអំពីហានិភ័យផ្សេងៗគ្នា ដែលកុមារីនិងកុមារាកំពុងជួបប្រទះនៅក្នុងបរិបទផ្សេងៗគ្នា ទាក់ទងនឹងអំពើហិង្សាក្នុងទម្រង់ផ្សេងៗគ្នា ព្រមទាំងក្នុង

---

[១៣] UNCRC, The Rights of the Child to Freedom from all Forms of Violence, 2011

[១៤] Special Representative of the Secretary General on Violence Against Children, Toward a World Free from Violence: Global Survey on Violence Against Children, 2013.

[១៥] UNCRC, The Rights of the Child to Freedom from all Forms of Violence, 2011.

គោលបំណងដោះស្រាយរាល់ទម្រង់ទាំងអស់នៃការរើសអើងផ្អែកយេនឌ័រដែលរួមចំណែកធ្វើឱ្យអំពើហិង្សាតែងកើតមានទៅលើកុមារ

- **ការទប់ស្កាត់បឋម :** យល់ថាការទប់ស្កាត់ គឺជាសកម្មភាពសំខាន់បំផុតនៅក្នុងរាល់ការឆ្លើយតបទៅនឹងអំពើហិង្សាលើកុមារ
- **តួនាទីបឋមរបស់គ្រួសារ :** ការទទួលស្គាល់ពីតួនាទីបឋមរបស់គ្រួសារក្នុងការការពារកុមារពីអំពើហិង្សា និងការទទួលស្គាល់ផងដែរថា អំពើហិង្សាអាចកើតមាននៅក្នុងបរិបទគ្រួសារ
- **ភាពធន់និងកត្តាការពារ :** ការទទួលស្គាល់អំពីចំណុចខ្លាំងខាងក្នុងនិងខាងក្រៅ ព្រមទាំងកិច្ចគាំទ្រដែលលើកកម្ពស់សន្តិសុខផ្ទាល់ខ្លួនរបស់កុមារ និងកាត់បន្ថយការរំលោភបំពាន និងការមិនអើពើ ព្រមទាំងផលប៉ះពាល់អវិជ្ជមានសកម្មភាពទាំងនេះ។ ឧទាហរណ៍ គ្រួសារដែលមានស្ថិរភាព មនុស្សពេញវ័យដែលជាអ្នកបីបាច់ថែទាំកុមារ បានបំពេញទៅតាមសេចក្តីត្រូវការរបស់កុមារ ការប្រើវិន័យបែបវិជ្ជមាន និងក្នុងភាពអហិង្សា ការផ្សារភ្ជាប់ទំនាក់ទំនងជាមួយមនុស្សពេញវ័យប្រកបដោយសុវត្ថិភាព ទំនាក់ទំនងដែលផ្តល់កិច្ចគាំទ្រជាមួយមិត្តភក្តិ ការផ្សារភ្ជាប់ទៅក្នុងសង្គម និងបរិយាកាសអហិង្សានៅក្នុងសង្គម
- **ការកាត់បន្ថយកត្តាហានិភ័យ :** ការទទួលស្គាល់ថា ត្រូវចាត់វិធានការបែបប្រតិសកម្មទៅតាមស្ថានភាពជាក់ស្តែង ដើម្បីកាត់បន្ថយកត្តាហានិភ័យដែលកុមារម្នាក់ៗនិងក្រុមកុមារអាចរងកត្តាប្រឈម ក្នុងនោះរាប់បញ្ចូលការប្រើប្រាស់គ្រឿងញៀន បញ្ហាសុខភាពផ្លូវចិត្ត និងការផ្តាច់ខ្លួនពីសង្គម ព្រមទាំងកត្តាហានិភ័យគ្រួសារ ដូចជា ភាពក្រីក្រ ភាពគ្មានការងារធ្វើ និងការរើសអើង
- **កុមារដែលមានការប្រឈមខ្ពស់និងស្ថិតនៅក្នុងស្ថានភាពងាយរងគ្រោះ :** ការទទួលស្គាល់កុមារដែលស្ថិតនៅក្នុងស្ថានភាពងាយរងគ្រោះនិងកុមារដែលមានការប្រឈមខ្ពស់ទៅនឹងអំពើហិង្សា។ ឧទាហរណ៍ កុមារដែលស្ថិតនៅក្នុងការថែទាំជំនួស កុមារដែលរស់នៅនិងធ្វើការងារតាមចិញ្ចើមថ្នល់ កុមារមានទំនាស់នឹងច្បាប់ កុមារមានពិការភាព កុមារនៃក្រុមជនជាតិដើមភាគតិច កុមារស្រឡាញ់ភេទដូចគ្នា កុមារដែលធាប់រៀបអាពាហ៍ពិពាហ៍ កុមារដែលចូលរួមនៅក្នុងពលកម្មប្រកបដោយគ្រោះថ្នាក់ និងកុមារចំណាកស្រុក ឬកុមារដែលត្រូវបានជម្លៀស និងកុមាររស់នៅក្នុងគ្រួសារក្រីក្រ
- **ធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងធនធានបច្ចេកទេស :** ការពិចារណាថា ធនធានគប្បីត្រូវបានបែងចែកទូទាំងវិស័យ ក្នុងកម្រិតអតិបរមានៃធនធានដែលមាន និងគប្បីអភិវឌ្ឍយន្តការត្រួតពិនិត្យឱ្យបានរឹងមាំ ដើម្បីធានាបាននូវគណនេយ្យភាពក្នុងការវិភាជនិងប្រើប្រាស់ថវិកា
- **ការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព :** ការយល់ថា ត្រូវមានយន្តការ ដើម្បីធានាឱ្យមានការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់មូលដ្ឋាន រវាងវិស័យនីមួយៗ និងជាមួយសង្គមស៊ីវិល
- **យន្តការគណនេយ្យភាព :** ការបង្កើតឱ្យមានយន្តការគណនេយ្យភាព ព្រមជាមួយនឹងប្រព័ន្ធ និងឧបករណ៍នានាសម្រាប់ពិនិត្យ វាយតម្លៃ និងរាយការណ៍អំពីកាតព្វកិច្ចក្នុងការអនុវត្តសកម្មភាព។

## ១.៦- បញ្ហាអាទិភាព

បញ្ហាប្រឈមចម្បងៗសម្រាប់គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល និងវិស័យឯកជនត្រូវចូលរួមដោះស្រាយ រួមមាន៖

- ចំណេះដឹងនិងការអនុវត្តរបស់អ្នកសារព័ត៌មាន និងគ្រឹះស្ថានប្រព័ន្ធផ្សព្វផ្សាយក្នុងការបង្ការ ឆ្លើយតប និងរាយការណ៍ឱ្យបានសមស្រប នៅមានកម្រិតចំពោះបញ្ហាអំពើហិង្សាលើកុមារ ដោយសារខ្វះធនធានសម្រាប់បណ្តុះបណ្តាល និងកិច្ចសហការពីស្ថាប័នពាក់ព័ន្ធក្នុងការពង្រឹងសមត្ថភាពនេះ

- ធនធាននៅមានកម្រិត( ថវិកា កម្លាំងសេវាសង្គម និងសម្ភារៈ ) សម្រាប់គាំទ្រដល់ការទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ និងកិច្ចការពារកុមារ
- ការផ្សព្វផ្សាយអំពីផែនការសកម្មភាពស្តីពីការបង្ការទប់ស្កាត់អាពាហ៍ពិពាហ៍វ័យក្មេង និងការមានផ្ទៃពោះវ័យជំទង់និងផលលំបាកនៃការរៀបអាពាហ៍ពិពាហ៍វ័យកុមារ នៅមិនទាន់បានទូលំទូលាយដោយសារភាពខ្វះចន្លោះនៃការធ្វើការរួមគ្នាលើការងារនេះនៅតំបន់ដែលមានអត្រារៀបការវ័យកុមារច្រើន
- ការអនុវត្តកម្មវិធីអប់រំពីការចិញ្ចឹមកូនបែបវិជ្ជមានទាំងពាកម្រិត នៅមានការចូលរួមតិចតួចពីឪពុកម្តាយនិងអ្នកថែទាំកុមារ ដោយសារបញ្ហាជីវភាពគ្រួសារជួបការលំបាក បញ្ហាចំណាកស្រុករបស់ប្រជាពលរដ្ឋការលំបាកក្នុងការកំណត់អត្តសញ្ញាណគ្រួសារដែលមានកូនមានពិការភាព និងមិនទាន់បានបញ្ចូលទៅក្នុងផែនការវិនិយោគខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ សម្រាប់អនុវត្តសកម្មភាពនេះ
- ការយល់ដឹងរបស់សហគមន៍និងអាជ្ញាធរមូលដ្ឋាន នៅមិនទាន់ច្បាស់លាស់អំពីសេវាថែទាំកុមាររងគ្រោះដោយអំពើហិង្សាលើកុមារ ធ្វើឱ្យពួកគាត់ពិបាកក្នុងការបញ្ជូនកុមារទៅរកសេវាសមស្របព្រមទាំងនៅមានឥរិយាបថស្តីបន្ទោស ការរើសអើងចំពោះកុមារ និងគ្រួសារដែលរងគ្រោះដោយការរំលោភបំពានផ្លូវភេទ
- ការអនុវត្តវិធានការការពារកុមារលើប្រព័ន្ធអនឡាញរបស់ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត និងក្រុមហ៊ុនបច្ចេកវិទ្យាក្នុងស្រុកនៅមានកម្រិត និងមិនទាន់ឆ្លើយតបនឹងបញ្ហា
- សេវាសម្រាប់ជនរងគ្រោះដោយសារអំពើហិង្សានៅតាមសហគមន៍ នៅតិចតួច ហើយមណ្ឌលសុខភាពឬមន្ទីរពេទ្យបង្អែកពិបាកស្វែងរកនិងបញ្ជូនបន្តពេលកុមាររងគ្រោះទទួលបានការព្យាបាលបឋមរួចជាពិសេសពិគ្រោះយោបល់ផ្លូវចិត្ត សេវាប្រឹក្សាផ្លូវច្បាប់ និងសេវាចាំបាច់ដទៃទៀត។

## ២- យុទ្ធសាស្ត្រ

គោលដៅរួមនៃផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារឆ្នាំ២០២៥-២០៣០ គឺដើម្បីកាត់បន្ថយអំពើហិង្សាលើកុមារដែលមានហានិភ័យខ្ពស់តាមរយៈការបង្កើនកិច្ចអន្តរាគមន៍បង្ការទប់ស្កាត់ ការបង្កើនការឆ្លើយតប ការបង្កើនការទទួលបានសេវាប្រកបដោយគុណភាពប្រសិទ្ធភាព និងការសម្របសម្រួលពហុវិស័យនិងកិច្ចសហការ។ គោលដៅយុទ្ធសាស្ត្រសំខាន់ៗចំនួន៥ ត្រូវបានកំណត់ថាជាយុទ្ធសាស្ត្រចម្បងដែលត្រូវផ្តោតការយកចិត្តទុកដាក់ រួមមាន៖

យុទ្ធសាស្ត្រទី១ : ការសម្របសម្រួលនិងកិច្ចសហប្រតិបត្តិការ

យុទ្ធសាស្ត្រទី២ : ការបង្ការនិងទប់ស្កាត់

យុទ្ធសាស្ត្រទី៣ : សេវាឆ្លើយតបជាពហុវិស័យចំពោះកិច្ចការពារកុមារ

យុទ្ធសាស្ត្រទី៤ : ការរៀបចំក្របខ័ណ្ឌគតិយុត្តនិងប្រព័ន្ធយុត្តិធម៌

យុទ្ធសាស្ត្រទី៥ : ការត្រួតពិនិត្យនិងវាយតម្លៃ។

ដោយផ្អែកលើយុទ្ធសាស្ត្រទាំង៥នេះ រាជរដ្ឋាភិបាលកម្ពុជាបានណែនាំចង្អុលសកម្មភាព(ច.ស.)សំខាន់ៗដូចខាងក្រោម៖

**យុទ្ធសាស្ត្រទី១ : ការសម្របសម្រួលនិងកិច្ចសហប្រតិបត្តិការ**

ច.ស. ទី១.១- ពង្រឹងយន្តការសម្របសម្រួលអនុវត្តផែនការសកម្មភាពជាតិទាំងនៅថ្នាក់ជាតិនិងនៅថ្នាក់ក្រោមជាតិ

ច.ស. ទី១.២- ពង្រឹងនិងពង្រីកយន្តការកិច្ចការពារកុមារនៅតាមសាលារៀនរដ្ឋនិងឯកជន

ច.ស. ទី១.៣- ពង្រឹងបណ្តាញយុវជននិងកុមារ ចូលរួមសម្របសម្រួលក្នុងការទប់ស្កាត់អំពើហិង្សាលើកុមារ។

**យុទ្ធសាស្ត្រទី២ : ការបង្ការនិងទប់ស្កាត់**

ច.ស. ទី២.១- បង្កើនការផ្សព្វផ្សាយអំពីការទប់ស្កាត់អំពើហិង្សាលើកុមារ និងការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារ តាមប្រព័ន្ធអនឡាញ(OCSE)

ច.ស. ទី២.២- បង្កើនការវិនិយោគលើកម្មវិធីការពារកុមារនិងអំពីការប្រើអ៊ីនធឺណិតប្រកបដោយសុវត្ថិភាព ទៅក្នុងកម្មវិធីវិនិយោគខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់

ច.ស. ទី២.៣- បង្កើនការផ្សព្វផ្សាយការទប់ស្កាត់អំពើហិង្សាលើកុមារ ទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់ និងទប់ស្កាត់ការកេងប្រវ័ញ្ចមកលើកុមារនៅតាមខ្នងផ្ទះ សាលារៀន សហគមន៍ កន្លែងធ្វើការ សហគ្រាស គ្រឹះស្ថាន និងកន្លែងថែទាំកុមារ។

**យុទ្ធសាស្ត្រទី៣ : សេវាឆ្លើយតបជាពហុវិស័យចំពោះកិច្ចការពារកុមារ**

ច.ស. ទី៣.១- ពង្រឹងប្រព័ន្ធរាយការណ៍អំពើហិង្សាលើកុមារនិងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ(OCSE)

ច.ស. ទី៣.២- ពង្រឹងប្រព័ន្ធអន្តរាគមន៍ចំពោះអំពើហិង្សាលើកុមារនិងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ(OCSE)

ច.ស. ទី៣.៣- ពង្រឹងប្រព័ន្ធឆ្លើយតបនិងផ្តល់សេវាដល់កុមាររងគ្រោះដោយអំពើហិង្សានិងការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារ តាមប្រព័ន្ធអនឡាញ(OCSE)

ច.ស. ទី៣.៤- ពង្រឹងប្រព័ន្ធឆ្លើយតបតាមរយៈការផ្តល់សេវាកិច្ចអន្តរាគមន៍ស្នូល សេវាសន្តិសុខសង្គមនិងការបណ្តុះបណ្តាលជំនាញដល់ជនងាយរងគ្រោះដោយសារអំពើហិង្សានិងការកេងប្រវ័ញ្ចកម្លាំងពលកម្មមកលើកុមារ។

**យុទ្ធសាស្ត្រទី៤ : ការរៀបចំក្របខ័ណ្ឌគតិយុត្តនិងប្រព័ន្ធយុត្តិធម៌**

ច.ស. ទី៤.១- ពិនិត្យនិងបំពេញបន្ថែមចន្លោះខ្វះខាតខ្លឹមសារនៅក្នុងក្របខ័ណ្ឌគតិយុត្ត

ច.ស. ទី៤.២- ជំរុញការអនុវត្តគោលនយោបាយពាក់ព័ន្ធនឹងកិច្ចការពារកុមារ និងការប្តេជ្ញារបស់រាជរដ្ឋាភិបាលលើការលុបបំបាត់អំពើហិង្សាលើកុមារ។

**យុទ្ធសាស្ត្រទី៥ : ការត្រួតពិនិត្យនិងវាយតម្លៃ**

ច.ស. ទី៥.១- បង្កើតក្របខ័ណ្ឌត្រួតពិនិត្យនិងវាយតម្លៃពហុវិស័យ

ច.ស. ទី៥.២- ពង្រឹងប្រព័ន្ធប្រមូលទិន្នន័យនិងរាយការណ៍ដើម្បីផ្តល់ភស្តុតាងសម្រាប់រៀបចំតាក់តែងគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំ។

## ៣- ផែនការសកម្មភាព

ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០២៥-២០៣០ គឺផ្អែកលើចក្ខុវិស័យរបស់គោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ ២០១៩-២០២៩«ធានាឱ្យកុមារគ្រប់រូបនៅក្នុងព្រះរាជាណាចក្រកម្ពុជា ទទួលបាននូវសិទ្ធិស្មើៗគ្នា ដូចមានចែងនៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ

និងពិធីសារបន្ថែម មានសិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបាននូវការការពារ សិទ្ធិអភិវឌ្ឍន៍ និងសិទ្ធិចូលរួម»។ ដូច្នេះ ចាំបាច់ត្រូវយកចិត្តទុកដាក់លើកកម្ពស់កិច្ចការពារកុមារបន្ថែមទៀត តាមរយៈការពង្រឹងការអនុវត្តប្រព័ន្ធកិច្ចការពារកុមារមានលក្ខណៈគ្រប់ជ្រុងជ្រោយនិងប្រទាក់ក្រឡាគ្នាពីគ្រប់ភាគីពាក់ព័ន្ធ សំដៅឆ្លើយតបទៅនឹងកិច្ចការពារកុមារពីការរំលោភបំពាននិងកេងប្រវ័ញ្ចគ្រប់ទម្រង់ ដើម្បីឧត្តមប្រយោជន៍កុមារ។

## ៣.១- វិសាលភាព

ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០២៥-២០៣០ គ្របដណ្តប់លើ៖

- គ្រប់ក្រសួងនិងស្ថាប័នពាក់ព័ន្ធ
- រដ្ឋបាលថ្នាក់ក្រោមជាតិ
- ដៃគូអភិវឌ្ឍ
- សង្គមស៊ីវិល
- អង្គការផ្អែកលើជំនឿសាសនា
- ក្រុមកុមាររងគ្រោះនិងងាយរងគ្រោះ
- សាធារណជនទូទៅ។

## ៣.២- សកម្មភាពនៃការអនុវត្តការងារ

អភិក្រមសម្រាប់ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០២៥-២០៣០ មានគោលបំណងផ្តល់នូវមូលដ្ឋានច្បាស់លាស់ ដោយផ្តោតទៅលើការបង្ការនិងទប់ស្កាត់ការអន្តរាគមន៍ និងផ្តល់សេវាឆ្លើយតបជាពហុវិស័យ ប្រទាក់ក្រឡានិងស៊ីចង្វាក់គ្នា មានប្រសិទ្ធភាព គុណភាព និងបានទាន់ពេលវេលា ដើម្បីឱ្យកុមាររងគ្រោះឱ្យទទួលបានសុវត្ថិភាពទាំងរាងកាយ ផ្លូវចិត្ត និងសុខុមាលភាព និងជំរុញឱ្យមានផ្លាស់ប្តូរឥរិយាបថសង្គមចំពោះការប្រព្រឹត្តទៅលើកុមារ។

ការឆ្លើយតបប្រកបដោយប្រសិទ្ធភាពជាច្រើន គឺអាស្រ័យទៅលើកិច្ចសហការនិងកិច្ចសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធដទៃទៀត ដូច្នេះគណនេយ្យភាពនិងការទទួលខុសត្រូវច្បាស់លាស់របស់អ្នកពាក់ព័ន្ធពិតជាមានសារៈសំខាន់ណាស់។ កិច្ចសហការនិងការសម្របសម្រួលត្រូវតែធ្វើឡើងនៅគ្រប់កម្រិតទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងរវាងក្រសួង ស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជន និងជាលក្ខណៈបុគ្គល ហើយការឆ្លើយតបដែលមានការសម្របសម្រួល មានឥទ្ធិពលក្នុងការបង្កើតឱ្យមានការផ្លាស់ប្តូរជាវិជ្ជមានផ្សេងទៀតដែលចាំបាច់ក្នុងការកាត់បន្ថយអំពើហិង្សាលើកុមារ។ សូចនាករដាក់លាក់មិនត្រូវបានរំលេចក្នុងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០២៥-២០៣០ នេះទេ ដោយសូចនាករជាក់លាក់ទាំងនេះនឹងដាក់នៅក្នុងផែនការប្រតិបត្តិ និងផែនការថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនីមួយៗ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តផែនការសកម្មភាពជាតិនេះ។

| | |
|---|---|
| គោលបំណងទូទៅ : | អំពើហិង្សាលើកុមារគ្រប់រូបភាពត្រូវបានកាត់បន្ថយ និងឈានទៅលុបបំបាត់តាមរយៈការបង្កើនបង្ការទប់ស្កាត់ ការអន្តរាគមន៍ និងផ្តល់សេវាឆ្លើយតបជាពហុវិស័យប្រទាក់ក្រឡានិងស៊ីចង្វាក់គ្នាមានប្រសិទ្ធភាព គុណភាព និងបានទាន់ពេលវេលា។ |
| លទ្ធផលរយៈពេលវែង : | កុមារគ្រប់រូបទទួលបានសិទ្ធិរួមទាំងសិទ្ធិក្នុងបរិយាកាសឌីជីថល ក្នុងការអភិវឌ្ឍរាងកាយ សតិបញ្ញាស្មារតី និងសិទ្ធិការពារពីគ្រប់ទម្រង់នៃអំពើហិង្សាដើម្បីក្លាយជាមូលធនមនុស្សសម្រាប់ការអភិវឌ្ឍប្រទេសប្រកបដោយចីរភាព។ |
| សូចនាករលទ្ធផលចុងក្រោយទី១ : | ប្រេវ៉ាឡង់នៃអំពើហិង្សាលើរាងកាយ ផ្លូវចិត្ត ផ្លូវភេទ និងការមិនអើពើដែលកុមារជួបប្រទះត្រូវបានកាត់បន្ថយ និងឈានទៅលុបបំបាត់។ |
| សូចនាករលទ្ធផលចុងក្រោយទី២ : | ភាគរយនៃពលរដ្ឋកម្ពុជាដែលមិនគាំទ្ររាល់ទម្រង់នៃអំពើហិង្សាលើកុមារក្នុងគ្រប់បរិបទទាំងអស់(ខ្នងផ្ទះ សាលារៀន សហគមន៍ កន្លែងធ្វើការ សហគ្រាសគ្រឹះស្ថាន និងកន្លែងថែទាំកុមារ)មានការកើនឡើង។ |

| | |
|---|---|
| **យុទ្ធសាស្ត្រទី១ :** | **ការសម្របសម្រួលនិងកិច្ចសហប្រតិបត្តិការ** |
| គោលបំណង : | ពង្រឹងសមត្ថភាពយន្តការកិច្ចការពារកុមារទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីសម្របសម្រួល និងបង្កើនកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌស្ថាប័នពហុវិស័យសម្រាប់ការទប់ស្កាត់បឋម និងយុទ្ធសាស្ត្រឆ្លើយតបជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ សំដៅកំណត់គោលដៅលើតួអង្គសំខាន់ៗ និងកំណត់ឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាន។ |
| លទ្ធផលរំពឹងទុក | ក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថភាពក្នុងការសម្របសម្រួល និងសហប្រតិបត្តិការដោះស្រាយករណីអំពើហិង្សាលើកុមារនិងកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ។ |
| សូចនាករលទ្ធផលទី១ក : | ភាគរយនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិបានបញ្ចូលសកម្មភាពនិងសូចនាករ ដូចមានចែងនៅក្នុងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ទៅក្នុងផែនការយុទ្ធសាស្ត្រថវិកា ផែនការថវិកា និងផែនការសកម្មភាពប្រចាំឆ្នាំរបស់ខ្លួន។ |
| សូចនាករលទ្ធផលទី១ខ : | ភាគរយនៃកញ្ចប់ថវិការដ្ឋ ត្រូវបានក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិវិភាជសម្រាប់គាំទ្រសកម្មភាព និងសូចនាករដូចមានចែងនៅក្នុងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារមានការកើនឡើង។ |

**ចង្កោមសកម្មភាពនិងសកម្មភាពអនុវត្ត**

| ចង្កោមសកម្មភាព | | សូចនាករ លទ្ធផលក្នុងឆ្នាំ | | សកម្មភាពអនុវត្ត | | ស្ថាប័នទទួលខុសត្រូវ | ពេលវេលា 2025-2030 1 | 2 | 3 | 4 | 5 | 6 | ប្រភពធនធាន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១.១ | ពង្រឹងយន្តការសម្របសម្រួលអនុវត្តផែនការសកម្មភាពជាតិទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ | ១.១ក | ចំនួនយន្តការសម្របសម្រួលកិច្ចការពារកុមារពាក់ព័ន្ធថ្នាក់ជាតិត្រូវបានពង្រឹងសមត្ថភាព | ១.១.១ | ពង្រឹងសមត្ថភាព ក.ជ.ក. និងអគ្គលេខាធិការដ្ឋាននៃ ក.ជ.ក. ទទួលបន្ទុកសម្របសម្រួលអនុវត្តផែនការសកម្មភាពជាតិនៅថ្នាក់ជាតិ | CNCC | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |

| ចង្កោមសកម្មភាព | សូចនាករ លទ្ធផលក្នុងឆ្នាំ | | សកម្មភាពអនុវត្ត | | ស្ថាប័នទទួលខុសត្រូវ | ពេលវេលា 2025-2030 1 | 2 | 3 | 4 | 5 | 6 | ប្រភពធនធាន |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ១.១.២ | ពង្រឹងសមត្ថភាពគណៈកម្មាធិការពាក់ព័ន្ធដែលដឹកនាំ និងសម្របសម្រួលដោយក្រសួង ស្ថាប័នក្នុងការសម្របសម្រួលកិច្ចការពារកុមាររួមទាំងទិដ្ឋភាពនៃពលកម្មកុមារ | CNCC NCCL ក្រសួង ស្ថាប័នពាក់ព័ន្ធ | X | X | X | | | | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | ១.១.៣ | ជំរុញក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិបង្កើនធនធានគាំទ្រសកម្មភាព និងសូចនាករដែលបានស្នើឡើងក្នុងផែនការសកម្មភាពជាតិ | CNCC ក្រសួង ស្ថាប័នពាក់ព័ន្ធ | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | ១.១.៤ | ពិនិត្យកែសម្រួលថ្នាក់ដឹកនាំជាន់ខ្ពស់ទទួលបន្ទុកសិទ្ធិកុមារ។ | CNCC | X | X | | | | | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | ១.១ខ | ចំនួនយន្តការកិច្ចការពារកុមារថ្នាក់ក្រោមជាតិត្រូវបានពង្រឹងសមត្ថភាព | ១.១.៥ | ពង្រឹងសមត្ថភាព ក.ជ.ក. រាជធានី និងលេខាធិការដ្ឋាន | CNCC | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | ១.១.៦ | ពង្រឹងសមត្ថភាពយន្តការសម្របសម្រួលកិច្ចការពារកុមារពាក់ព័ន្ធថ្នាក់ក្រោមជាតិ | CNCC NCCL រដ្ឋបាលរាជធានី ខេត្ត | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | ១.១.៧ | ពង្រឹងសមត្ថភាពក្រុមការងារកិច្ចការពារកុមាររាជធានី ខេត្ត ក្នុងការសម្របសម្រួលអន្តរាគមន៍ករណីអំពើហិង្សាលើកុមារ | រដ្ឋបាលរាជធានី ខេត្ត | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | ១.១.៨ | ពង្រឹងសមត្ថភាព គ.ក.ស.ក. រាជធានី ខេត្ត និង គ.ក.ស.ក. | រដ្ឋបាលរាជធានី ខេត្ត | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |

| ចង្កោមសកម្មភាព | | សូចនាករ លទ្ធផលក្នុងឆ្នាំ | | សកម្មភាពអនុវត្ត | | ស្ថាប័នទទួលខុសត្រូវ | ពេលវេលា 2025-2030 1 | 2 | 3 | 4 | 5 | 6 | ប្រភពធនធាន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ក្រុង ស្រុក ខណ្ឌ សម្របសម្រួលលើការងារគ្រប់គ្រងករណីអំពើហិង្សាលើកុមារ | | | | | | | | |
| | | | | ១.១.៩ | ពង្រឹងសមត្ថភាពរបស់ គ.ក.ន.ក. ឃុំ សង្កាត់ ក្នុងការបង្ការទប់ស្កាត់និងឆ្លើយតបចំពោះករណីអំពើហិង្សាលើកុមារ | រដ្ឋបាលឃុំ សង្កាត់ | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ១.១.១០ | ជំរុញឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិបង្កើនធនធានប្រចាំឆ្នាំដើម្បីផ្តល់សេវាបង្ការទប់ស្កាត់និងឆ្លើយតបករណីអំពើហិង្សាលើកុមារ។ | MoI | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| ១.២ | ពង្រឹងនិងពង្រីកយន្តការកិច្ចការពារកុមារនៅតាមសាលារៀនរដ្ឋនិងឯកជន | ១.២ក | ចំនួនគណៈកម្មការទទួលបន្ទុកកិច្ចការពារកុមារត្រូវបានពង្រឹងសមត្ថភាពសម្របសម្រួលការអនុវត្តផែនការសកម្មភាពស្តីពីកិច្ចការពារកុមារតាមសាលារៀន | ១.២.១ | ប្រមូលទិន្នន័យដើមគ្រាក្នុងការអនុវត្តផែនការសកម្មភាពកិច្ចការពារកុមារនៅសាលារៀន ២០២៤-២០២៨(Baseline) ពីសាលាបឋមសិក្សាទូទាំងប្រទេស | MoEYS | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ១.២.២ | រៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីការបង្ការទប់ស្កាត់និងឆ្លើយតបកិច្ចការពារកុមារនៅកម្ពុជា | MoEYS | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ១.២.៣ | ពិនិត្យការគាំទ្រ និងសម្របសម្រួលការអនុវត្តគោលនយោបាយកិច្ចការពារកុមារ និងការអនុវត្តវិន័យបែបវិជ្ជមានរបស់សាលា។ | MoEYS | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |

| ចង្កោមសកម្មភាព | | សូចនាករលទ្ធផលក្នុងឆ្នាំ | | សកម្មភាពអនុវត្ត | | ស្ថាប័នទទួលខុសត្រូវ | 1 | 2 | 3 | 4 | 5 | 6 | ប្រភពធនធាន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១.២ខ | ចំនួនជនបង្គោលកិច្ចការពារកុមារនៅតាមសាលារៀននិងអ្នកពាក់ព័ន្ធដែលបានចូលរួមអនុវត្តផែនការសកម្មភាពស្តីពីកិច្ចការពារកុមារតាមសាលារៀន | ១.២.៤ | ផ្សព្វផ្សាយឯកសារណែនាំដល់ជនបង្គោលសម្រាប់កិច្ចការពារកុមារដើម្បីសកម្មភាពការងារឆ្លើយតប និងធ្វើរបាយការណ៍ដល់លេខាធិការដ្ឋាន ពីថ្នាក់នាយកដ្ឋាន មន្ទីរអប់រំ ការិយាល័យអប់រំស្រុក និងសាលារៀន | MoEYS | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ១.២.៥ | ផ្តល់វគ្គបំប៉នទាក់ទងនឹងការការពារកុមារ ការអប់រំបែបវិជ្ជមាន និងការគ្រប់គ្រងថ្នាក់រៀនសម្រាប់មន្ទីរអប់រំ ការិយាល័យអប់រំស្រុក គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន។ | MoEYS | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| ១.៣ | ពង្រឹងបណ្តាញយុវជន និងកុមារចូលរួមសម្របសម្រួលក្នុងការទប់ស្កាត់អំពើហិង្សាលើកុមារ | ១.៣ក | ចំនួនបណ្តាញយុវជនត្រូវបានពង្រឹងសមត្ថភាព និងលើកទឹកចិត្តចូលរួមបង្ការទប់ស្កាត់អំពើហិង្សាលើកុមារ | ១.៣.១ | ផ្សព្វផ្សាយអំពីផែនការសកម្មភាពជាតិដល់យុវជនដែលជាសមាជិកបណ្តាញយុវជន | CNCC<br>MoSVY | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ១.៣.២ | បណ្តុះបណ្តាលសមាជិកបណ្តាញយុវជនចូលរួមសម្របសម្រួល និងទប់ស្កាត់អំពើហិង្សាលើកុមារ | CNCC<br>MoSVY | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | ១.៣ខ | ចំនួនបណ្តាញកុមារត្រូវបានពង្រឹងសមត្ថភាព និងលើកទឹកចិត្តចូលរួមបង្ការទប់ស្កាត់អំពើហិង្សាលើកុមារ | ១.៣.៣ | ផ្សព្វផ្សាយអំពីផែនការសកម្មភាពជាតិដល់កុមារដែលជាសមាជិកបណ្តាញកុមារ។ | CNCC<br>MoSVY | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ១.៣.៤ | បណ្តុះបណ្តាលសមាជិកកុមារចូលរួមបង្ការទប់ស្កាត់អំពើហិង្សាលើកុមារ។ | CNCC<br>MoSVY | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |

| | |
|---|---|
| **យុទ្ធសាស្ត្រទី២ :** | **ការបង្ការនិងទប់ស្កាត់** |
| គោលបំណង : | ដើម្បីកាត់បន្ថយអំពើហិង្សាលើកុមារនៅតាមខ្នងផ្ទះ សាលារៀន សហគមន៍ កន្លែងធ្វើការ សហគ្រាស គ្រឹះស្ថាន កន្លែងថែទាំកុមារ និងក្នុងប្រព័ន្ធផ្សព្វផ្សាយ តាមរយៈយុទ្ធសាស្ត្រទប់ស្កាត់បឋម ដែលមានការសម្របសម្រួលជាពហុវិស័យជាមួយក្រសួង និងស្ថាប័ននានា សំដៅកំណត់គោលដៅគួអង្គ និងវិស័យសំខាន់ៗ ដើម្បីឱ្យមានការផ្លាស់ប្តូរឥរិយាបថប្រព្រឹត្តលើកុមារជាវិជ្ជមាន។ |
| លទ្ធផលរំពឹងទុក : | ករណីអំពើហិង្សាលើកុមារនិងកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញត្រូវបានកាត់បន្ថយ។ |
| សូចនាករលទ្ធផលទី២ក : | ភាគរយនៃប្រជាជននៅតាមសហគមន៍ មានការផ្លាស់ប្តូរឥរិយាបថប្រព្រឹត្តអំពើហិង្សាលើកុមារ។ |
| សូចនាករលទ្ធផលទី២ខ : | ភាគរយនៃអំពើហិង្សាលើកុមារនៅតាមខ្នងផ្ទះ សាលារៀន សហគមន៍ កន្លែងធ្វើការ សហគ្រាស គ្រឹះស្ថាន និងកន្លែងថែទាំកុមារ ត្រូវបានបង្ការនិងទប់ស្កាត់។ |
| សូចនាករលទ្ធផលទី២គ : | ភាគរយនៃការយល់ដឹងអំពីការប្រើប្រាស់អ៊ីនធឺណិតប្រកបដោយសុវត្ថិភាព និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ(OCSE)។ |

**ចង្កោមសកម្មភាពនិងសកម្មភាពអនុវត្ត**

| ចង្កោមសកម្មភាព | | សូចនាករលទ្ធផលក្នុងឆ្នាំ | | សកម្មភាពអនុវត្ត | | ស្ថាប័នទទួលខុសត្រូវ | ពេលវេលា 2025-2030 1 | 2 | 3 | 4 | 5 | 6 | ប្រភពធនធាន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២.១ | បង្កើនការផ្សព្វផ្សាយអំពីការទប់ស្កាត់អំពើហិង្សាលើកុមារ និងការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ(OCSE) | ២.១ក | ចំនួនអង្គភាពសារព័ត៌មានដែលចូលរួមផ្សព្វផ្សាយ និងលើកកម្ពស់ការទប់ស្កាត់អំពើហិង្សាលើកុមារ និងផ្លាស់ប្តូរឥរិយាបថបុគ្គលបទដ្ឋានយេនឌ័រនិងសង្គម | ២.១.១ | លើកទឹកចិត្តអង្គភាពសារព័ត៌មានចូលរួមផ្សព្វផ្សាយអំពីផ្លាស់ប្តូរឥរិយាបថបុគ្គលបទដ្ឋានយេនឌ័រនិងសង្គម | MoINF | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ២.១.២ | បណ្តុះបណ្តាលអ្នកសារព័ត៌មានអំពីកិច្ចការពារកុមារ និងក្រមសីលធម៌ក្នុងការផ្សាយរូបភាពកុមាររងគ្រោះជាសាធារណៈ | MoINF<br>MoWA<br>CNCW | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | ២.១ខ | ចំនួនកុមារ យុវជន ឪពុកម្តាយ អ្នកថែទាំកុមារ គ្រូបង្រៀន មន្ត្រីអនុវត្តច្បាប់ អ្នករៀបចំគោលនយោបាយ និងសាធារណជនទទួលបានចំណេះដឹងអំពីការប្រើអ៊ីនធឺណិតប្រកបដោយសុវត្ថិភាព | ២.១.៣ | លើកកម្ពស់អក្ខរកម្មឌីជីថល និងការយល់ដឹងអំពីការប្រើប្រាស់អ៊ីនធឺណិតទាក់ទងនឹងហានិភ័យ វិធានសុវត្ថិភាព ឯកជនភាព និងរបៀបរាយការណ៍និងស្វែងរកជំនួយទៅដល់សាធារណជន | CNCC<br>MPTC<br>MoINF | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |

| ចង្កោមសកម្មភាព | សូចនាករ លទ្ធផលក្នុងឆ្នាំ | សកម្មភាពអនុវត្ត | | ស្ថាប័នទទួលខុសត្រូវ | ពេលវេលា 2025-2030 1 | 2 | 3 | 4 | 5 | 6 | ប្រភពធនធាន |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ២.១.៤ | យុទ្ធនាការប្រព័ន្ធផ្សព្វផ្សាយសង្គមដើម្បីផ្លាស់ប្តូរបទដ្ឋានសង្គមនិងយេនឌ័រដែលទាក់ទងនឹងហានិភ័យនៃ (OCSE) | CNCC<br>MoSVY<br>MoINF<br>MoWA<br>CNCW | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | ២.១.៥ | បង្កើតកម្មវិធីផ្សព្វផ្សាយ និងបញ្ច្រាបការយល់ដឹងអំពីបទល្មើសនិងគ្រោះថ្នាក់ពាក់ព័ន្ធនឹង(OCSE) នៅទីប្រជុំជននិងជនបទ ពិសេសនៅតំបន់ជនជាតិភាគតិច | CNCC<br>MoSVY<br>MoINF | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | ២.១.៦ | ពង្រឹងសមត្ថភាពមន្ត្រីទទួលបន្ទុកក្នុងកិច្ចការពារកុមារលើការបង្ការនិងការទប់ស្កាត់រាល់ទម្រង់នៃការជួញដូរកុមារថ្នាក់ជាតិនិងក្រោមជាតិ | NCCT<br>CNCC | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | ២.១.៧ | ផលិតសម្ភារៈអប់រំផ្សព្វផ្សាយបង្ការទប់ស្កាត់(វីដេអូ-រូបភាព) អំពីសម្ភារៈរំលោភបំពានផ្លូវភេទកុមារលើអនឡាញ និងទម្រង់ផ្សេងទៀតនៃ(OCSE) | CNCC<br>MoSVY<br>MoLVT | X | X | X | | | | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | ២.១.៨ | បង្កើតកម្មវិធីអប់រំឪពុកម្តាយ | CNCC<br>MoSVY | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |

| ចង្កោមសកម្មភាព | | សូចនាករលទ្ធផលក្នុងឆ្នាំ | | សកម្មភាពអនុវត្ត | | ស្ថាប័នទទួលខុសត្រូវ | ពេលវេលា 2025-2030 1 | 2 | 3 | 4 | 5 | 6 | ប្រភពធនធាន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | អ្នកថែទាំកុមារ លោកគ្រូ អ្នកគ្រូឱ្យយល់ដឹងពីការប្រើអ៊ីនធឺណិតដែលនឹងភ្ជាប់ទំនាក់ទំនងកុមារ និងយុវជននឹងប្រព័ន្ធអនឡាញ ឬពិភពនិម្មិត | | | | | | | | |
| | | | | ២.១.៩ | រៀបចំយុទ្ធនាការផ្សព្វផ្សាយតាមទូរទស្សន៍ ឬបណ្តាញសង្គម ឱ្យកុមារ និងយុវជន រួមទាំងសាធារណជនអំពីគ្រោះថ្នាក់នៃការប្រើអ៊ីនធឺណិត និងវិធីបង្ការទប់ស្កាត់ហានិភ័យ។ | CNCC<br>MoSVY<br>MoWA<br>CNCW | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| ២.២ | បង្កើនការវិនិយោគលើកម្មវិធីការពារកុមារនិងអំពីការប្រើអ៊ីនធឺណិតប្រកបដោយសុវត្ថិភាពទៅក្នុងកម្មវិធីវិនិយោគខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ | ២.២ក | ចំនួនរដ្ឋបាលឃុំ សង្កាត់ ដែលបានបង្កើនកញ្ចប់ថវិកាអនុវត្តកម្មវិធីកិច្ចការពារកុមារនិងការប្រើអ៊ីនធឺណិតប្រកបដោយសុវត្ថិភាព | ២.២.១ | បង្កើនការផ្សព្វផ្សាយប្រកាសលេខ ៣៨៤០ ប្រក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ និងគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព | MoI | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ២.២.២ | បណ្តុះបណ្តាល គ.ក.ន.ក. និងអ.ក.ន.ក. (អ្នកសង្គមកិច្ចបឋម)ស្តីពីការអនុវត្តៈ | MoI | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |

| ចង្កោមសកម្មភាព | | សូចនាករលទ្ធផលក្នុងឆ្នាំ | | សកម្មភាពអនុវត្ត | ស្ថាប័នទទួលខុសត្រូវ | ពេលវេលា 2025-2030 1 | 2 | 3 | 4 | 5 | 6 | ប្រភពធនធាន |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | - សៀវភៅណែនាំស្ដីពីកិច្ចការពារកុមារសម្រាប់ឃុំ សង្កាត់<br>- សៀវភៅណែនាំស្ដីពីការអនុវត្តសកម្មភាពសេវាសង្គមឃុំ សង្កាត់<br>- មាត្រា៧នៃអនុក្រឹត្យលេខ៣៤ ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៧ ប្រគល់មុខងារ «ការគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះនិងងាយរងគ្រោះនៅសហគមន៍» | | | | | | | | |
| | | | ២.២.៣ | វិភាជថវិកាគាំទ្រ អ.ក.ន.ក. អនុវត្តសៀវភៅណែនាំ និងមាត្រា៧នៃអនុក្រឹត្យលេខ៣៤ និងគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព។ | រដ្ឋបាលឃុំ សង្កាត់ | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | ២.២ខ | ចំនួនរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលបានបង្កើនកញ្ចប់ថវិកាអនុវត្តដំណើរការគ្រប់គ្រងករណីកុមាររងគ្រោះដោយអំពើហិង្សាលើកុមារ និងកុមារមានពិការភាព | ២.២.៤ | បង្កើនការផ្សព្វផ្សាយមុខងារដែលបានប្រគល់ដូចមានចែងនៅក្នុងឧបសម្ព័ន្ធទី១និង៣ (ជ)វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | MoI | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |

| ចង្កោមសកម្មភាព | | សូចនាករ<br>លទ្ធផលក្នុងឆ្នាំ | | សកម្មភាពអនុវត្ត | | ស្ថាប័នទទួល<br>ខុសត្រូវ | ពេលវេលា 2025-2030<br>1 | 2 | 3 | 4 | 5 | 6 | ប្រភព<br>ធនធាន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | នៃអនុក្រឹត្យលេខ១៨២ ១៨៣ និង១៨៤ និងគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព | | | | | | | | |
| | | | | ២.២.៥ | បណ្ដុះបណ្ដាលមន្ត្រីទទួលបន្ទុកការងារសង្គមកិច្ច(អ្នកសង្គមអាជីពរង)អ្នកកាន់ករណីស្ដីពីការអនុវត្តៈ<br>- សៀវភៅណែនាំស្ដីពីការអនុវត្តមុខងារនៃវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- សៀវភៅណែនាំស្ដីពីនីតិវិធីប្រតិបត្តិការកិច្ចការពារកុមារសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។ | MoI<br>MoSVY | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ២.២.៦ | រៀបចំថវិកាគាំទ្រមន្ត្រីទទួលបន្ទុកការងារសង្គមកិច្ចអនុវត្តសៀវភៅណែនាំស្ដីពីការអនុវត្តមុខងារ និងសៀវភៅណែនាំស្ដីពីនីតិវិធីប្រតិបត្តិការកិច្ចការពារកុមារ។ | រដ្ឋបាលក្រុង ស្រុក ខណ្ឌ | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| ២.៣ | បង្កើនការផ្សព្វផ្សាយការទប់ស្កាត់អំពើហិង្សាលើ | ២.៣ក | ចំនួនកុមារនិងកុមារមានពិការភាពនៅតាមខ្នងផ្ទះ សាលារៀន | ២.៣.១ | បង្កើនការបណ្ដុះបណ្ដាល | MoSVY<br>MoWA | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |

| ចង្កោមសកម្មភាព | សូចនាករ<br>លទ្ធផលក្នុងឆ្នាំ | | សកម្មភាពអនុវត្ត | ស្ថាប័នទទួល<br>ខុសត្រូវ | ពេលវេលា 2025-2030<br>1 | 2 | 3 | 4 | 5 | 6 | ប្រភព<br>ធនធាន |
|---|---|---|---|---|---|---|---|---|---|---|---|
| កុមារ ទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារ ដោយមិនចាំបាច់ និងទប់ស្កាត់ការកេងប្រវ័ញ្ចលើកុមារនៅតាមខ្នងផ្ទះ សាលារៀន សហគមន៍ កន្លែងធ្វើការ សហគ្រាស គ្រឹះស្ថាន និងកន្លែងថែទាំកុមារ | សហគមន៍ កន្លែងធ្វើការ សហគ្រាស គ្រឹះស្ថាន និងកន្លែងថែទាំកុមារដែលទទួលបានសេវាការពារពីអំពើហិង្សា | | និងជំរុញការផ្សព្វផ្សាយដល់សហគមន៍ស្តីពីការចិញ្ចឹមកូនបែបវិជ្ជមាន | CNCW | | | | | | | |
| | | ២.៣.២ | រៀបចំនិងអនុវត្តយុទ្ធនាការគ្រួសាររឹងមាំដើម្បីបញ្ចប់អំពើហិង្សាលើកុមារ និងទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់នៅកម្ពុជាជំហានទី២(២០២៥-២០៣០) | MoSVY | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | ២.៣.៣ | រៀបចំនិងអនុវត្តឯកសារបណ្តុះបណ្តាលការថែរក្សាកុមារក្នុងគ្រួសារ( Gatekeeping )ដើម្បីទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់ | MoSVY | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | ២.៣.៤ | កំណត់អត្តសញ្ញាណជនរងគ្រោះនិងបញ្ជូនបន្តទៅរកសេវាសង្គមផ្សេងៗ ដែលចាំបាច់សម្រាប់គ្រួសារ និងកុមារដែលស្របតាមកម្មវិធីផ្ទេរសាច់ប្រាក់ | MoSVY | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | ២.៣.៥ | បង្កើតនិងអនុវត្តក្របខ័ណ្ឌការងារជាក់លាក់សម្រាប់យន្តការកិច្ចការពារកុមារតាម | MoI<br>MoSVY | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |

| ចង្កោមសកម្មភាព | សូចនាករលទ្ធផលក្នុងឆ្នាំ | | សកម្មភាពអនុវត្ត | ស្ថាប័នទទួលខុសត្រូវ | ពេលវេលា 2025-2030 1 | 2 | 3 | 4 | 5 | 6 | ប្រភពធនធាន |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | សហគមន៍(CBCPMs) សម្រាប់ទប់ស្កាត់និងការពារឱ្យបានមុនបញ្ហាកិច្ចការពារកុមារកើតឡើង | | | | | | | | |
| | | ២.៣.៦ | អប់រំផ្សព្វផ្សាយអំពីការបង្ការនិងការពារកុមារពីអំពើហិង្សា ការរំលោភបំពានគ្រប់រូបភាព រួមទាំងតាមប្រព័ន្ធអនឡាញ ដល់អ្នកស្ម័គ្រចិត្តតាមកន្លែងថែទាំ វិស័យឯកជន ភ្នាក់ងារទេសចរណ៍ និងអ្នកពាក់ព័ន្ធ | MoSVY | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | ២.៣.៧ | ផ្សព្វផ្សាយការពារពីគ្រប់ទម្រង់នៃអំពើហិង្សា ការរំលោភបំពាន ការកេងប្រវ័ញ្ច និងហិង្សានៅលើអ៊ីនធឺណិតនិងក្រៅបណ្ដាញអ៊ីនធឺណិត និងយន្តការរាយការណ៍ និងស្វែងរកជំនួយប្រចាំឆ្នាំដល់សិស្សនៅតាមសាលារៀន | MoEYS | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | ២.៣.៨ | រៀបចំយុទ្ធនាការផ្សព្វផ្សាយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិស្ដីពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ | MoLVT | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |

| ចង្កោមសកម្មភាព | សូចនាករលទ្ធផលក្នុងឆ្នាំ | | សកម្មភាពអនុវត្ត | ស្ថាប័នទទួលខុសត្រូវ | ពេលវេលា 2025-2030 1 | 2 | 3 | 4 | 5 | 6 | ប្រភពធនធាន |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | និងលើកកម្ពស់ការយល់ដឹងស្ដីពីការទប់ស្កាត់អំពើហិង្សានិងការបៀតបៀនផ្លូវភេទនៅកន្លែងការងារ | | | | | | | | |
| | | ២.៣.៩ | ការលើកកម្ពស់សមភាពយេនឌ័រ សហគមន៍សុខសាន្ត ទារកដ្ឋាន និងកន្លែងទុកដាក់ក្មេង ដើម្បីទប់ស្កាត់អំពើហិង្សានិងបង្កើនផលិតភាពការងារ ដោយផ្ដោតជាពិសេសកម្មករនិយោជិតវ័យក្មេងនិងកុមារតូច | MoLVT | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | ២.៣.១០ | ពង្រឹងសមត្ថភាពជនបង្គោលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងជនបង្គោលតាមសហគមន៍ស្ដីពីការលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ | MoLVT | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | ២.៣.១១ | បង្កើនការបណ្ដុះបណ្ដាលព្រះសង្ឃ អាចារ្យ គណៈកម្មការ តាជី ដូនជី ក្មេងវត្ត និងយុវជនស្នាក់នៅក្នុងវត្តស្ដីពីគោលនយោបាយវត្តសង្គហកុមារ។ | MoCAR | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |

| | |
|---|---|
| **យុទ្ធសាស្ត្រទី៣ :** | **សេវាឆ្លើយតបជាពហុវិស័យចំពោះកិច្ចការពារកុមារ** |
| **គោលបំណង :** | **ការផ្តល់សេវាអន្តរាគមន៍ សេវាឆ្លើយតប និងសេវាសង្គមចំពោះអំពើហិង្សាលើកុមារនិងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ។** |
| **លទ្ធផលរំពឹងទុក :** | **កុមាររងគ្រោះនិងងាយរងគ្រោះដោយអំពើហិង្សា និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញទទួលបានសេវាឆ្លើយតបជាពហុវិស័យប្រកបដោយគុណភាព។** |
| សូចនាករលទ្ធផលទី៣ក : | ភាគរយនៃការរាយការណ៍ករណីអំពើហិង្សាលើកុមារនិងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញទទួលបានសេវាគ្រប់គ្រងករណីដោយអ្នកសង្គមអាជីពរងនៃកម្លាំងសេវាសង្គម។ |
| សូចនាករលទ្ធផលទី៣ខ : | ភាគរយនៃកុមារដែលរងគ្រោះដោយអំពើហិង្សានិងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញទទួលបានសេវាសង្គមប្រកបដោយគុណភាព។ |
| សូចនាករលទ្ធផលទី៣គ : | ភាគរយនៃកុមាររងគ្រោះដោយអំពើហិង្សានិងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញត្រូវបានបិទករណី។ |

**ចង្កោមសកម្មភាពនិងសកម្មភាពអនុវត្ត**

| ចង្កោមសកម្មភាព | | សូចនាករ លទ្ធផលក្នុងឆ្នាំ | | សកម្មភាពអនុវត្ត | | ស្ថាប័នទទួលខុសត្រូវ | ពេលវេលា 2025-2030 1 | 2 | 3 | 4 | 5 | 6 | ប្រភពធនធាន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៣.១ | ពង្រឹងប្រព័ន្ធរាយការណ៍អំពើហិង្សាលើកុមារ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ(OCSE) | ៣.១ក | ចំនួនកុមារដែលជួបប្រទះអំពើហិង្សា ការរំលោភបំពាន ការកេងប្រវ័ញ្ច និងការមិនអើពើ ដែលត្រូវបានផ្តល់សេវាដោយកម្លាំងសេវាសង្គមប្រកបដោយវិជ្ជាជីវៈ | ៣.១.១ | បង្កើនការបណ្តុះបណ្តាលដល់ប្រធានភូមិ និងអ្នកពាក់ព័ន្ធស្តីពីការទទួលរបាយការណ៍សង្ស័យករណីអំពើហិង្សាលើកុមារ និងការកំណត់ខ្លួនផ្ទះមានអំពើហិង្សាលើកុមារ និងរាយការណ៍ករណីជូន អ.ក.ន.ក. ឃុំ សង្កាត់ | MoI | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ៣.១.២ | បង្កើនការបណ្តុះបណ្តាលដល់ អ.ក.ន.ក.ស្តីពីការកត់ត្រាព័ត៌មានករណីអំពើហិង្សាលើកុមារ និងធ្វើការប៉ាន់ប្រមាណបឋម | MoI<br>MoSVY | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |

| | ចង្កោមសកម្មភាព | | សូចនាករលទ្ធផលក្នុងឆ្នាំ | | សកម្មភាពអនុវត្ត | ស្ថាប័នទទួលខុសត្រូវ | ពេលវេលា 2025-2030 1 | 2 | 3 | 4 | 5 | 6 | ប្រភពធនធាន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ៣.១.៣ | ផ្សព្វផ្សាយបណ្តាញទូរសព្ទ ១២៨៨ នគរបាលជាតិ និង នគរបាលថ្នាក់ក្រោមជាតិ និង ទូរសព្ទជំនួយកុមារ ១២៨០ | រដ្ឋបាល ឃុំ សង្កាត់ | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ៣.១.៤ | បង្កើតនិងសម្របសម្រួលបណ្តាញទូរសព្ទជំនួយកុមារ Child Hotline ឬChild Helpline | MoSVY MoWA CNCW | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ៣.១.៥ | អនុវត្តផែនការមេស្តីពីការបណ្តុះបណ្តាលកម្លាំងសេវាសង្គម | MoSVY | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ៣.១.៦ | ការអនុម័តនិងដាក់ឱ្យអនុវត្តក្របខ័ណ្ឌគ្រប់គ្រងករណីជាតិ | MoSVY | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ៣.១.៧ | អនុវត្តផែនការយុទ្ធសាស្ត្រស្តីពីកម្លាំងសេវាសង្គមនៅកម្ពុជា ២០២២-២០៣១ | MoSVY | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ៣.១.៨ | ពង្រឹងការអនុវត្តសៀវភៅណែនាំស្តីពីនីតិវិធីប្រតិបត្តិកិច្ចការពារកុមារ(CP-SOP)។ | MoSVY MoI | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | ៣.១ខ | ចំនួនករណីកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ (OCSE) ត្រូវបានកត់ត្រានិងវាយតម្លៃដោយអង្គភាពជំនាញ | ៣.១.៩ | ផ្សព្វផ្សាយគោលការណ៍ណែនាំនិងវិធានការទប់ស្កាត់មាតិកា ខុសច្បាប់ពាក់ព័ន្ធនឹង CSAM បង្ហាញលើអ៊ីនធឺណិត ឬបណ្តាញសង្គមដែលប៉ះពាល់ | CNCC MoINF MoSVY MoI | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |

| ចង្កោមសកម្មភាព | សូចនាករលទ្ធផលក្នុងឆ្នាំ | សកម្មភាពអនុវត្ត | | ស្ថាប័នទទួលខុសត្រូវ | ពេលវេលា 2025-2030 | | | | | | ប្រភពធនធាន |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | 1 | 2 | 3 | 4 | 5 | 6 | |
| | | | ដល់សីលធម៌ ប្រពៃណីជាតិ សាសនា និងសុវត្ថិភាពកុមារ | | | | | | | | |
| | | ៣.១.១០ | ផ្សព្វផ្សាយនិងជំរុញការអនុវត្ត គោលការណ៍ណែនាំស្ដីពី កិច្ចការពារកុមារលើប្រព័ន្ធ អនឡាញសម្រាប់ក្រុមហ៊ុន បច្ចេកវិទ្យាឌីជីថលនៅកម្ពុជា | MPTC | X | X | X | X | X | X | ថវិការដ្ឋនិង ដៃគូអភិវឌ្ឍ |
| | | ៣.១.១១ | ផ្សព្វផ្សាយ និងពង្រឹងប្រព័ន្ធ រាយការណ៍បន្ទាន់តាមអ៊ីនធឺណិត (Internet Hotlines) សម្រាប់ CSAM និងករណីផ្សេងទៀត នៃ OCSE ដល់សាធារណជន | MPTC អគ្គស្នងការដ្ឋាន នគរបាលជាតិ | X | X | X | X | X | X | ថវិការដ្ឋនិង ដៃគូអភិវឌ្ឍ |
| | | ៣.១.១២ | ផ្សព្វផ្សាយក្រមសីលធម៌ សម្រាប់កិច្ចការពារកុមារដល់ អ្នកសារព័ត៌មាន និងអ្នកពាក់ ព័ន្ធដែលធ្វើការងារជាមួយ កុមារ | CNCC | X | X | X | X | X | X | ថវិការដ្ឋនិង ដៃគូអភិវឌ្ឍ |
| | | ៣.១.១៣ | លើកកម្ពស់ការចូលរួមរបស់ កុមារនិងយុវជននៅក្នុងដំណើរ ការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រនិងផែនការសកម្ម ភាពដើម្បីបង្ការទប់ស្កាត់ និង ឆ្លើយតប(OCSE)។ | CNCC | X | X | X | X | X | X | ថវិការដ្ឋនិង ដៃគូអភិវឌ្ឍ |

| ចង្កោមសកម្មភាព | | សូចនាករ<br>លទ្ធផលក្នុងឆ្នាំ | | សកម្មភាពអនុវត្ត | | ស្ថាប័នទទួលខុសត្រូវ | ពេលវេលា 2025-2030<br>1 | 2 | 3 | 4 | 5 | 6 | ប្រភពធនធាន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៣.២ | ពង្រឹងប្រព័ន្ធអន្តរាគមន៍ចំពោះអំពើហិង្សាលើកុមារ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ(OCSE) | ៣.២ក | ចំនួនករណីអំពើហិង្សាលើកុមារត្រូវបានគ្រប់គ្រងករណីពីមន្ត្រីទទួលបន្ទុកការងារសង្គមកិច្ច | ៣.២.១ | គ្រប់គ្រង ធ្វើទំនើបកម្ម និងពង្រឹងការអនុវត្តប្រព័ន្ធគ្រប់គ្រងករណីកុមារតាមបច្ចេកវិទ្យា Primero និងប្រព័ន្ធពាក់ព័ន្ធ | MoSVY | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ៣.២.២ | ពង្រឹងសមត្ថភាពមន្ត្រីទទួលបន្ទុកការងារកិច្ចការពារកុមារ និងបុគ្គលិកសង្គម លើការងារគ្រប់គ្រងករណី និងស្វែងរកសេវាចាំបាច់សម្រាប់កុមារ | MoSVY | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ៣.២.៣ | បង្កើនកញ្ចប់ថវិកាគាំទ្រដំណើរការគ្រប់គ្រងករណីអំពើហិង្សាលើកុមារ។ | រដ្ឋបាលក្រុង ស្រុក ខណ្ឌ | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | ៣.២ខ | ចំនួនករណីការរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអនឡាញត្រូវឆ្លើយតបដោយអង្គភាពជំនាញ (OCSE) | ៣.២.៤ | ពង្រឹងនិងពង្រីកយន្តការប្រឆាំងបទល្មើសបច្ចេកវិទ្យាព័ត៌មានដែលមានស្រាប់នៅថ្នាក់ក្រោមជាតិដើម្បីបង្ការទប់ស្កាត់ និងឆ្លើយតបករណី(CSAM)បានទាន់ពេលវេលា | MoI | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ៣.២.៥ | ពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិប្រឆាំងបទល្មើសបច្ចេកវិទ្យាព័ត៌មាន ជាពិសេស (OCSE) | MoI | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |

| ចង្កោមសកម្មភាព | សូចនាករ លទ្ធផលក្នុងឆ្នាំ | | សកម្មភាពអនុវត្ត | ស្ថាប័នទទួល ខុសត្រូវ | ពេលវេលា 2025-2030 1 | 2 | 3 | 4 | 5 | 6 | ប្រភពធនធាន |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ៣.២.៦ | ជំរុញនិងលើកកម្ពស់ការអនុវត្តនីតិវិធីកុមារមេត្រីនៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ ដើម្បីការពារសិទ្ធិនិងឧត្តមប្រយោជន៍របស់កុមាររងគ្រោះ | MoI | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | ៣.២.៧ | បង្កើនធនធាននិងកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិនិងអន្តរជាតិពាក់ព័ន្ធក្នុងការឆ្លើយតបករណី OCSE | CNCC<br>MoI | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | ៣.២.៨ | ផ្សព្វផ្សាយដល់សិស្សថៅក្រមព្រះរាជអាជ្ញា ក្រឡាបញ្ជី និងក្រុមមេធាវីអំពីច្បាប់ប្រឆាំងបទល្មើសបច្ចេកវិទ្យាព័ត៌មាន និង(OCSE) | MoJ | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | ៣.២.៩ | បញ្ចូលប្រធានបទអំពីOCSE ទៅក្នុងកម្មវិធីបណ្តុះបណ្តាលដល់សិស្សមធ្យមវិចិត្រសិល្បៈ | MCFA | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | ៣.២.១០ | ពង្រឹងប្រព័ន្ធបណ្តាញទំនាក់ទំនងជាតិ និងអន្តរជាតិរវាងស្ថាប័នអនុវត្តច្បាប់លើការកំណត់អត្តសញ្ញាណជនរងគ្រោះ និងគ្រប់គ្រងជនល្មើសក្នុងករណី OCSE។ | MoI<br>MoSVY | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |

| | ចង្កោមសកម្មភាព | | សូចនាករលទ្ធផលក្នុងឆ្នាំ | | សកម្មភាពអនុវត្ត | ស្ថាប័នទទួលខុសត្រូវ | ពេលវេលា 2025-2030 1 | 2 | 3 | 4 | 5 | 6 | ប្រភពធនធាន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៣.៣ | ពង្រឹងប្រព័ន្ធឆ្លើយតបនិងផ្តល់សេវាដល់កុមាររងគ្រោះដោយអំពើហិង្សា និងការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ(OCSE) | ៣.៣ក | ចំនួនកុមាររងគ្រោះដោយអំពើហិង្សាដែលទទួលបានសេវាឆ្លើយតបនិងសេវាសង្គមពាក់ព័ន្ធ | ៣.៣.១ | បង្កើតស្តង់ដាសេវាជាតិសម្រាប់គាំទ្រដល់កុមារ និងគ្រួសាររបស់ពួកគេ | MoSVY | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ៣.៣.២ | ពង្រឹងគុណភាពនៃការផ្តល់សេវាថែទាំជំនួសចំពោះកុមារ និងលើកកម្ពស់ការថែទាំកុមារនៅតាមគ្រួសារនិងសហគមន៍ | MoSVY | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ៣.៣.៣ | លើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តសុំកូនក្នុងប្រទេស និងអន្តរប្រទេស | MoSVY | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ៣.៣.៤ | ការគ្រប់គ្រងករណីអនីតិជនក្រោយពេលធ្វើសមាហរណកម្ម | MoSVY | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ៣.៣.៥ | ការពង្រឹងនិងពង្រីកកម្មវិធីបង្វែរកុមារចេញពីប្រព័ន្ធតុលាការ | MoSVY | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ៣.៣.៦ | ផ្តល់សេវាស្តារលទ្ធភាពពលកម្មដល់កុមារមានពិការភាព | MoSVY | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ៣.៣.៧ | ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ | MoSVY | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ៣.៣.៨ | ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីជាតិជំនួយសង្គមផ្នែកបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស | MoSVY | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |

| ចង្កោមសកម្មភាព | សូចនាករ<br>លទ្ធផលក្នុងឆ្នាំ | | សកម្មភាពអនុវត្ត | | ស្ថាប័នទទួលខុសត្រូវ | ពេលវេលា 2025-2030<br>1 | 2 | 3 | 4 | 5 | 6 | ប្រភពធនធាន |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ៣.៣.៩ | ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីជាតិជំនួយសង្គមឆ្លើយតបនឹងគ្រោះអាសន្ន | MoSVY | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | ៣.៣.១០ | រៀបចំសេវាស្ពានចម្លងដល់គ្រួសារក្រីក្រ និងជនងាយរងគ្រោះ | MoSVY | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | ៣.៣.១២ | ផ្តល់សេវាសុខាភិបាល និងផ្តល់កញ្ចប់សុខាភិបាលដល់កុមាររងគ្រោះដោយអំពើហិង្សាលើកុមារ | MoH | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | ៣.៣.១២ | បង្កើតនិងដំណើរការបណ្តាញទូរសព្ទបន្ទាន់សម្រាប់ការពារកុមារ និងឆ្លើយតបគ្រប់ទម្រង់នៃអំពើហិង្សា ការរំលោភបំពាន ការកេងប្រវ័ញ្ច និងអំពើហិង្សាផ្អែកលើយេនឌ័រ ជាមួយអ្នកជំនាញដែលបានទទួលការបណ្តុះបណ្តាល ឬមានការបញ្ជាក់។ | MoEYS | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | ៣.៣ខ | ចំនួនកុមាររងគ្រោះដោយការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ (OCSE)ដែលទទួលបានសេវាឆ្លើយតបនិងសេវាសង្គមពាក់ព័ន្ធ | ៣.៣.១៣ | បង្កើនការបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់មន្ត្រីតុលាការ ចៅក្រម និងព្រះរាជអាជ្ញាស្តីពីការស៊ើបអង្កេត និង | MoJ | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |

| ចង្កោមសកម្មភាព | សូចនាករ លទ្ធផលក្នុងឆ្នាំ | | សកម្មភាពអនុវត្ត | ស្ថាប័នទទួលខុសត្រូវ | ពេលវេលា 2025-2030 1 | 2 | 3 | 4 | 5 | 6 | ប្រភពធនធាន |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ផ្តន្ទាទោសករណីOCSE និង វិធីសាស្ត្រធ្វើការជាមួយកុមាររងគ្រោះ និងគ្រួសារ | | | | | | | | |
| | | ៣.៣.១៤ | ផ្តល់កញ្ចប់សេវាគាំពារដល់កុមារនិងយុវជនរងគ្រោះដោយសារ(OCSE)ដែលចូលរួមក្នុងដំណើរការនីតិវិធីច្បាប់ | MoSVY<br>MoWA | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | ៣.៣.១៥ | ផ្តល់សេវាប្រឹក្សាយោបល់ ជំនួយផ្លូវច្បាប់និងស្តារនីតិសម្បទាដល់កុមាររងគ្រោះដោយ (OCSE) និងគ្រួសារ | MoSVY<br>MoWA<br>CNCW | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | ៣.៣.១៦ | ផ្តល់សេវាព្យាបាលផ្នែករាងកាយនិងផ្លូវចិត្តដល់កុមាររងគ្រោះដោយសារ(OCSE) | MoSVY<br>MoH | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | ៣.៣.១៧ | ផ្តល់សេវាពិគ្រោះយោបល់តាមទូរសព្ទ និងព័ត៌មានអំពីការការពារខ្លួនពី(OCSE)ដល់កុមាររងគ្រោះនិងងាយរងគ្រោះ | CNCC | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | ៣.៣.១៨ | សម្របសម្រួលសំណាងជំងឺចិត្តនិងសំណាងបដិទានដល់កុមាររងគ្រោះដោយអំពើហិង្សា និង (OCSE) | MoSVY | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |

| ចង្កោមសកម្មភាព | | សូចនាករលទ្ធផលក្នុងឆ្នាំ | | សកម្មភាពអនុវត្ត | | ស្ថាប័នទទួលខុសត្រូវ | ពេលវេលា 2025-2030 | | | | | | ប្រភពធនធាន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | 1 | 2 | 3 | 4 | 5 | 6 | |
| | | | | ៣.៣.១៩ | ធ្វើសមាហរណកម្មកុមាររងគ្រោះដោយអំពើហិង្សា និង(OCSE) ទៅគ្រួសារនិងសហគមន៍វិញ។ | MoSVY | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| ៣.៤ | ពង្រឹងប្រព័ន្ធឆ្លើយតបតាមរយៈការផ្តល់សេវាកិច្ចអន្តរាគមន៍ស្នូល សេវាសន្តិសុខសង្គមនិងការបណ្តុះបណ្តាលជំនាញដល់ជនងាយរងគ្រោះដោយសារអំពើហិង្សានិងការកេងប្រវ័ញ្ចកម្លាំងពលកម្មមកលើកុមារ | ៣.៤ក | ជនងាយរងគ្រោះដោយសារអំពើហិង្សា និងការកេងប្រវ័ញ្ចកម្លាំងពលកម្មមកលើកុមារ បានទទួលសេវាកិច្ចអន្តរាគមន៍ស្នូល សេវាសន្តិសុខសង្គម និងការបណ្តុះបណ្តាលជំនាញ | ៣.៤.១ | រៀបចំក្រុមការងារ និងការអនុវត្តកិច្ចអន្តរាគមន៍ស្នូលស្តីពីការទប់ស្កាត់ និងដកហូតពលកម្មកុមារនិងកិច្ចអន្តរាគមន៍រហ័ស រួមបញ្ចូលទាំងសេវាសន្តិសុខសង្គមនិងកម្មវិធីបណ្តុះបណ្តាល១,៥លាននាក់។ | MoLVT | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |

| | |
|---|---|
| **យុទ្ធសាស្ត្រទី៤ :** | **ការរៀបចំក្របខ័ណ្ឌគតិយុត្តនិងប្រព័ន្ធយុត្តិធម៌** |
| **គោលបំណង :** | **ពង្រឹងក្របខ័ណ្ឌច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្ត ដោយអនុលោមតាមបទដ្ឋានអន្តរជាតិដើម្បីផ្តល់កិច្ចការពារកុមាររងគ្រោះដោយអំពើហិង្សាគ្រប់ទម្រង់ និងការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ។** |
| **លទ្ធផលរំពឹងទុក :** | **កុមាររងគ្រោះដោយអំពើហិង្សាគ្រប់ទម្រង់ និងការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញទទួលបានការគាំពារដោយក្របខ័ណ្ឌច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្ត។** |
| សូចនាករលទ្ធផលទី៤ក : | សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារកុមារត្រូវបានអនុម័តដោយរដ្ឋសភា និងប្រកាសដាក់ឱ្យប្រើប្រាស់ផ្លូវការ។ |
| សូចនាករលទ្ធផលទី៤ខ : | សេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន ត្រូវបានអនុម័តដោយរដ្ឋសភា និងប្រកាសដាក់ឱ្យប្រើប្រាស់ផ្លូវការ។ |
| សូចនាករលទ្ធផលទី៤គ : | ភាគរយនៃមន្ត្រីរាជការ កុមារ ឪពុកម្តាយ និងអ្នកពាក់ព័ន្ធមានការយល់ដឹងខ្លឹមសារ និងអត្ថប្រយោជន៍នយោបាយពាក់ព័ន្ធនឹងកិច្ចការពារកុមារ។ |

**ចង្កោមសកម្មភាពនិងសកម្មភាពអនុវត្ត**

| ចង្កោមសកម្មភាព | | សូចនាករ លទ្ធផលក្នុងឆ្នាំ | | សកម្មភាពអនុវត្ត | | ស្ថាប័នទទួលខុសត្រូវ | ពេលវេលា 2025-2030 | | | | | | ប្រភពធនធាន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | 1 | 2 | 3 | 4 | 5 | 6 | |
| ៤.១ | ពិនិត្យនិងបំពេញបន្ថែមចន្លោះខ្វះខាតខ្លឹមសារនៅក្នុងក្របខ័ណ្ឌគតិយុត្ត | ៤.១ក | សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារកុមារត្រូវបានពិនិត្យនិងអនុម័តដោយស្ថាប័ននីតិប្បញ្ញត្តិ | ៤.១.១ | ពិនិត្យនិងកែសម្រួលសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារកុមារចុងក្រោយដែលដាក់បញ្ចូលបញ្ញតិពាក់ព័ន្ធនឹង OCSE គ្រប់ទម្រង់ និងការរំលោភបំពានកុមារក្នុងបរិបទទេសចរណ៍ការងារស្ម័គ្រចិត្ត (Voluntourism) | MoSVY | X | | | | | | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ៤.១.២ | សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារកុមារ ចុងក្រោយត្រូវបានពិនិត្យនិងឯកភាពពីថ្នាក់ដឹកនាំក្រសួង ស.អ.យ. | MoSVY | X | | | | | | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ៤.១.៣ | សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារកុមារ ត្រូវដាក់ឆ្លងគណៈរដ្ឋមន្ត្រី | MoSVY | X | | | | | | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ៤.១.៤ | សេចក្ដីព្រាងច្បាប់ស្ដីពីកិច្ចការពារកុមារ ត្រូវដាក់ឆ្លងស្ថាប័ននីតិប្បញ្ញត្តិដើម្បីអនុម័ត | MoSVY | | X | X | | | | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ៤.១.៥ | រៀបចំផ្សព្វផ្សាយច្បាប់ស្ដីពីកិច្ចការពារកុមារ។ | MoSVY | | | | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | ៤.១ខ | សេចក្ដីព្រាងច្បាប់ស្ដីពីបទល្មើសបច្ចេកវិទ្យាព័ត៌មានត្រូវបានអនុម័តដោយស្ថាប័ននីតិប្បញ្ញត្តិ | ៤.១.៦ | សេចក្ដីព្រាងច្បាប់ស្ដីពីបទល្មើសបច្ចេកវិទ្យាព័ត៌មានដែលដាក់បញ្ចូលបទប្បញ្ញត្តិគ្រប់គ្រាន់ពាក់ព័ន្ធនឹងបទល្មើសបច្ចេកវិទ្យា និងOCSE ត្រូវដាក់ឆ្លងគណៈរដ្ឋមន្ត្រី | MoI | X | | | | | | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ៤.១.៧ | សេចក្ដីព្រាងច្បាប់ស្ដីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន ត្រូវដាក់ឆ្លងស្ថាប័ននីតិប្បញ្ញត្តិដើម្បីអនុម័ត | MoI | | X | X | | | | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ៤.១.៨ | រៀបចំផ្សព្វផ្សាយច្បាប់ស្ដីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន។ | MoI | | | | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | ៤.១គ | ពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្ដីពីនីតិវិធីបណ្ដឹង ត្រូវបានពិនិត្យនិងពិចារណាដើម្បីផ្ដល់សច្ចាប័ន | ៤.១.៩ | សិក្សាស្រាវជ្រាវលើស្ថានភាពនៃការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្ដីពីនីតិវិធីបណ្ដឹង | CNCC | X | X | | | | | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ៤.១.១០ | ទស្សនកិច្ចសិក្សានៅប្រទេសដែលបានផ្ដល់សច្ចាប័ននិងកំពុងអនុវត្ត | CNCC | X | X | | | | | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ៤.១.១១ | បណ្ដុះបណ្ដាលគ្រូបង្គោល និងពង្រឹងសមត្ថភាពមន្ត្រីថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិស្ដីពីពិធី | CNCC | X | X | | | | | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | សារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារ ស្តីពីនីតិវិធីបណ្តឹង។ | | | | | | | | |
| | | ៤.១ឃ | គោលការណ៍ណែនាំស្តីពីសុវត្ថិភាពកុមារត្រូវបានបង្កើត | ៤.១.១២ | បង្កើតគោលការណ៍ណែនាំស្តីពីសុវត្ថិភាពកុមារ | CNCC | X | X | | | | | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ៤.១.១៣ | បណ្តុះបណ្តាលនិងពង្រឹងការអនុវត្តគោលការណ៍ណែនាំស្តីពីសុវត្ថិភាពកុមារនៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធ | CNCC | X | X | | | | | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ៤.១.១៤ | ពិនិត្យកែសម្រួលនិងជំរុញការអនុវត្តគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីការចូលរួមរបស់កុមារ។ | CNCC | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| ៤.២ | ជំរុញការអនុវត្តគោលនយោបាយពាក់ព័ន្ធនឹងកិច្ចការពារកុមារ និងការប្តេជ្ញារបស់រាជរដ្ឋាភិបាលលើការលុបបំបាត់អំពើហិង្សាលើកុមារ | ៤.២ក | ចំនួនមន្ត្រីនិងអ្នករៀបចំលិខិតបទដ្ឋានគតិយុត្តនិងផែនការមានការយល់ដឹងពីខ្លឹមសារគោលនយោបាយពាក់ព័ន្ធនឹងកិច្ចការពារកុមារ | ៤.២.១ | បង្កើនការផ្សព្វផ្សាយគោលនយោបាយស្តីពីប្រព័ន្ធកិច្ចការពារកុមារ រួមទាំងទិដ្ឋភាពនៃពលកម្មកុមារ ដល់មន្ត្រីក្រសួង ស្ថាប័នថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការពាក់ព័ន្ធ | CNCC<br>NCCL | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ៤.២.២ | ជំរុញការផ្សព្វផ្សាយនិងអនុវត្តការប្តេជ្ញារបស់រាជរដ្ឋាភិបាលលើការលុបបំបាត់អំពើហិង្សាលើកុមារ | CNCC | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ៤.២.៣ | បង្កើនការផ្សព្វផ្សាយគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារដល់មន្ត្រីក្រសួង ស្ថាប័នថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការពាក់ព័ន្ធ | MoSVY | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ៤.២.៤ | បង្កើនការផ្សព្វផ្សាយគោលនយោបាយវត្តសង្គហកុមារដល់មន្ត្រីសង្ឃ និងអ្នកពាក់ព័ន្ធ | MoCAR | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ៤.២.៥ | រៀបចំការណែនាំអំពីកាតព្វកិច្ចក្នុងការផ្តល់ការបណ្តុះបណ្តាលគ្រូនិងអ្នកគ្រប់គ្រង ដើម្បីលើកកម្ពស់ការយល់ដឹងអំពីការការពារកុមារនៅក្នុងគោលនយោបាយនិងផែនការសកម្មភាពរបស់សាលារៀន រួមទាំងការឆ្លើយតបទៅនឹងអំពើហិង្សានៅក្នុងសាលារៀន និងយន្តការបញ្ជូនបន្តដែលមានស្រាប់ការអប់រំនិងការបណ្តុះបណ្តាលប្រកបដោយវិន័យវិជ្ជមានដើម្បីគាំទ្រគ្រូបង្រៀនក្នុងការលើកកម្ពស់និងដឹកនាំដោយគ្មានអំពើហិង្សានៅថ្នាក់រៀន។ | MoEYS | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ៤.២.៦ | អនុវត្តវិធានការអធិការកិច្ចការងារ ដើម្បីពង្រឹងលក្ខខណ្ឌការងារ សហគមន៍សុខសាន្តសមភាពយេនឌ័រ ទារកដ្ឋាននិងកន្លែងទុកដាក់ក្មេងក្នុងគោលដៅលើកកម្ពស់ផលិតភាពការងារ និងសុវត្ថិភាពកម្មករនិយោជិតវ័យក្មេងនិងកុមារតូច។ | MoLVT | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ៤.២ខ | ចំនួនបទដ្ឋានគតិយុត្តនិងបទដ្ឋានអប្បបរមាដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារត្រូវបានបង្កើតនិងវិសោធនកម្ម | ៤.២.៧ | រៀបចំនិងអនុវត្តបទដ្ឋានអប្បបរមាស្តីពីការថែទាំកុមារក្រៅកន្លែងថែទាំ និងនៅក្នុងកន្លែងថែទាំឆ្លើយតបគោលនយោបាយថែទាំជំនួសចំពោះកុមារ២០២៤ | MoSVY | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ៤.២.៨ | រៀបចំនិងអនុវត្តប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារឆ្នាំ២០២៤ | MoSVY | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ៤.២.៩ | បង្កើតនិងអនុវត្តបទដ្ឋានអប្បបរមាសម្រាប់ថែទាំនិងកិច្ចការពារកុមារមានពិការភាព | MoSVY | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ៤.២.១០ | រៀបចំអនុស្សរណៈនៃការយោគយល់គ្នា(MoU) និងនីតិវិធីប្រតិបត្តិ(SOP) ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការកិច្ចការពារកុមារដែលរងផលប៉ះពាល់ដោយការធ្វើទេសន្តរប្រវេសន៍រវាងប្រទេសថៃនិងប្រទេសកម្ពុជា | MoSVY | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ៤.២.១១ | ផ្សព្វផ្សាយនីតិវិធីប្រតិបត្តិកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ | MoSVY | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ៤.២.១២ | ធ្វើវិសោធនកម្មប្រកាស និង | MoSVY | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | អនុក្រឹត្យពាក់ព័ន្ធ ឱ្យស្របតាមគោលនយោបាយនិងច្បាប់ | | | | | | | |
| | | | | ៤.២.១៣ | ធ្វើវិសោធនកម្មច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ។ | MoWA<br>CNCW | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ៤.២.១៤ | រៀបចំផែនការសកម្មភាពជាតិស្ដីពីការបង្ការទប់ស្កាត់អាពាហ៍ពិពាហ៍នៅវ័យក្មេង និងការមានផ្ទៃពោះនៅវ័យជំទង់ ឆ្នាំ២០២៥-២០៣០ | MoWA<br>CNCW | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ៤.២.១៥ | ធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រស្ដីពីការចិញ្ចឹមកូនបែបវិជ្ជមាន | MoWA<br>CNCW | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |

| | |
|---|---|
| **យុទ្ធសាស្ត្រទី៥ :** | **ការត្រួតពិនិត្យនិងវាយតម្លៃ** |
| **គោលបំណង :** | **អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងជ្រោយមួយសម្រាប់ប្រមូលទិន្នន័យពិនិត្យ វាយតម្លៃ និងរាយការណ៍អំពីបទពិសោធដែលកុមារក្នុងប្រទេសកម្ពុជាបានជួបប្រទះ។** |
| **លទ្ធផលរំពឹងទុក :** | **របាយការណ៍វាយតម្លៃផែនការសកម្មភាពជាតិត្រូវបានប្រើប្រាស់ជាធាតុចូលក្នុងការរៀបចំផែនការថ្មី បទដ្ឋានគតិយុត្ត គោលនយោបាយ និងច្បាប់ពាក់ព័ន្ធកិច្ចការពារកុមារ។** |
| សូចនាករលទ្ធផលទី៥ក : | ប្រព័ន្ធគ្រប់គ្រងទិន្នន័យករណីអំពើហិង្សាលើកុមារនិងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញត្រូវបានបង្កើតឡើង។ |
| សូចនាករលទ្ធផលទី៥ខ : | ឧបករណ៍ប្រមូលទិន្នន័យករណីអំពើហិង្សាលើកុមារនិងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញត្រូវបានបង្កើតនិងប្រើប្រាស់។ |

**ចង្កោមសកម្មភាពនិងសកម្មភាពអនុវត្ត**

| ចង្កោមសកម្មភាព | | សូចនាករលទ្ធផលក្នុងឆ្នាំ | | សកម្មភាពអនុវត្ត | | ស្ថាប័នអនុវត្ត | ពេលវេលា 2024-2030 | | | | | | ប្រភពធនធាន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | 1 | 2 | 3 | 4 | 5 | 6 | |
| ៥.១ | បង្កើតក្របខ័ណ្ឌត្រួតពិនិត្យ និងវាយតម្លៃពហុវិស័យ | ៥.១ក | ឧបករណ៍ប្រមូលទិន្នន័យពីក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធត្រូវបានបង្កើតនិងប្រើប្រាស់ផ្លូវការ | ៥.១.១ | បង្កើតវិធីសាស្ត្រប្រមូលទិន្នន័យតាមឌីជីថលដើម្បីវាស់វែងពីវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពជាតិ | CNCC | X | X | | | | | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ៥.១.២ | ផ្សព្វផ្សាយវិធីសាស្ត្រប្រមូលទិន្នន័យតាមឌីជីថលដល់មន្ត្រីបង្គោលក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការវាស់វែងផែនការសកម្មភាពជាតិ | CNCC | X | X | | | | | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ៥.១.៣ | ត្រួតពិនិត្យនិងវាយតម្លៃក្របខ័ណ្ឌគោលនយោបាយ កិច្ចអន្តរាគមន៍ស្នូល និងវឌ្ឍនភាពនៃយន្តការការងារថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិក្នុងការទប់ស្កាត់ ពលកម្មកុមារ។ | MoLVT | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | ៥.១ខ | របាយការណ៍វឌ្ឍនភាពត្រូវបានរាយការណ៍តាមពេលកំណត់ ដោយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ | ៥.១.៤ | មន្ត្រីបង្គោលក្រសួង ស្ថាប័ន រាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពជាតិជូនដល់អគ្គលេខាធិការដ្ឋាន ក.ជ.ក. | ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ៥.១.៥ | បណ្តុះបណ្តាលមន្ត្រីលេខាធិការដ្ឋាន ក.ជ.ក. រាជធានី ខេត្តស្តីពីវិធីសាស្ត្រការប្រមូលទិន្នន័យរដ្ឋបាលថ្នាក់ក្រោមជាតិ | CNCC រាជធានី ខេត្ត | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| | | | | ៥.១.៦ | អគ្គលេខាធិការដ្ឋាន ក.ជ.ក. ធ្វើរបាយការណ៍បូកសរុបវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពជាតិ។ | CNCC | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |
| ៥.២ | ពង្រឹងប្រព័ន្ធប្រមូលទិន្នន័យនិងរាយការណ៍ | ៥.២ក | បញ្ហានានាស្តីពីអំពើហិង្សាលើកុមារ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ | ៥.២.១ | ពិនិត្យការអនុវត្តផែនការសកម្មភាពជាតិដោយក្រសួងស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិការ | CNCC | X | X | X | X | X | X | ថវិការដ្ឋនិងដៃគូអភិវឌ្ឍ |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ដើម្បីផ្តល់ភស្តុតាង សម្រាប់រៀបចំតាក់តែង គោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំ | | ដែលបានបញ្ចូលក្នុងរបៀបវារៈ សិក្ខាសាលា ឬកិច្ចប្រជុំ បច្ចេកទេស | | ទប់ស្កាត់និងឆ្លើយតបចំពោះ អំពើហិង្សាលើកុមារ | | | | | | | | |
| | | | ៥.២.២ | កែលម្អប្រព័ន្ធប្រមូលទិន្នន័យ របស់រដ្ឋាភិបាលតាមឌីជីថល (Primero, CPIMS, Commune Database និងផ្សេងៗទៀត) ដើម្បីប្រមូលទិន្នន័យដែលអាច ប្រៀបធៀបបានអំពីទិន្នន័យ អំពើហិង្សាលើកុមារគ្រប់ទម្រង់ (រាងកាយ អារម្មណ៍ ផ្លូវភេទ) និងគ្រប់ទីកន្លែង (ខ្នងផ្ទះ សាលារៀន វត្តអារាម ស្ថាប័ន និងសហគមន៍) | MoSVY<br>MoP | X | X | X | X | X | X | ថវិការដ្ឋនិង ដៃគូអភិវឌ្ឍ |
| | | | ៥.២.៣ | ត្រួតពិនិត្យការអនុវត្តផែនការ សកម្មភាពជាតិដោយរដ្ឋបាល ថ្នាក់ក្រោមជាតិ | CNCC<br>រាជធានី ខេត្ត | | X | X | X | X | X | ថវិការដ្ឋនិង ដៃគូអភិវឌ្ឍ |
| | | | ៥.២.៤ | សមាហរណកម្មសូចនាករ SDG ទាក់ទងនឹងអំពើហិង្សាលើ កុមារ ទៅក្នុងការអង្កេតថ្នាក់ ជាតិដែលមានស្រាប់ (CENSUS, CDHS,CSES និងផ្សេងៗ)។ | MoP | | X | X | X | X | X | ថវិការដ្ឋនិង ដៃគូអភិវឌ្ឍ |
| | ៥.២ខ | របាយការណ៍វាយតម្លៃផែនការ សកម្មភាពជាតិត្រូវបានផ្សព្វផ្សាយ និងប្រើប្រាស់ជាធាតុចូលក្នុងការ រៀបចំផែនការថ្មី និងការរៀបចំ | ៥.២.៥ | អង្កេតដើមគ្រាលើផែនការ សកម្មភាពជាតិ | CNCC | X | | | | | | ថវិការដ្ឋនិង ដៃគូអភិវឌ្ឍ |
| | | | ៥.២.៦ | វាយតម្លៃពាក់កណ្តាលអាណត្តិ ការអនុវត្តផែនការសកម្មភាពជាតិ | CNCC | | | X | | | | ថវិការដ្ឋនិង ដៃគូអភិវឌ្ឍ |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ និងច្បាប់ | ៥.២.៧ | វាយតម្លៃបញ្ចប់នៃការអនុវត្ត ផែនការសកម្មភាពជាតិ | CNCC | | | | | | X | ថវិការដ្ឋនិង ដៃគូអភិវឌ្ឍ |
| | | | | ៥.២.៨ | រួមបញ្ចូលសូចនាករ «SDG» របស់កម្ពុជាដែលទាក់ទងនឹង អំពើហិង្សាលើកុមារ ទៅក្នុង ផែនការយុទ្ធសាស្ត្ររបស់ រដ្ឋាភិបាលដែលមានស្រាប់ («NSDP» និងផែនការ យុទ្ធសាស្ត្រជាតិប្រាំឆ្នាំរបស់ ក្រសួង ស្ថាប័ន) | MoP ក្រសួង ស្ថាប័ន ពាក់ព័ន្ធ | X | X | X | X | X | X | ថវិការដ្ឋនិង ដៃគូអភិវឌ្ឍ |
| | | | | ៥.២.៩ | គាំទ្រការកសាងសមត្ថភាពជា ប្រចាំលើការប្រើប្រាស់ទិន្នន័យ ដើម្បីជូនដំណឹងអំពីគោល នយោបាយនិងកម្មវិធី | CNCC | X | X | X | X | X | X | ថវិការដ្ឋនិង ដៃគូអភិវឌ្ឍ |
| | | | | ៥.២.១០ | ពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មាន កិច្ចការពារកុមារ(CPIMS) សម្រាប់ពង្រឹងការបញ្ជូនទៅ រកសេវាកម្ម | MoSVY | X | X | X | X | X | X | ថវិការដ្ឋនិង ដៃគូអភិវឌ្ឍ |
| | | | | ៥.២.១១ | កសាងសមត្ថភាពដល់មន្ត្រី របស់ក្រសួងដើម្បីផ្តល់ អភិបាលកិច្ចនិងការត្រួតពិនិត្យ លើប្រព័ន្ធគ្រប់គ្រងករណី | MoSVY | X | X | X | X | X | X | ថវិការដ្ឋនិង ដៃគូអភិវឌ្ឍ |
| | | | | ៥.២.១២ | ការកសាងសមត្ថភាពដល់ បុគ្គលិកសង្គម ដើម្បីអនុវត្ត ប្រព័ន្ធគ្រប់គ្រងករណី។ | MoSVY | X | X | X | X | X | X | ថវិការដ្ឋនិង ដៃគូអភិវឌ្ឍ |

## ៤- ការវិភាគរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត

នាពេលកន្លងមក រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំឱ្យមានច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះឆ្នាំ២០០៥ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨ ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ច្បាប់ស្តីពីយុត្តិធម៌អនីតិជនឆ្នាំ២០១៦ និងច្បាប់ពាក់ព័ន្ធផ្សេងៗទៀត ក៏ដូចជាគោលនយោបាយនានារបស់រាជរដ្ឋាភិបាលពាក់ព័ន្ធការគាំពារ ថែទាំ និងអភិវឌ្ឍកុមារ រួមទាំងបញ្ហាប្រឈមដែលកុមាររងគ្រោះបានជួបប្រទះក្នុងការទទួលយកការការពារផ្នែកច្បាប់ ក្នុងគោលបំណងដើម្បីទប់ស្កាត់ កាត់បន្ថយ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារឱ្យដល់កម្រិតអតិបរមា និងលើកកម្ពស់នូវវប្បធម៌អហិង្សានិងភាពសុខដុមរមនានៅក្នុងគ្រួសារ សហគមន៍ និងសង្គម។

ការផ្សព្វផ្សាយច្បាប់និងគោលនយោបាយនានា ការផ្តល់ការអភិវឌ្ឍសមត្ថភាពដល់ដៃគូពាក់ព័ន្ធសំខាន់ៗ ដើម្បីមានចំណេះដឹងគ្រប់គ្រាន់សម្រាប់ដោះស្រាយករណីអំពើហិង្សាលើកុមារ ការផ្តល់កិច្ចការពារដល់កុមាររងគ្រោះប្រកបដោយប្រសិទ្ធភាពនិងទាន់ពេលវេលា និងការជំរុញការទទួលខុសត្រូវរបស់ជនប្រព្រឹត្តនៅចំពោះមុខច្បាប់ គឺជាកត្តាសំខាន់ក្នុងការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាពខ្ពស់។

ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០២៥-២០៣០ ជាផែនការសកម្មភាពសម្រាប់អនុវត្ត ដែលតម្រូវឱ្យដៃគូទាំងអស់ចូលរួមចំណែកក្នុងការអនុវត្តផែនការនេះ ដើម្បីសម្រេចបានជោគជ័យរួម។ ហេតុដូច្នេះ ការស្នើឱ្យមានការពិនិត្យការធ្វើវិសោធនកម្មច្បាប់មួយចំនួន និង/ឬ កែសម្រួលលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា ការរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តថ្មី ព្រមទាំងជំរុញការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារកុមារឱ្យបានរួចរាល់ ក្នុងគោលបំណងដើម្បីធ្វើឱ្យប្រសើរឡើងសម្រាប់ក្របខ័ណ្ឌគតិយុត្តដែលមានស្រាប់ និងសម្រាប់ការអនុវត្តរយៈពេលវែង។

## ៥- គម្រោងចំណាយ

ដើម្បីអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០២៥-២០៣០ នេះត្រូវប្រើប្រាស់ថវិកាជាតិ ដែលតម្រូវឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវគ្រោងថវិកានៅក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់សាមីក្រសួង ស្ថាប័ននីមួយៗ ដោយធ្វើការវិភាជថវិកាប្រចាំឆ្នាំតាមលទ្ធភាពថវិកាជាតិជាក់ស្តែង ស្របតាមសារាចររបស់រាជរដ្ឋាភិបាលស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកានិងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ និងថវិកាដែលទទួលបានពីដៃគូអភិវឌ្ឍ ផ្នែកឯកជន សង្គមស៊ីវិល និងសប្បុរសជន។

## ៦- ការត្រួតពិនិត្យនិងវាយតម្លៃ

ដើម្បីឱ្យផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០២៥-២០៣០ នេះអនុវត្តបានដោយជោគជ័យនិងសម្រេចបានលទ្ធផលតាមការរំពឹងទុកនិងប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ដើម្បីឧត្តមប្រយោជន៍របស់កុមារ តម្រូវឱ្យមានការត្រួតពិនិត្យនិងវាយតម្លៃ។ ការអនុវត្តនេះគួរបញ្ចូលនូវយន្តការនានា ដូចខាងក្រោម៖

### ៦.១- យន្តការសម្របសម្រួលថ្នាក់ជាតិ

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ មានភារកិច្ចសម្របសម្រួល ត្រួតពិនិត្យនិងវាយតម្លៃលើការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០២៥-២០៣០ ដោយធ្វើការផ្សព្វផ្សាយ និងជំរុញឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ បញ្ចូលសកម្មភាពដែលពាក់ព័ន្ធទៅ

ក្នុងផែនការសកម្មភាព ផែនការថវិកាប្រចាំឆ្នាំ និងរាយការណ៍ជូនក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ធ្វើការបូកសរុបនិងធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពពីការអនុវត្តផែនការសកម្មភាពជាតិនេះជូនរាជរដ្ឋាភិបាល។

ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិលដែលពាក់ព័ន្ធ ត្រូវចាត់តាំងមន្ត្រីបង្គោលទទួលខុសត្រូវសម្របសម្រួល និងរាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពជាតិនេះជូនក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ តាមពេលវេលាកំណត់។

## ៦.២- យន្តការសម្របសម្រួលថ្នាក់ក្រោមជាតិ

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមាររាជធានី ខេត្ត មានភារកិច្ចសម្របសម្រួលក្នុងការប្រមូលទិន្នន័យវឌ្ឍនភាពពីមន្ទីរ អង្គភាពពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការមិនមែនរដ្ឋាភិបាលដែលចូលរួមអនុវត្តផែនការសកម្មភាពជាតិនេះ ដើម្បីរាយការណ៍ជូនលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។ ជំរុញឱ្យមន្ទីរ អង្គភាពពាក់ព័ន្ធ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ រដ្ឋបាលឃុំ សង្កាត់ ដាក់បញ្ចូលសកម្មភាពទៅក្នុងផែនការសកម្មភាព និងផែនការវិនិយោគប្រចាំឆ្នាំរបស់ខ្លួន។

មន្ទីរ អង្គភាពពាក់ព័ន្ធ រដ្ឋបាលក្រុង ស្រុក ខណ្ឌ រដ្ឋបាលឃុំ សង្កាត់ និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវចាត់តាំងមន្ត្រីទទួលបន្ទុកក្នុងការសម្របសម្រួល និងរាយការណ៍ពីវឌ្ឍនភាពនៃការចូលរួមអនុវត្តផែនការសកម្មភាពជាតិនេះ ជូនលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមាររាជធានី ខេត្ត។

## ៦.៣- ប្រព័ន្ធប្រមូលទិន្នន័យ

ប្រព័ន្ធប្រមូលទិន្នន័យដើម្បីតាមដានការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០២៥-២០៣០ នឹងត្រូវបានបង្កើតឡើងដោយសហការជាមួយបណ្តាក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ សង្គមស៊ីវិល បង្កើតឧបករណ៍សម្រាប់ការត្រួតពិនិត្យ វាយតម្លៃ និងរាយការណ៍។

ប្រព័ន្ធប្រមូលទិន្នន័យនេះនឹងផ្តល់ឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធ នូវធនធានសម្រាប់អភិវឌ្ឍនិងវិភាគគោលនយោបាយ និងអាចកែលម្អការអនុវត្តក្នុងការផ្តល់សេវា។ ប្រព័ន្ធនេះនឹងរំលេចអំពីការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាពខ្ពស់ ក៏ដូចជាបញ្ហាប្រឈមក្នុងការអនុវត្ត ដែលប្រការនេះនឹងរួមចំណែកលើកកម្ពស់តម្លាភាពនិងគណនេយ្យភាពក្នុងការអនុវត្ត។ បន្ថែមលើនេះ ទិន្នន័យផ្សេងទៀតរួមមានទិន្នន័យអំពីអត្រាប្រេវ៉ាឡង់តាមរយៈការអង្កេតស្តីពីប្រជាសាស្ត្រនិងសុខភាពកម្ពុជា(CDHS) នឹងវាស់វែងអំពីវឌ្ឍនភាពផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០២៥-២០៣០។ ការត្រួតពិនិត្យនិងការវាយតម្លៃនៃផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០២៥-២០៣០ នឹងដាក់បញ្ចូលនូវរបាយការណ៍សកម្មភាពប្រចាំឆ្នាំ របាយការណ៍វាយតម្លៃនៃការអនុវត្តពាក់កណ្តាលអាណត្តិនិងការវាយតម្លៃចុងក្រោយ។

## ៧- សេចក្តីសន្និដ្ឋាន

ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០២៥-២០៣០ ត្រូវបានរៀបចំឡើងផ្អែកលើកត្តាជោគជ័យ បទពិសោធ និងមេរៀនដែលបានមកពីការអនុវត្តផែនការសកម្មភាពដើម្បីទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០១៧-២០២១ បន្តអនុវត្តរហូតដល់ឆ្នាំ២០២៣ និងរបាយការណ៍ស្តីពីការវាយតម្លៃផែនការសកម្មភាពដើម្បីទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ និងរបាយការណ៍ស្តីពីការវាយតម្លៃកណ្តាលអាណត្តិនៃវិស័យអាទិភាព ក្រោមផែនការសកម្មភាពតំបន់អាស៊ានស្តីពីការលុបបំបាត់អំពើហិង្សាលើកុមារ ២០១៦-២០២៥។ ផ្អែកលើបទពិសោធ និងអនុសាសន៍នៃការ

វាយតម្លៃផែនការទាំងពីរ តម្រូវឱ្យការរៀបចំផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០២៥-២០៣០ ដោយផ្តោតលើយុទ្ធសាស្រ្តចំនួន៥គឺ៖

(យុទ្ធសាស្រ្តទី១) ការសម្របសម្រួលនិងកិច្ចសហប្រតិបត្តិការ

(យុទ្ធសាស្រ្តទី២) ការបង្ការនិងទប់ស្កាត់

(យុទ្ធសាស្រ្តទី៣) សេវាឆ្លើយតបជាពហុវិស័យចំពោះកិច្ចការពារកុមារ

(យុទ្ធសាស្រ្តទី៤) ការរៀបចំក្របខ័ណ្ឌគតិយុត្តនិងប្រព័ន្ធយុត្តិធម៌ និង

(យុទ្ធសាស្រ្តទី៥) ការត្រួតពិនិត្យនិងវាយតម្លៃ។

ក្នុងយុទ្ធសាស្រ្តទាំង៥ខាងលើ តម្រូវឱ្យគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ សង្គមស៊ីវិល អង្គការផ្អែកលើជំនឿសាសនា ក្រុមកុមាររងគ្រោះនិងងាយរងគ្រោះ និងសាធារណជនទូទៅ ចូលរួមអនុវត្តផែនការសកម្មភាពជាតិនេះប្រកបដោយការទទួលខុសត្រូវ ដើម្បីផ្លាស់ប្តូរឥរិយាបថលើកុមារជាវិជ្ជមាន លុបបំបាត់អំពើហិង្សាលើកុមារ ធានាបាននូវសិទ្ធិជាមូលដ្ឋាន និងឧត្តមប្រយោជន៍របស់កុមារ។

# សន្ទានុក្រម

**១- កុមារ** សំដៅដល់ជនដែលមានអាយុក្រោម១៨ឆ្នាំ។

**២- អំពើហិង្សាលើកុមារ** សំដៅដល់ការធ្វើបាបលើរូបរាងកាយ ផ្លូវចិត្ត និងផ្លូវភេទរបស់កុមារ។

(១) អំពើហិង្សាលើរាងកាយកុមារ ជាអាទិ៍៖

(ក) ការទះកំផ្លៀង ក្តិច ទាត់ ឬរុញ/ច្រាន។

(ខ) ការវាយដោយកណ្តាប់ដៃ ឬវត្ថុអ្វីមួយ។

(គ) ការអុជឬធ្វើឱ្យរលាក។

(ឃ) ការវាយដោយរំពាត់។

(ង) ការគំរាមកំហែងដោយអាវុធ ដូចជាកាំបិតឬកាំភ្លើងជាដើម។

(ច) ការបង្ខំ ការតម្រូវ ការលើកទឹកចិត្ត ឬការបង្គឱ្យកុមារចូលរួមក្នុងសកម្មភាពណាមួយដែលអាចមានគ្រោះថ្នាក់ចំពោះរាងកាយ(ឧទាហរណ៍ ការលើករបស់ធ្ងន់ៗលើសពីសមត្ថភាពរាងកាយ ការឱ្យកុមារលុតជង្គង់ ឈរ ឬរត់ក្រោមកម្តៅថ្ងៃក្នុងរយៈពេលយូរ)។

(២) អំពើហិង្សាផ្លូវចិត្តកុមារ ជាអាទិ៍៖

(ក) ការធ្វើឱ្យកុមារមានអារម្មណ៍ថា គ្មានតម្លៃ ពិបាកចិត្ត មិនមានការស្រឡាញ់ថ្នាក់ថ្នម ឬមានតម្លៃតែនៅពេលដែលកុមារបំពេញតម្រូវការរបស់អ្នកដទៃ។

(ខ) ធ្វើឱ្យកុមារមានអារម្មណ៍ថា មានការគំរាមកំហែងឬមានគ្រោះថ្នាក់។

(៣) អំពើហិង្សាផ្លូវភេទកុមារ គឺជាការធ្វើឱ្យកុមារចូលរួមសកម្មភាពណាមួយ ដើម្បីចំណង់ផ្លូវភេទរបស់ជនណាម្នាក់ ជាអាទិ៍៖

(ក) ការរួមភេទនិងការប៉ះពាល់បែបផ្លូវភេទ។

(ខ) ការបង្ហាញសកម្មភាពផ្លូវភេទទៅដល់កុមារ ដូចជាការឱ្យកុមារមើលរឿងអាសអាភាស សកម្មភាពរួមភេទជាដើម។

(គ) ការប្រើប្រាស់ភាសាទាក់ទងផ្លូវភេទ នៅពេលនិយាយជាមួយកុមារ។

(ឃ) ការលើកទឹកចិត្តកុមារឱ្យប្រព្រឹត្តអាកប្បកិរិយាមិនសមរម្យខាងផ្លូវភេទ។

(ង) ការមានចេតនាឱ្យកុមារប្រព្រឹត្តសកម្មភាពខាងលើ។

**៣- ការមិនអើពើ** សំដៅដល់ការខកខានក្នុងការផ្តល់តម្រូវការមូលដ្ឋានដល់កុមារ និងការពារពួកគេពីគ្រប់ទម្រង់នៃអំពើហិង្សា និងការកេងប្រវ័ញ្ច។ ការមិនអើពើលើកុមារ កើតឡើងដោយសារឪពុកម្តាយ អ្នកអាណាព្យាបាល ឬអ្នកថែទាំ រួមមាន៖

(ក) មិនផ្តល់អាហារ សម្លៀកបំពាក់ និងទីជម្រកសមរម្យគ្រប់គ្រាន់ដល់កុមារ។

(ខ) បោះបង់ចោលកុមារនិងបណ្តេញកុមារចេញពីផ្ទះ។

(គ) មិនការពារកុមារពីគ្រោះថ្នាក់ផ្លូវរាងកាយនិងផ្លូវចិត្ត។

(ឃ) មិនធានានូវការទទួលបានការថែទាំសុខភាពសមស្រប។

(ង) មិនធានាឱ្យមានការគ្រប់គ្រងគ្រប់គ្រាន់និងការដាក់កុមារឱ្យរស់នៅជាមួយអ្នកថែទាំមិនល្អគ្រប់គ្រាន់។



ស-៤៥

**៤- ការកេងប្រវ័ញ្ច** សំដៅដល់ការកេងប្រវ័ញ្ចសេដ្ឋកិច្ចឬការកេងប្រវ័ញ្ចផ្លូវភេទ ហើយរួមបញ្ចូលទាំងពលកម្មកុមារ អំពើជួញដូរសម្រាប់គោលបំណងផ្លូវភេទ ឬពលកម្មដោយបង្ខំ និងទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ។

**៥- ការកេងប្រវ័ញ្ចកម្លាំងពលកម្ម** សំដៅលើសកម្មភាពទាំងឡាយណា ដែលទាញយកប្រយោជន៍ ពីអ្នកស្វែងរកការងារធ្វើ ឬកម្មករនិយោជិត ក្រោមទម្រង់នៃការបោកប្រាស់ ឬការបោកបញ្ឆោត ការបង្ខិតបង្ខំ ការគំរាមកំហែង ការរំលោភសិទ្ធិសេរីភាព និងការកេងចំណេញលើស្ថានភាពរបស់អ្នកស្វែងរកការងារធ្វើ ឬកម្មករនិយោជិត ក្នុងគោលបំណងឱ្យអ្នកស្វែងរកការងារធ្វើ ឬកម្មករនិយោជិត ទទួលយកឬបំពេញការងារក្នុងលក្ខខណ្ឌការងារមិនល្អ ឬមិនអនុលោមភាពតាមច្បាប់ ជាអាទិ៍ការមិនគោរពតាមកិច្ចសន្យាការងារ ការរស់នៅមិនល្អ ការងារប្រកបដោយគ្រោះថ្នាក់ ការធ្វើការលើសរយៈពេលអតិបរមា ដែលកំណត់ដោយច្បាប់ ការងារទទួលបានប្រាក់ឈ្នួលទាប ឬគ្មានប្រាក់ឈ្នួល ការកាត់ប្រាក់ឈ្នួល ការមិនទទួលបានអត្ថប្រយោជន៍គាំពារសង្គម និងការមិនទទួលបានការអប់រំ។

**៦- ការអនុវត្តប្រកបដោយគ្រោះថ្នាក់** សំដៅដល់ការអនុវត្តដែលបង្កគ្រោះថ្នាក់ដល់សុខភាព សុខុមាលភាព និងការអភិវឌ្ឍរបស់កុមារ ដូចជាការដាក់ទណ្ឌកម្មលើរាងកាយ ការផ្តន្ទាទោសបែបឃោរឃៅ និងបែបបន្ទាបបន្ថោក ព្រមទាំងការបង្ខំឱ្យរៀបការ។ល។

**៧- អំពើហិង្សាក្នុងគ្រួសារ** សំដៅដល់សកម្មភាពដែលបុគ្គលម្នាក់ប្រើប្រាស់ទម្រង់ នៃអំពើហិង្សាណាមួយឬការរំលោភបំពានទៅលើបុគ្គលផ្សេងទៀត ដើម្បីគ្រប់គ្រងនៅក្នុងផ្ទះ។ អំពើហិង្សាក្នុងគ្រួសារ រួមមានដូចជាការរំលោភបំពានផ្លូវកាយ( ការវាយដំកុមារ ) ផ្លូវចិត្ត( ការជេរឬការស្តីបន្ទោសកុមារ ) ផ្លូវភេទ ជីវភាពសេដ្ឋកិច្ច និងការមើលឃើញឪពុកម្តាយវាយតប់គ្នាខាងរាងកាយជាដើម។ រូបភាពទូទៅពីអំពើហិង្សាក្នុងគ្រួសារនៅកម្ពុជា គឺនៅពេលដែលកុមារមើលឃើញឪពុកវាយម្តាយរួមទាំងសកម្មភាពនិងរូបភាពហិង្សាផ្សេងទៀតក្នុងគ្រួសារ។

**៨- អំពើហិង្សាយេនឌ័រ** សំដៅដល់ការរំលោភបំពាន ការមិនអើពើ ការកេងប្រវ័ញ្ច ឬអំពើហិង្សាលើកុមារ ក៏អាចពាក់ព័ន្ធនឹងអំពើហិង្សាយេនឌ័រផងដែរ ដែលជាអំពើហិង្សាផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ ឬជីវភាពសេដ្ឋកិច្ច ដែលប្រព្រឹត្តទៅលើអ្នកណាម្នាក់ដោយសារយេនឌ័ររបស់ពួកគេ។ អំពើហិង្សាផ្អែកយេនឌ័រ រួមមានអំពើហិង្សាក្នុងគ្រួសារ ទំនាក់ទំនងផ្លូវភេទដោយបង្ខំ និងការរំលោភសេពសន្ថវៈ។

**៩- ក្រុមកុមាររងគ្រោះនិងងាយរងគ្រោះ មានដូចខាងក្រោម៖**

- កុមារមានពិការភាព
- កុមារផ្ទុកមេរោគអេដស៍
- កុមារដែលរស់នៅក្នុងមណ្ឌលថែទាំ
- កុមារដែលរស់នៅឬធ្វើការងារតាមចិញ្ចើមថ្នល់
- កុមារនៅក្រៅសាលារៀន
- កុមារចំណាកស្រុកនិងកុមារជាកូនរបស់គ្រួសារចំណាកស្រុក
- កុមាររស់នៅតំបន់ជនបទឬតំបន់ដាច់ស្រយាល
- កុមារនៃសហគមន៍ជនជាតិដើមភាគតិច ជាតិសាសន៍ ឬសាសនាភាគតិច
- កុមារដែលមានទំនាស់នឹងច្បាប់
- កុមារដែលមានទំនាក់ទំនងផ្ទាល់ជាមួយអ្នកទេសចរការងារស្ម័គ្រចិត្ត

- កុមាររស់នៅជាមួយគ្រួសារសាច់ញាតិនិងឪពុកម្តាយធម៌
- កុមាររស់នៅជាមួយគ្រួសារសុំកូន
- កុមារដែលជាកូនរបស់ស្ត្រីជាប់ពន្ធនាគារ
- កុមារដែលគ្មានឪពុកម្តាយឬអ្នកអាណាព្យាបាលដែលខ្លួនអាចរស់នៅជាមួយ
- កុមារបែកចេញពីគ្រួសារបណ្តាលមកពីស្ថានភាពគំរាមកំហែង
- កុមារដែលមានអត្តសញ្ញាណភេទចម្រុះ(កុមារស្រឡាញ់ភេទដូចគ្នា LGBTIQ+)[១៦]
- កុមារដែលមាននិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រចម្រុះ(SOGIESC សូជី)[១៧]
- កុមារដែលឪពុកម្តាយឬអ្នកអាណាព្យាបាលរបស់ខ្លួនពុំមានលទ្ធភាពបំពេញកាតព្វកិច្ចចាំបាច់ថែរក្សា ដោយសារលំបាកបំផុត ខ្វះខាតតម្រូវការចាំបាច់ និងសេវាមូលដ្ឋាន ទីជម្រក ចំណីអាហារ សម្លៀកបំពាក់ ការអប់រំ និងការថែទាំសុខភាព
- កុមារដែលអ្នកថែទាំមានជំងឺរ៉ាំរ៉ៃ ឬមានពិការភាព ដែលមិនអាចផ្តល់ការថែទាំកុមារបានសមស្រប
- កុមារដែលគ្រួសារញៀនគ្រឿងស្រវឹង លេងល្បែងស៊ីសង ប្រើប្រាស់សារធាតុញៀនផ្សេងៗ ដែលមិនអាចផ្តល់ការថែទាំសមស្របដល់កុមារ
- កុមារដែលស្ថិតនៅក្នុងគ្រោះមហន្តរាយបង្កដោយធម្មជាតិនិងសកម្មភាពរបស់មនុស្ស។

**១០- INSPIRE** សំដៅដល់យុទ្ធសាស្ត្រចំនួនប្រាំពីរសម្រាប់ការបញ្ចប់អំពើហិង្សាលើកុមារ រួមមាន(១)ពង្រឹងការអនុវត្តច្បាប់ (២)បទដ្ឋាននិងគុណតម្លៃ (៣)បរិយាកាសប្រកបដោយសុវត្ថិភាព (៤)ការគាំទ្រដល់ឪពុកម្តាយនិងអ្នកថែទាំកុមារ (៥)ការពង្រឹងសេដ្ឋកិច្ចគ្រួសារ (៦)សេវាឆ្លើយតបនិងសេវាគាំទ្រ និង(៧)ការអប់រំនិងបំណិនជីវិត។

**១១- WePROTECT** គឺជាសេចក្តីថ្លែងការណ៍សកម្មភាពសកល ដែលបានបង្កើតយន្តការឆ្លើយតបថ្នាក់ជាតិគំរូ ដែលសង្កត់ធ្ងន់លើសារៈសំខាន់នៃការចូលរួមរបស់អ្នកពាក់ព័ន្ធនានានិងកំណត់នូវឧស្សាហកម្មពាក់ព័ន្ធធំៗនៅក្នុងកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ។ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចចូលជារដ្ឋភាគីនៃសេចក្តីថ្លែងការណ៍សកម្មភាពសកល(WePROTECT) ដែលបានចុះហត្ថលេខានៅឯកិច្ចប្រជុំកំពូលជាសកលនៅទីក្រុងអាប៊ុយដាប៊ីនៅឆ្នាំ២០១៥។

**១២- The Pathfinding Global Alliance** សំដៅដល់ការប្រមូលផ្តុំប្រទេស និងអ្នកពាក់ព័ន្ធទាំងអស់ដែលបានប្តេជ្ញាចិត្តក្នុងការពន្លឿនកិច្ចខិតខំប្រឹងប្រែងដើម្បីបញ្ចប់គ្រប់ទម្រង់នៃអំពើហិង្សាលើកុមារនៅឆ្នាំ២០៣០ និងលើសពីនេះ ស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព(SDGs)និងស្តង់ដាសិទ្ធិកុមារ។ កម្ពុជាបានចូលជាសមាជិកនៃប្រទេសភាពជាដៃគូសកលដើម្បីលុបបំបាត់អំពើហិង្សាលើកុមារ(Pathfinding Country) នៅឆ្នាំ២០១៩។

[១៦] Lesbian, Gay, Bisexual, Transgender, Intersex and Queer/Questioning (LGBTIQ)
[១៧] Sexual Orientation, Gender Identity, Gender Expression and Sex Characteristic (SOGIESC)